# របាយការណ៍សកម្មភាពប្រចាំឆ្នាំ
# អង្គការលីកាដូ

## លើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅកម្ពុជា




## ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្ស នៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំ២ពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែក ច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរក ព័ត៌មានវិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង៖**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន៖ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖(៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១ ទូរសារ៖ (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦

អ៊ីម៉ែល៖ contact@licadho-cambodia.org គេហទំព័រ៖ http://www.licadho-cambodia.org/

# មាតិកា


ការពិនិត្យលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៨ ...... ១

សេចក្តីផ្តើម ...... ១៧

ព័ត៌មានទូទៅ និងការងាររដ្ឋបាល ...... ២៣

ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ...... ២៧

ការិយាល័យសិទ្ធិកុមារ ...... ៥០

ការិយាល័យប្រឆាំងអំពើទារុណកម្ម ...... ៦៩

ការិយាល័យពេទ្យ ...... ៧៣

ការិយាល័យធនធានឯកសារ និងព័ត៌មាន ...... ៧៧

ការិយាល័យអប់រំសិទ្ធិមនុស្ស ...... ៨៤

ឧបសម្ព័ន្ធទី១: ការចេញផ្សាយផ្សេងៗរបស់អង្គការលីកាដូ ឆ្នាំ២០០៨ ...... ៨៨

# ការពិនិត្យលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៨

ការពិនិត្យលើស្ថានភាពសិទ្ធិមនុស្សនេះ គឺជ្រើសរើសតែករណីរំលោភសិទ្ធិមនុស្សសំខាន់ៗ ដែលកើតមានក្នុងកំឡុងឆ្នាំ២០០៨ តែប៉ុណ្ណោះ ។

## ករណីរំលោភដីធ្លី

**សហគមន៍ដីក្រហម-រាជធានីភ្នំពេញ:** សមាជិកដែលបន្តរស់នៅក្នុងសហគមន៍ដីក្រហមបានប្រឈមមុខនឹងការគំរាមកំហែង ការបំភិតបំភ័យ និងវិធានការផ្នែកច្បាប់ដើម្បីបង្ខំពួកគេឱ្យបោះបង់ដីរបស់ពួកគេជាបន្តបន្ទាប់ ។ តាំងពីឆ្នាំ២០០៥ ក្រុមហ៊ុន សេរិនអេនជី បានទាមទារយកដីមាត់ទន្លេ តំបន់ដីក្រហមនៅកណ្ដាលរាជធានីភ្នំពេញ ដោយយោងទៅតាមកិច្ចសន្យាមិនត្រឹមត្រូវតាមច្បាប់ជាមួយនឹងអតីតអ្នកតំណាងសហគមន៍ ។ ក្រោយពីមានការប្រឈមមុខនឹងការបណ្ដេញចេញដោយការគំរាមកំហែង ប្រជាពលរដ្ឋក្នុងសហគមន៍ជាច្រើនបានយល់ព្រមទៅរស់នៅទីតាំងថ្មីក្រៅទីក្រុងភ្នំពេញ ឬព្រមទទួលយកការទូទាត់ជាសាច់ប្រាក់ដែលមានតំលៃទាបជាងតំលៃដីលើទីផ្សារ ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋមួយចំនួននៅតែបន្តរស់នៅលើតំបន់នោះដើម្បីតវ៉ាប្រឆាំងទាមទារដីរបស់ពួកគេ ឬយ៉ាងហោចណាស់ក៏គេអាចទទួលបានការទូទាត់សំណងដោយយុត្តិធម៌ និងសមរម្យខ្លះ ។



នៅក្នុងខែមករា ឆ្នាំ២០០៨ ក្រុមហ៊ុន សេរិនអេនជី និងនគរបាលមូលដ្ឋានបានព្យាយាមបិទផ្លូវចេញ-ចូលក្នុងតំបន់ដីក្រហម ដោយការលើករនាំងកាត់ផ្លូវជុំវិញសហគមន៍ ។ នគរបាល ប៉េអឹម និងបុគ្គលិកក្រុមហ៊ុនបានយកសំបកធុងសាំងចាក់ទឹកបំពេញមកដាក់រាំងនៅលើដងផ្លូវចេញ-ចូល និងបានហាមឃាត់មិនឱ្យមានការដឹកទំនិញឆ្លងកាត់ទៅក្នុងសហគមន៍តំបន់ដីក្រហម (ទំនងមានគោលបំណងផ្ដាច់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ដីក្រហម ដែលរស់ពឹងផ្អែកលើការលក់ទំនិញនៅផ្សារ) ។ ប្រជាពលរដ្ឋបានរុះរើរនាំងបាំងផ្លូវនោះចេញដោយកំហឹងគ្រប់ពេលទាំងអស់ ។ ការប្រឈមមុខដាក់គ្នារវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនសេរិនអេនជីបានបន្តជាច្រើនថ្ងៃ និងយប់ ហើយអាជ្ញាធរព្យាយាមបង្កឱ្យមានស្ថានការតានតឹង និងញុះញង់ឱ្យមានភាពចលាចល ។ រថយន្តមួយគ្រឿង ដែលគេប្រើដើម្បីដាក់បង្ខាំងផ្លូវបានឆេះដោយគ្មានមូលហេតុ (ក្រោយពីពន្លឺអគ្គិសនីបំភ្លឺនៅតាមដងផ្លូវត្រូវបានកាត់ផ្ដាច់រយៈពេលមួយនាទីដើម្បីធ្វើឱ្យងងឹតនៅកន្លែងកើតហេតុ) ហើយភ្លាមៗនោះប្រជាពលរដ្ឋនៅតំបន់ដីក្រហមត្រូវបានចោទប្រកាន់ពីបទដុតបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ។ ការចោទប្រកាន់ដែលពុំមានបទល្មើសព្រហ្មទណ្ឌ ហើយសូម្បីភស្តុតាងក៏គ្មាននោះ គឺនៅតែបន្តយកមកប្រើដើម្បីគំរាមកំហែងមកលើអ្នកតំណាងសហគន៍ដីក្រហម ។

ជាក់ស្តែង នៅថ្ងៃទី២១ ខែមករា តំណាងសហគមន៍ម្នាក់ ឈ្មោះ រស់ ពៅ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧ ក្រោមការចោទប្រកាន់ពីបទបង្ករបួសស្នាម ហើយត្រូវបានឃុំខ្លួននៅពន្ធនាគារព្រៃស ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៦ខែ និងបន្ថែមការព្យួរទោសចំនួន ១៨ខែ ទៀត។ គាត់ត្រូវបានចោទប្រកាន់ពីបទបង្ករបួសស្នាមមកលើកម្មករក្រុមហ៊ុន សេរិនអេនជី មួយចំនួនកាលពីថ្ងៃទី៤ ខែសីហា នៅពេលដែលក្រុមកម្មករបានមករុះរើផ្ទះសម្បែងនៅក្នុងសហគមន៍។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលមានវត្តមានក្នុងកំឡុងពេលកើតហេតុបានមានប្រសាសន៍ថា គាត់មិនបានឃើញនារីរងគ្រោះបង្ករបួសស្នាមលើជនណាម្នាក់ឡើយ។ ការបណ្តេញនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើអំណះអំណាងរបស់បុគ្គលិកក្រុមហ៊ុន សេរិនអេនជី តែប៉ុណ្ណោះ ហើយការផ្តន្ទាទោសនេះពុំមានការបង្ហាញឯកសារពេទ្យដែលពាក់ព័ន្ធនឹងការបង្ករបួសស្នាមនោះទេ។

កាលពីថ្ងៃទី១៤ ខែសីហា អ្នកតំណាងសហគមន៍ដីក្រហម ឈ្មោះ ឡៅ សីហា ត្រូវបានកាត់ទោសដោយតុលាការក្រុងភ្នំពេញឱ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ និងព្យួរទោសរយៈពេល១៨ខែ។ ការចោទប្រកាន់នេះ គឺមានការពាក់ព័ន្ធនឹងបណ្តឹងក្នុងឆ្នាំ២០០៥ របស់អតីតអ្នកតំណាងសហគមន៍ ដែលបានធ្វើការចោទប្រកាន់មកលើគាត់ និងប្រជាពលរដ្ឋ ៧នាក់ ពីបទបរិហារកេរ្តិ៍ និងក្លែងបន្លំឯកសារ ហើយនៅក្នុងករណីរបស់ ឡៅ សីហា គឺបន្ថែមបទល្មើសបង្ករបួសស្នាមមួយទៀត។

**បូរីកីឡា-រាជធានីភ្នំពេញ:** កាលពីខែកក្កដា ឆ្នាំ២០០៣ ដីសម្បទានសង្គមកិច្ចមួយកន្លែងដែលសម្រាប់រៀបចំបែងចែកក្នុងបូរីកីឡា ត្រូវបានអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនធ្វើការអភិវឌ្ឍន៍លើផ្ទៃដីមួយផ្នែក ដើម្បីធ្វើពាណិជ្ជកម្មដោយបានផ្តល់ផ្ទះដល់ប្រជាពលរដ្ឋនៅលើដីដែលសល់។ គំនិតនេះត្រូវបានទទួលការសាទរ ពីព្រោះប្រជាពលរដ្ឋមិនចាំបាច់ត្រូវគេបណ្តេញចេញ ហើយពួកគាត់នឹងទទួលសំណងសម្រាប់ដីរបស់ពួកគេជាមួយ និងអគារថ្មីដែលបានសាងសង់។ សាលារាជធានីភ្នំពេញ និងអាជ្ញាធរខណ្ឌបានស្ទង់ចំនួនផ្ទៃដី និងជាលទ្ធផលមានប្រជាពលរដ្ឋ១,៧៧៦ គ្រួសារ ដែលបានចុះឈ្មោះទទួលផ្ទះនៅអគារនោះ។ បន្ថែមលើនេះម្ចាស់ផ្ទះ និងអ្នកជួលផ្ទះក៏មានសិទ្ធិទទួលបានផ្ទះដែរ ប្រសិនបើពួកគេបានរស់នៅបូរីកីឡាមានរយៈពេល៣ឆ្នាំឡើងទៅ។



នៅចុងឆ្នាំ២០០៨ រយៈពេលជាង៥ឆ្នាំកន្លងមក ហើយចាប់តាំងពីដីសម្បទានសង្គមកិច្ចត្រូវបានសាងសង់ជាលើកទីមួយដែលមានប្រជាពលរដ្ឋ១,២៥៤គ្រួសារកំពុងរង់ចាំទទួលបានផ្ទះល្វែងនៅអាគារនោះ ប៉ុន្តែមានតែ៥២២ គ្រួសារប៉ុណ្ណោះដែលបានទទួលផ្ទះល្វែងពីសាលារាជធានីភ្នំពេញ។ បច្ចុប្បន្ននេះមានអគារថ្មីចំនួន៧ល្វែងទៀតត្រូវ

បានកំពុងសាងសង់ និងអគារបីល្វែងបានសាងសង់រួច។ មានដីនៅសល់យ៉ាងច្រើនសម្រាប់សាងសង់អគារឱ្យគ្រប់គ្រួសារប្រជាពលរដ្ឋទាំងអស់ បើយោងទៅលើគម្រោងសម្បទានដំបូង ប៉ុន្តែដោយសារមានអំពើពុករលួយពីមន្ត្រីមូលដ្ឋាន និងភាពមិនប្រក្រតីក្នុងដំណើរការបែងចែកផ្ទះបានធ្វើឱ្យប្រជាពលរដ្ឋបូរីកីឡាមានភាពច្របូកច្របល់។ មានព័ត៌មានបានលេចឮថា មានគ្រួសារខ្លះបានទទួលផ្ទះនៅលើអគារនោះដែលពួកគេមិនមែនជាប្រជាពលរដ្ឋបូរីកីឡាទេ ចំណែកឯប្រជាពលរដ្ឋបូរីកីឡាក្រីក្របំផុតនោះបែរជាទុកពួកគេចោលឱ្យគ្មានទីជម្រកសមរម្យ។ ប្រជាពលរដ្ឋបានដាក់បណ្តឹងពុករលួយចំនួន២ផ្សេងៗគ្នាទៅការិយាល័យសម្តេចនាយករដ្ឋមន្ត្រី បណ្តឹងទី១ដាក់ក្នុងខែធ្នូ ឆ្នាំ២០០៧ និងបណ្តឹងមួយទៀតនៅខែមិថុនា ឆ្នាំ២០០៨។ កាលពីខែសីហា ឆ្នាំ២០០៨ ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានបើកការស៊ើបអង្កេតជាផ្លូវការលើការចោទប្រកាន់ថាមានអំពើពុករលួយ។ អស់រយៈពេលជាច្រើនកន្លងមកពុំមានលទ្ធផលណាមួយត្រូវបានបង្ហាញទេ។

ស្របពេលជាមួយគ្នានេះក៏មានការព្រួយបារម្ភដែរ ដោយអាជ្ញាធរមានគម្រោងបណ្តេញក្រុមគ្រួសារមានផ្ទុកមេរោគអេដស៍ក្នុងពេលខាងមុខឆាប់ៗនេះ ដើម្បីយកទីធ្លាសម្រាប់សាងសង់អគារថ្មីរបស់ក្រសួងទេសចរណ៍។ ការអភិវឌ្ឍបានធ្វើឡើងលើទំហំដីទាំងអស់នៅបូរីកីឡា ហើយគ្រួសារប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ មិនត្រូវបានគេដាក់បញ្ចូលក្នុងបញ្ជីសម្រង់ឈ្មោះពីដំណើការទទួលបានផ្ទះឡើយ។

ឥឡូវនេះសាលារាជធានីភ្នំពេញកំពុងមានគម្រោងប្តូរទីលំនៅក្រុមគ្រួសារ ដែលមានផ្ទុកមេរោគអេដស៍ពីផ្ទះសង្គ័សីពណ៌ខៀវឱ្យទៅរស់នៅទួលសំបូរ ដែលមានចម្ងាយ២០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ កង្វះអនាម័យ និងសេវាសុខភាពយ៉ាងធ្ងន់ធ្ងរសម្រាប់ពួកគេ។ ទីតាំងថ្មីនោះមិនបានផ្តល់ស្ថានភាពរស់នៅសមរម្យដល់អ្នកផ្ទុកមេរោគអេដស៍ឡើយ សូម្បីតែអ្នកមានសុខភាពល្អក៏ពុំអាចរស់នៅទីនោះបានដែរ។ ក្រុមគ្រួសារពួកគេនឹងប្រឈមគ្រោះថ្នាក់ទៅនឹងសុខភាពទូទៅនៅតំបន់នោះ ដោយសាររស់នៅឆ្ងាយពីរាជធានីភ្នំពេញ ហើយពុំមានសេវាពេទ្យគ្រប់គ្រាន់ដូចបច្ចុប្បន្នដែលពួកគេកំពុងតែមាននោះទេ។ ក្រុមគ្រួសារទាំងនេះ ដែលបានកំពុងប្រឹងប្រែងតស៊ូរស់នៅ និងបាត់បង់ចំណូលរបស់ពួកគេ ហើយធ្វើឱ្យពួកគេកាន់តែអស់សង្ឃឹម។

**ភូមិជ័យសេនា-ខេត្តកំពត:** នៅក្នុងឆ្នាំ២០០៨ នេះ ប្រជាពលរដ្ឋមកពីភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត បានប្រឈមមុខនឹងការគំរាមកំហែងទាក់ទងនឹងករណីរំលោភដីធ្លីរបស់ពួកគាត់។ ករណីនេះពាក់ព័ន្ធទៅនឹងការរំលោភបំពានជាញឹកញាប់ពីសំណាក់នគរបាល និងមន្ត្រីយោធា ដែលមានដូចជាការបង្ករបួសស្នាម និងការបាញ់កាំភ្លើងបង្ហើរលើក្បាលរបស់ប្រជាពលរដ្ឋ និងការបណ្តេញចេញដោយបង្ខំ និងការតាំងទីលំនៅថ្មី។ នៅដើមខែមេសា មន្ត្រីនគរបាលឃុំ រួមទាំងប្រធានឃុំ និងប៉េអឹមបានធ្វើការគំរាមកំហែងប្រជាពលរដ្ឋចំនួន១៥២គ្រួសារដែលកំពុងរស់នៅក្នុងភូមិជ័យសេនា។ អាជ្ញាធរខេត្តបានចេញលិខិតមួយដែលមានចំណារថា ដីនោះត្រូវបានប្រគល់

ឱ្យក្រុមហ៊ុនឯកជនមួយ។ នៅថ្ងៃទី៦ ខែមេសា ផ្ទះមួយខ្នងរបស់ប្រជាពលរដ្ឋត្រូវបានបំផ្លាញដោយនគរបាលឃុំតាកែន។ ដោយមានកិច្ចអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាលទៅអាជ្ញាធរខេត្ត នគរបាលមូលដ្ឋាន និងមន្ត្រីយោធាបានសូមទោសប្រជាពលរដ្ឋ និងបានសន្យាថាគ្មាននរណាម្នាក់នឹងត្រូវបណ្តេញចេញដោយបង្ខំទៀតឡើយ។

តែក្រោយមក នៅក្នុងខែមេសា ជម្លោះបានកើតឡើងម្តងទៀតរវាងប្រជាពលរដ្ឋភូមិជ័យសេនា និងទាហានមកពីកងពលតូចលេខ ៣១ នៅពេលដែលទាហានបានយកដីភូមិប្រមាណជា ២០ម៉ែត្រ ដើម្បីធ្វើផ្លូវ។ ដីនេះត្រូវបានអភិវឌ្ឍដោយកងវរសេនាតូចលេខ ៣១៧ និងកងពលតូចលេខ ៣១ ដែលជាផ្នែកនៃដីសម្បទានសង្គមកិច្ចចំនួន ៤៥០ ហិកតា ដែលទំនងរដ្ឋាភិបាលទុកសម្រាប់ចែកជូនដល់គ្រួសារយុទ្ធជនពិការ។ នៅពេលដែលប្រជាពលរដ្ឋធ្វើការទាមទារដីដែលបាត់បង់ ទាហានបានបាញ់កាំភ្លើងឡើងទៅលើ ដើម្បីបំបែកហ្វូងប្រជាពលរដ្ឋ ហើយទាហានម្នាក់បានបង្ករបួសស្នាមទៅលើស្ត្រីវិកលចរិតម្នាក់។ ចុងក្រោយប្រជាពលរដ្ឋបាន "យល់ព្រម" ប្រគល់ដីរបស់ពួកគេដើម្បីសាងសង់ផ្លូវ។



នៅថ្ងៃទី២២ ខែមិថុនា ទាហានមកពីកងពលតូចលេខ ៣១ បានបិទច្រកចេញ-ចូល និងបិទផ្លូវទៅកាន់សហគមន៍។ មួយថ្ងៃមុននេះ មន្ត្រីរដ្ឋបាលព្រៃឈើ បានប្រាប់ដល់ប្រជាពលរដ្ឋរាប់រយនាក់រស់នៅក្នុងភូមិជ័យសេនាថាពួកគេចាំបាច់ត្រូវតែប្រគល់ដីឱ្យសាលាខេត្តកំពតវិញដើម្បីសាងសង់កសិដ្ឋានបណ្តុះកូនឈើ។ មន្ត្រីរដ្ឋបាលព្រៃឈើ ដោយមានការសហការពីទាហានបានអះអាងថាដីជម្លោះនេះ ជាដីរបស់រដ្ឋ ដែលប្រជាពលរដ្ឋគ្មានសិទ្ធិសង់លំនៅដ្ឋានលើដីនេះទេ ហើយពួកគេបានចាប់ផ្តើមបណ្តេញប្រជាពលរដ្ឋដោយបង្ខំតែម្តង។ ប្រជាពលរដ្ឋទាំងអស់ត្រូវបានជម្លៀសទៅកាន់ទីតាំងថ្មីដែលគេបានដឹងថាមានម្ចាស់កាន់កាប់រួចទៅហើយ ដោយមានចម្ងាយ ១០ គីឡូម៉ែត្រ ពីតំបន់ដែលពួកគេកំពុងរស់នៅសព្វថ្ងៃ។ មានសេចក្តីរាយការណ៍ថា ទាហានបានយាមកាមនៅក្នុងភូមិរុះរើផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ និងទាមទារឱ្យប្រជាពលរដ្ឋបង់ប្រាក់ថ្លៃដឹកជញ្ជូនទ្រព្យសម្បត្តិរបស់ពួកគេទៅកាន់ទីតាំងថ្មីទៀតផង។

នៅថ្ងៃទី២៤ ខែមិថុនា ទាហានបានរារាំងបុគ្គលិកអង្គការលីកាដូ និងអាដហុកមិនឱ្យចូលទៅកាន់ភូមិជ័យសេនា ដើម្បីធ្វើការស៊ើបអង្កេតពីស្ថានភាពនៅក្នុងភូមិឡើយ។ ជាមួយគ្នានេះផងដែរផ្លូវទាំងអស់ត្រូវបានបិទច្រកចេញ-ចូល។ មានសេចក្តីរាយការណ៍ជាច្រើនថា ទាហានបានគ្រប់គ្រងព្រៃឈើដោយមិនអនុញ្ញាតឱ្យចេញ-ចូលក្នុងភូមិឡើយ។ នៅថ្ងៃទី១ ខែកក្កដា ប្រជាពលរដ្ឋដែលត្រូវបានគ្រប់គ្រងដោយទាហានបានរាយការណ៍ថា ពួកគេជួបកង្វះខាតម្ហូបអាហារ។

នៅថ្ងៃទី២ ខែកក្កដា មេបញ្ជាការកងពលតូចលេខ ៣១ លោក ស៊ុន សារឿន បានអនុញ្ញាតឱ្យមន្ត្រីសិទ្ធិមនុស្សមកពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស អង្គការអាដហុក និងអង្គការលីកាដូបានចូលទៅក្នុងតំបន់ភូមិជ័យសេនា។ ទាហានបានដើរតាម បុគ្គលិកអង្គការអាដហុក និងលីកាដូក្នុងកំឡុងពេលចូលទៅក្នុងតំបន់នោះ ដែលជាហេតុធ្វើឱ្យបុគ្គលិកអង្គការ មិនអាចនិយាយជាមួយប្រជាពលរដ្ឋដោយសម្ងាត់បានឡើយ។

ទោះជាយ៉ាងណាក្តី នេះសបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋមួយចំនួនបានព្យាយាមតវ៉ាប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដែលបណ្តាលឱ្យប្រជាពលរដ្ឋបួននាក់ត្រូវបានចាប់ខ្លួនបីនាក់រត់គេចខ្លួន និងប្រជាពលរដ្ឋជាច្រើននាក់ទៀតទទួលរងរបួស។ ប្រជាពលរដ្ឋមួយចំនួនបានរត់ទៅលាក់ខ្លួននៅក្នុងព្រៃហើយ២៣នាក់ផ្សេងទៀតបានធ្វើដំណើរទៅទីក្រុងភ្នំពេញដើម្បីប្តឹងទៅអាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះប្រជាពលរដ្ឋដែលនៅសល់ត្រូវបានបណ្តេញចេញដោយបង្ខំចេញពីតំបន់នោះ ដែលពេលបច្ចុប្បន្ននេះកំពុងស្ថិតក្នុងកណ្តាប់ដៃរបស់រដ្ឋបាលព្រៃឈើ និងទាហាន។

**គងយុ-ខេត្តរតនគិរី:** ករណីរំលោភដីធ្លីដោយបុគ្គលមានអំណាចមកលើអ្នកភូមិជនជាតិភាគតិចក្នុងខេត្តរតនគិរីនៅតែបន្តដោយគ្មានដំណោះស្រាយ។ នេះរួមបញ្ចូលទាំងករណីដែលអូសបន្លាយដ៏យូររបស់អ្នកស្រី គាត កុល្យាណី ប្អូនស្រីរបស់លោក គាត ឈុន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលនៅក្នុងខែមករា ឆ្នាំ២០០៧ ត្រូវបានចោទប្រកាន់ថាបានរំលោភយកដីប្រជាពលរដ្ឋចំនួន ៤៥០ ហិកតា។ នៅក្នុងខែមេសា ឆ្នាំ២០០៨ លោក យ៉ា ណារិន ជាចៅក្រមស៊ើបសួរតុលាការខេត្តរតនគិរីបានអះអាងថា គាត់នឹងមិនស៊ើបអង្កេតក្នុងបណ្តឹងរបស់ប្រជា-ពលរដ្ឋប្រឆាំងនឹងអ្នកស្រី គាត កុល្យាណី ទៀតទេ។ គាត់បានមានប្រសាសន៍ថា គាត់មិនសប្បាយចិត្តទេ ដែលគ្មានភាគីណាមួយបង់ប្រាក់ប្រដាប់ក្តីចំនួន ១,៥០០ ដុល្លារអាមេរិក ហើយថាប្រជាពលរដ្ឋបានបដិសេធមិនអនុញ្ញាតឱ្យក្រុមហ៊ុនអ្នកស្រី គាត កុល្យាណី ចូលទៅវាស់វែងដីសម្រាប់ករណីបណ្តឹងតុលាការ។

ដូចគ្នានេះផងដែរ នៅខែសីហា ឆ្នាំ២០០៧ តុលាការពុំមានចាត់វិធានការទៅលើករណីប្រជាពលរដ្ឋចំនួន ១៨០ គ្រួសារ ដែលបានប្តឹងចោទឧត្តមសេនីយ៍ទោនៃកងយោធពលខេមរភូមិន្ទ លោក កៅ ទ្រី ពីបទរំលោភយកដីធ្លី ជាង ២០០ ហិចតា ដែលពួកគេបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ។ លោក កៅ ទ្រី មានប្រតិកម្មតបដោយការដាក់ពាក្យបណ្តឹងប្រឆាំងនឹងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានមួយចំនួន។ តុលាការខេត្តរតនគិរីបានពន្យារពេលបើកសវនាការលើករណីទាំងពីរនេះ។

នៅក្នុងខែឧសភា អាជ្ញាធរបានរារាំងការដើរក្បួនដែលត្រូវបានរៀបចំឡើងដោយក្រុមជនជាតិភាគតិចដែលរួមមាន ចារ៉ាយ ភ្នង គ្រឹង និងទំពួន ដើម្បីតវ៉ាប្រឆាំងនឹងការរំលោភយកដីធ្លី និងការកាប់ឈើខុសច្បាប់នៅ

លើទឹកដីដូនតារបស់ពួកគេ។ ក្រោយមក ប្រជាពលរដ្ឋចំនួន ៣០០ នាក់ បានរៀបចំអង្គប្រជុំជាសាធារណៈនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាលមួយដើម្បីពិភាក្សាពីការព្រួយបារម្ភរបស់ពួកគេ ក្រោមការឃ្លាំមើលពីកងកំលាំងនគរបាលដែលដាក់ពង្រាយវត្តមាននៅជិតកន្លែងប្រារព្ធព្រឹត្តិការណ៍នោះរហូត។

**ស្រុកស្នួល-ខេត្តក្រចេះ :** នៅក្នុងខែតុលា ជនជាតិដើមភាគតិចមាន ស្មៀង ភ្នង នៅក្នុងស្រុកស្នួល ខេត្តក្រចេះបាន ប្រឈមមុខជាមួយក្រុមហ៊ុន ស៊ីអាយវី ដែលថ្មីៗទើបបានទទួលដីជួលមានរយៈពេល ៩៩ឆ្នាំ ពីអាជ្ញាធរខេត្ត ដើម្បីប្រើប្រាស់ដីធ្វើចម្ការកៅស៊ូ។ មានប្រជាពលរដ្ឋ ៧៥០គ្រួសារ ដែលរស់នៅឃុំលើដីទំនាស់បានប្រាស្រ័យលើដំណាំ ដំឡូង និងធ្វើស្រែ។ នៅកំឡុងឆ្នាំនោះដែរមានការចចារយ៉ាងច្រើនលើករវាងអជ្ញាធរខេត្ត និងសហគមន៍បានធ្វើឡើង តែពុំបានឈានទៅដល់លទ្ធផលឡើយ។

កាលពីថ្ងៃទី៥ ខែតុលាប្រជាពលរដ្ឋបានប្រឈមជាមួយម៉ាស៊ីនឈូសឆាយ និងត្រាក់ទ័រ ដែលបានមកធ្វើការឈូសឆាយលើដីដំណាំប្រជាពលរដ្ឋ។ មានប្រជាពលរដ្ឋយ៉ាងច្រើនលើសលុបបានមកកាន់ទីនោះ ហើយធ្វើឱ្យកម្មកររបស់ក្រុមហ៊ុនបង្ខំបើកត្រាក់ទ័រនិងម៉ាស៊ីនឈូសឆាយចេញពីដីទំនាស់។ ពាក់ព័ន្ធជាមួយទំនាស់នេះ ក្រុហ៊ុន ស៊ីអាយវី បានដាក់ពាក្យបណ្ដឹងជាមួយនឹងអាជ្ញាធរខេត្ត ដោយបានធ្វើការចោទប្រកាន់ពីបទប្លន់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនកំឡុងពេលប្រឈមមុខជាមួយគ្នានោះ។



កាលពីថ្ងៃទី០៨ ខែតុលា អ្នកតំណាងសហគមន៍មកពីស្រុកស្នួល និងអ្នកតំណាងមកពី១១ខេត្តផ្សេងៗទៀតនៅក្នុងប្រទេស ដែលមានពាក់ព័ន្ធនឹងបញ្ហាដីធ្លីដូចគ្នាបានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីដាក់បណ្ដឹងបញ្ហាដីធ្លីជាមួយអាជ្ញាធរជាតិ។ សន្និសីទសារព័ត៌មានរួមបានធ្វើឡើង ដើម្បីទាមទារឱ្យមានការចាត់វិធានជួយលើដីកម្មសិទ្ធរបស់ពួកគេនិមួយៗ។ ពុំទាន់មានចម្លើយផ្លូវការណាមួយផ្ដល់ឱ្យសហគមន៍នោះទេ។

កាលពីថ្ងៃទី១៧ ខែវិច្ឆិកា មានអ្នកតំណាងសហគមន៍២-៣នាក់ត្រូវបានកោះហៅឱ្យឡើងតុលាការ ដើម្បីសាកសួរលើបណ្ដឹងរបស់ក្រុមហ៊ុន ស៊ីអាយវី។ មានប្រជាពលរដ្ឋយ៉ាងច្រើនបានជូនអ្នកតំណាងរបស់ពួកគេមកកាន់តុលាការ ដោយខ្លាចក្រែងអ្នកតំណាងត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកតុលាការបានផ្អាកការសាកសួរ។

**ទាហាន-យោធា ដែលពាក់ព័ន្ធនឹងដីទំនាស់:** នៅកំឡុងឆ្នាំ២០០៨ អង្គការលីកាដូបានស៊ើបអង្កេត និងចងក្រងបាន ២៧ករណី ពាក់ព័ន្ធនឹងការរំលោភដីធ្លីផ្សេងៗគ្នា ពីសំណាក់ទាហាន-យោធា ទៅលើដីប្រជាពលរដ្ឋចំនួន ១៣ខេត្ត ដែលមានការិយាល័យលីកាដូនៅទីនោះ។ ការប្រើប្រាស់កម្លាំងទាហាន ដើម្បីធ្វើការបំភិតបំភ័យ គំរាមកំហែង បង្ករបួសស្នាម និងបណ្ដេញប្រជាពលរដ្ឋចេញក្នុងពេលមានទំនាស់ដីធ្លីជួនកាល គឺមានបញ្ហាពីមន្ត្រីមាន

អំណាចជាន់ខ្ពស់ដែលជាម្ចាស់ក្រុមហ៊ុននោះ និងជាការរំលោភបំពានប្រើអំណាចខុសច្បាប់ មានការពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងទាហាននៅពេលបណ្តេញចេញ ដែលជាទូទៅបណ្តាលឱ្យមានអំពើហិង្សារងរបួស និងស្លាប់ប្រជា-ពលរដ្ឋនៅខណៈពេលនោះ។

## ការបង្ក្រាបសេរីភាពនៃការជួបជុំ

**កម្មកររោងចក្រទទួលរងរបួសក្នុងពេលធ្វើបាតុកម្ម:** នៅដើមខែកុម្ភៈ កម្មករចំនួន ៥០០ នាក់ ជាសមាជិកសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU) បានប្រមូលផ្តុំគ្នានៅខាងមុខរោងចក្រ ឃីង-ឡែន (Kingland) ដើម្បីទាមទារឱ្យទទួលយកតំណាងសហជីពចំនួន ១៩ នាក់ ដែលរោងចក្របានបណ្តេញចេញកាលពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០០៧ ឱ្យចូលធ្វើការវិញ។ កម្មករទាំងអស់បានបិទច្រកចូលទៅក្នុងរោងចក្រដោយទាមទារឱ្យមានដំណោះស្រាយដ៏សមរម្យមួយពីអ្នកគ្រប់គ្រងរោងចក្រ។

ម្ចាស់រោងចក្រ/អ្នកគ្រប់គ្រងរោងចក្រ បានបដិសេធមិនធ្វើការចរចាជាមួយក្រុមបាតុករ។ នគរបាល និងប៉េអឹមមួយក្រុមបានធ្វើការបោសសំអាតផ្លូវចូលទៅក្នុងរោងចក្រ ដែលបង្កឱ្យកម្មករចំនួន១១នាក់ទទួលរងរបួសក្នុងអំពើហិង្សានោះ។ កម្មករ ៥នាក់ ក្នុងចំណោម ១១នាក់ ត្រូវបានបញ្ជូនឱ្យសម្រាកព្យាបាលនៅគ្លីនិកមួយ។ អាជ្ញាធរមិនមានចាត់វិធានការលើជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សាមកលើកម្មករទេ។

ករណីនេះ គឺជាផ្នែកមួយនៃអំពើហិង្សាប្រឆាំងនឹងតំណាងសហជីព និងសមាជិកនៅក្នុងរោងចក្រកាត់ដេរក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

**នគរបាលបានបង្ករបួសស្នាមលើបាតុករមកពីសហព័ន្ធសហជីពយុវជនខ្មែរ:** នៅដើមខែមករា កម្មករចំនួន ៣០០ នាក់ មកពីសហព័ន្ធសហជីពយុវជនខ្មែរ ដែលធ្វើការនៅក្រុមហ៊ុនឧស្សាហកម្មសំលៀកបំពាក់កម្ពុជា នៅក្នុងខេត្តកំពង់ស្ពឺ បានធ្វើបាតុកម្មដោយអហិង្សាដើម្បីតវ៉ាជំទាស់នឹងការរំលោភបំពានច្បាប់ការងារ និងការបណ្តេញចេញកម្មករបណ្តែតចំនួន៧៨នាក់ និងអ្នកដឹកនាំសហជីពចំនួន៣នាក់។

បាតុកម្មបានបន្តអស់រយៈពេលជាច្រើនសប្តាហ៍ ដោយសារកម្មករមិនអាចធ្វើការចរចាដើម្បីរកដំណោះស្រាយមួយសមរម្យជាមួយម្ចាស់រោងចក្របាន។ នៅពេលដែលកម្មករបំរុងនឹងបិទច្រកចេញ-ចូលរោងចក្រ និងហាមឃាត់មិនឱ្យមានការនាំចេញផលិតផល ស្រាប់តែនគរបាលបានមកដល់រោងចក្រដោយមានកាន់របាំងការពារ និងដំបង ហើយបានវាយបំបែកហ្វូងបាតុករ។

ក្រោយមក កម្មកររោងចក្រទាំងអស់បាននាំគ្នាប្រមូលផ្តុំនៅមុខតុលាការខេត្តកំពង់ស្ពឺ និងបានដាក់ពាក្យបណ្តឹងចោទប្រកាន់ម្ចាស់រោងចក្រថាបានរំលោភច្បាប់ការងារ។

**អាជ្ញាធរបានហាមឃាត់ប្រតិភូ Mia Farrow មិនឱ្យចូលក្នុងសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដើម្បីគោរពវិញ្ញាណខន្ធ:** នៅថ្ងៃទី២១ ខែមករា នគរបាល និងកងរាជអាវុធហត្ថបំពាក់ដោយកាំភ្លើង និងដំបងឆក់ បានហាមឃាត់ប្រតិភូមួយក្រុមដែលដឹកនាំដោយតារាភាពយន្តសហរដ្ឋអាមេរិក លោកស្រី Mia Farrow មិនឱ្យចូលក្នុងសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ។ ក្រុមប្រតិភូមានគោលបំណងដាក់កម្រងផ្កាដើម្បីគោរពវិញ្ញាណខន្ធប្រជាពលរដ្ឋខ្មែរ ដែលបានស្លាប់ក្នុងរបប ប៉ុល ពត ដែលជាផ្នែកនៃសកម្មភាពយុទ្ធនាការ "សុបិន្ត របស់ Darfur" របស់លោកស្រី Mia Farrow ក្នុងគោលបំណង ដើម្បីទាញការចាប់អារម្មណ៍ចំពោះ ការគាំទ្រសេដ្ឋកិច្ចរបស់ប្រទេសចិនដល់ប្រទេសស៊ូដង់ និងសង្គ្រាមនៅក្នុងតំបន់ Darfur ជុំវិញកីឡាអូឡាំពិកនៅក្នុងខែសីហា។

ក្រោយពីមានការបំបែកដោយនគរបាល ក្រុមប្រតិភូបានធ្វើសន្និសីទកាសែតនៅការិយាល័យរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដើម្បីថ្កោលទោសចំពោះការរំលោភសិទ្ធិនៃការជួបជុំ និងការបញ្ចេញមតិ។

## ជនភៀសខ្លួន និងស្វែងរកសិទ្ធិជ្រកកោន

**ជនភៀសខ្លួន ម៉ុងតាញ៉ា:** កាលពីថ្ងៃទី៣ ខែមិថុនា គ្រូគង្វាលនិកាយប្រូតេស្តង់ឈ្មោះ ឌុង (ជាអ្នកស្វែងរកសិទ្ធិជ្រកកោនជនជាតិម៉ុងតាញ៉ា ដែលបានរត់គេចពីប្រទេសវៀតណាមមកប្រទេសកម្ពុជា ក្រោយពីមានការយាយីរុកគួនដល់សកម្មភាពជំនឿសាសនារបស់គាត់) បានបាត់ខ្លួនជាមួយនឹងភរិយា កូន និងប្អូនប្រុសរបស់គាត់ ខណៈពេលស្នាក់នៅផ្ទះសំណាក់មួយនៅទីក្រុងភ្នំពេញ។ សាក្សីដែលបានឃើញផ្ទាល់ភ្នែកបានរាយការណ៍ឱ្យដឹងថា ក្រុមគ្រួសារនេះត្រូវបាននគរបាលចាប់ខ្លួន។ គេជឿជាក់ថា គ្រួសារនេះត្រូវគេចាប់បញ្ជូនដោយសម្ងាត់ទៅប្រទេសវៀតណាមវិញ ហើយគ្រូគង្វាល ឌុង អាចត្រូវគេឃុំខ្លួននៅក្នុងផ្ទះ ឬក្នុងពន្ធនាគារនៅឯប្រទេសវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរវៀតណាមមិនបានធ្វើការបញ្ជាក់ជាសាធារណៈពីរឿងនេះឡើយ។ ការបាត់ខ្លួនរបស់គ្រូគង្វាល ឌុង គឺជាផ្នែកមួយ ដែលបញ្ជាក់ឱ្យឃើញពីការចាប់ពង្រត់អ្នកស្វែងរកសិទ្ធិជ្រកកោនជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា ដែលត្រូវគេបញ្ជូនត្រលប់ទៅវៀតណាមវិញ ហើយនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះមានអ្នកខ្លះត្រូវគេចាប់ដាក់ពន្ធនាគារទៀត។

ក្នុងខែមិថុនានេះដែរ មានបុរសពីរនាក់ជាជនភៀសខ្លួនជនជាតិម៉ុងតាញ៉ាសញ្ជាតិវៀតណាម ឈ្មោះ ប៉ាន់ សាវ៉ាន និងឡឺ យ៉ាំងហាយ ត្រូវតុលាការភ្នំពេញកាត់ទោសឱ្យជាប់ពន្ធនាគារ ៤ ខែ ពីបទផ្តល់កន្លែងស្នាក់ឱ្យជនជាតិម៉ុងតាញ៉ា ក្នុងប្រទេសកម្ពុជា បន្ទាប់ពីពួកគេចូលមកស្វែងរកសិទ្ធិជ្រកកោននៅទីនេះ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ករណីនេះនៅបន្តជាគំរូរបស់អាជ្ញាធរកម្ពុជាដាក់បន្ទុកបណ្តឹងព្រហ្មទណ្ឌទៅលើបុគ្គលណា ដែលជួយក្រុមជនជាតិម៉ុងតាញ៉ា

ឱ្យមកកាន់ប្រទេសកម្ពុជា ដើម្បីសុំសិទ្ធិសេរីភាពក្នុងការស្វែងរកសិទ្ធិជ្រកកោនផ្អែកតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីជនភៀសខ្លួន ។

## ការជួញដូរមនុស្ស

**បុរសកម្ពុជា២២នាក់ ត្រូវបានសង្គ្រោះឱ្យរួចពីក្រញាំនៃការជួញដូរៈ** ការរត់គេចខ្លួនរបស់បុរសកម្ពុជា ២២នាក់ពីទាសភាពលើកប៉ាល់នេសាទជនជាតិថៃក្នុងខែមីនា បានបង្ហាញឱ្យឃើញច្បាស់អំពីស្ថានភាពជនរងគ្រោះដោយការជួញដូរពលករជាលក្ខណៈអន្តរជាតិ ។ ដោយមានស្ថានភាពក្រលំបាក ក្រុមបុរសទាំងនោះបានជ្រើសរើសជម្រើសស្វែងរកការងារធ្វើនៅក្រៅប្រទេស ប៉ុន្តែពួកគេពុំបានដឹងខ្លួនថា ពួកគេអាចត្រូវបានគេជួញដូរឱ្យធ្វើការងារពលកម្មនោះឡើយ ។

បុរសទាំងនោះត្រូវបានគេនាំចូលទៅប្រទេសថៃឡង់ដ៏ដោយលួចលាក់ ហើយបន្តនាំទៅទូកនេសាទនៅឯតំបន់ប៉ាក់ណាម ខេត្តសាមុតប្រាកាន់នៅឆ្នេរខាងកើតប្រទេសថៃឡង់ដ៏ ។ នៅលើទូកនេសាទពួកគេត្រូវបង្ខំឱ្យធ្វើការទាំងយប់ទាំងថ្ងៃគ្មានប្រាក់កំម្រៃ មិនមានការសម្រាក និងអាហារហូបចុកគ្រប់គ្រាន់ឡើយ ហើយនៅថ្ងៃខ្លះពួកគេអាចដេកបានតែរយៈពេលមួយម៉ោង ឬពីរម៉ោងតែប៉ុណ្ណោះ ។

ក្រោយមកក្រុមបុរសទាំងនោះមានឱកាសរត់គេចចេញពីទូកនេសាទ ខណៈពេលដែលទូកនេសាទចូលចតនៅលើឆ្នេរនៃសមុទ្រសារ៉ាវ៉ាក់នៃដែនទឹកប្រទេសម៉ាឡេស៊ី ។ នៅពេលពួកគេរត់គេចខ្លួនរួច ពួកគេលាក់ខ្លួននៅក្នុងព្រៃ ហើយរាល់ពេលចេញមករកអាហារខាងក្រៅ ពួកគេតែងប្រយ័ត្នខ្លាចជួបអ្នកជួញផ្សេងទៀត ដែលអាចនាំពួកគេទៅធ្វើកម្មករនៅលើទូកនេសាទទៀត ឬបញ្ជូនពួកគេទៅនគរបាលមូលដ្ឋាន ដែលអាចឃាត់ខ្លួនពួកគេពីបទឆ្លងដែនខុសច្បាប់ ។ បន្ទាប់ក្រោយមក បុរសទាំងនោះអាចទំនាក់ទំនងសមាជិកក្រុមគ្រួសាររបស់ពួកគេនៅប្រទេសកម្ពុជាតាមទូរស័ព្ទ ។ បន្ទាប់ពីបានទទួលដំណឹងពីស្ថានភាពរស់នៅរបស់ពួកគេ ក្រុមគ្រួសារពួកគេបានទាក់ទងសុំជំនួយពីលីកាដូ ។

យោងតាមព័តិមានដែលទទួលបានពីអង្គការលីកាដូ និងក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរម៉ាឡេស៊ី និងកម្មវិធីភ្នាក់ងារអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ អង្គការតង់ស្សាណា និងស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំង២២នាក់ ត្រូវបានបញ្ជូនត្រលប់មកប្រទេសកម្ពុជាវិញដោយសុវត្ថិភាព កាលពីខែមេសា ឆ្នាំ២០០៨ ។

**ច្បាប់ថ្មីស្តីពីអំពើជួញដូរមនុស្ស:** ក្នុងខែកុម្ភៈ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ថ្មីមួយស្តីពី "ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ"។ ច្បាប់នេះ បង្ហាញអំពីនិយមន័យទូលំទូលាយ និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសដាក់ពេស្យាស្ថានក្រៅច្បាប់ និងការអូសទាញក្នុងទីសាធារណៈ។ ការអនុម័តច្បាប់ថ្មីនេះ នាំឱ្យប្រទេសកម្ពុជាត្រូវគេលើកឡើងដាក់ចំណាត់ថ្នាក់លំដាប់ទី២នៅក្នុងរបាយការណ៍ជួញដូរមនុស្សនៅសហរដ្ឋអាមេរិក ដែលនេះមានន័យថា ជាការឆ្លុះបញ្ចាំងឱ្យឃើញពីការកើនឡើងលើកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការជួញដូរមនុស្ស។ តាមរយៈការអនុម័តច្បាប់ថ្មីនេះ របាយការណ៍ស្តីអំពីការជួញដូរមនុស្សដែលបានចេញផ្សាយកាលពីពេលមុនរួចមកហើយនោះ អាជ្ញាធរបានចាប់ផ្តើមចុះចាត់វិធានការចំបង១នៅតាមពេស្យាស្ថាន ដោយបានបិទផ្ទះបនចំនួន១០០កន្លែង នៅក្នុងរាជធានីភំពេញ និងនៅតាមបណ្តាខេត្ត។ អ្នករកស៊ីផ្លូវភេទ និងអង្គការសង្គមស៊ីវិលបានធ្វើការរិះគន់យ៉ាងខ្លាំងដល់យុទ្ធនាការនេះ ដោយបញ្ជាក់ថាវាជាការជំរុញឱ្យមានអ្នករកស៊ីផ្លូវភេទច្រើននៅតាមដងផ្លូវ ហើយជាទូទៅពួកគេទទួលការយល់ដឹង ពីកម្មវិធីសុខភាពបានតិចតួច ហើយងាយនឹងត្រូវគេចាប់ខ្លួន និងឃុំខ្លួនដោយបំពាន (សូមអានករណីសិក្សាខាងក្រោម)។ ការចុះចាត់វិធានការនេះត្រូវបានគេរិះគន់ថា ធ្វើឡើងដោយមានការជ្រើសរើសជាមុន និងមិនមានប្រសិទ្ធិភាពទាល់តែសោះដោយសារតែការចាត់វិធានការចាប់ខ្លួន និងផ្តន្ទាទោសនេះធ្វើឡើងបានតែលើអ្នកជួញដូរ និងម្ចាស់ពេស្យាស្ថានមួយក្តាប់តូចតែប៉ុណ្ណោះ ដោយឡែកអ្នកដែលមានខ្នងជាមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់មិនត្រូវបានចាប់ខ្លួន ឬផ្តន្ទាទោសឡើយ។




## ការចាប់ខ្លួន និងឃុំឃាំងខុសច្បាប់

**ការឃុំឃាំងជនអនាថាតាមដងផ្លូវ:** កាលពីខែមិថុនា រដ្ឋាភិបាលបានចាប់ខ្លួនដោយខុសច្បាប់ និងឃុំឃាំងប្រជាជនក្រីក្រដែលគ្មានផ្ទះសម្បែង និងធ្វើការនៅតាមដងផ្លូវ ដោយការចាប់ខ្លួនបែបនេះបានកើតឡើងជាច្រើនឆ្នាំមកហើយ។ អ្នករកស៊ីផ្លូវភេទ ជនអនាថា អ្នកសុំទាន និងអ្នកញៀនថ្នាំ គឺជាក្រុមមនុស្សដែលជាទូទៅត្រូវគេចាប់ប្រមូលតាមបណ្តាដងផ្លូវ ហើយយកទៅឃុំដើម្បីអប់រំ ឬស្តារនីតិសម្បទារនៅក្នុងមណ្ឌលដែលរៀបចំចាត់ចែងដោយមន្ទីរសង្គមកិច្ចក្រុងភ្នំពេញ។ ជាញឹកញាប់ការចាប់ខ្លួនមានប្រើអំពើហិង្សាពីសំណាក់នគរបាល សន្តិសុខខណ្ឌ ឬបុគ្គលិកមន្ទីរសង្គមកិច្ចក្រុងផងដែរ។

អ្នកត្រូវគេចាប់ខ្លួន ត្រូវបានឃុំឃាំងដោយខុសច្បាប់ នៅមណ្ឌលសង្គមកិច្ច ក្នុងភូមិព្រៃស្ពឺ សង្កាត់ចោមចៅក្រុងភ្នំពេញ និងនៅកន្លែងមួយទៀតលើកោះគ ក្នុងស្រុកស្អាង ខេត្តកណ្តាល។ ស្ថានភាពក្នុងមណ្ឌលទាំងពីរ ត្រូវបានគេនិយាយថា មានសភាពរស់នៅលំបាកខ្លាំង ដូចជាមិនមានអាហារគ្រប់គ្រាន់ កង្វះទឹកស្អាតសម្រាប់បរិភោគ និង

សេវាថែទាំសុខភាព។ ជាពិសេស មានសេចក្តីរាយការណ៍ថា នៅមណ្ឌលព្រៃស្ពឺ ក៏មានការប្រើប្រាស់អំពើហិង្សា រួមទាំងការរំលោភសេពសន្ថវៈលើស្រ្តីជាអ្នកជាប់ឃុំពីសំណាក់ឆ្មាំមណ្ឌល។

នៅថ្ងៃទី១៧ ខែមិថុនា បុគ្គលិកអង្គការលីកាដូ បានចុះទៅពិនិត្យនៅមណ្ឌលកោះគ។ ក្រោមកិច្ចខិតខំប្រឹងប្រែង បុគ្គលិកអង្គការលីកាដូ បានរកឃើញមនុស្ស ២០ នាក់ មាន បុរស ស្ត្រី និងកុមារ ត្រូវបានចាក់សោរឃុំឃាំងនៅក្នុងបន្ទប់តែមួយ។ អ្នកជាប់ឃុំទាំងនោះ មានទាំងស្ត្រីមានផ្ទៃពោះ ៩ខែ និងកូនប្រុសអាយុ ៤ឆ្នាំ អ្នកជម្ងឺឈឺធ្ងន់ធ្ងរ (មានអ្នកជម្ងឺម្នាក់បានស្លាប់កាលពីពីរថ្ងៃមុន) កុមារីម្នាក់មានជម្ងឺឆ្កួតជ្រូក ហើយមិនអាចទទួលថ្នាំសម្រាប់ព្យាបាលបានដោយសារតែជាប់ឃុំ ហើយនៅមានបុរស នារីជំទង់ៗ ជាច្រើនទៀតមានខ្លះមានជម្ងឺសរសៃប្រសាទ និងមិនមានស្មារតីគ្រប់គ្រាន់ ជាហេតុធ្វើឱ្យពួកគេមិនអាចបរិយាយពីរយៈពេលដែលត្រូវជាប់ឃុំឃាំងបាន។



នៅថ្ងៃទី២៤ ខែមិថុនា អ្នកជាប់ឃុំឃាំងនៅកោះគត្រូវគេដោះលែងមកវិញភ្លាមៗ ក្រោយពីអង្គការលីកាដូផ្ញើររូបថតបុរស ស្ត្រី និងកុមារដែលជាប់ឃុំទៅរដ្ឋាភិបាល។ ពួកគេត្រូវដឹកតាមឡាន ហើយភាគច្រើនដឹកយកត្រឡប់មកភ្នំពេញ និងទំលាក់ចោលនៅតាមដងផ្លូវ។ ទោះជាយ៉ាងណាក្តី មណ្ឌលកោះគ មិនត្រូវបានបិទជាស្ថាពរទេ ចំណែកឯមណ្ឌលព្រៃស្ពឺ ក៏នៅតែបើកជាបន្ត ទោះបីជាអង្គការលីកាដូ ធ្លាប់ជំទាស់ក្នុងការប្រើប្រាស់មណ្ឌលនេះជាច្រើនសារក៏ដោយ។ ផ្អែកតាមបទពិសោធន៍កន្លងមក ការចាប់ និងឃុំខ្លួនខុសច្បាប់នៅមណ្ឌលនោះ នឹងត្រូវធ្វើឡើងម្តងទៀត។

ក្រសួងសង្គមកិច្ចការងារបានចេញសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី៤ ខែវិច្ឆិកា និងផ្សាយលើទំព័រសារព័ត៌មានរស្មីកម្ពុជា ថ្ងៃទី៦ ខែវិច្ឆិកា បានប្រកាសសេចក្តីថ្លែងការណ៍របស់ខ្លួនសារជាថ្មីឡើងវិញម្តងទៀតថា ជនក្រីក្រគ្មានផ្ទះសម្បែងបានស្នាក់នៅក្នុងមណ្ឌល "ដោយស្ម័គ្រចិត្ត" ដើម្បីទទួលបាននូវវគ្គបណ្តុះបណ្តាល និងសេវាផ្សេងៗ។ សេចក្តីថ្លែងការណ៍នេះ គឺបានធានាថា ក្រុមសិទ្ធិមនុស្ស និងក្រុមអង្គការសង្គមស៊ីវិល គឺមិនមានហេតុផលណាមួយគួរត្រូវព្រួយបារម្ភពីទីកន្លែងនោះទេ។



កាលពីថ្ងៃទី៦ ខែវិច្ឆិកា សេចក្តីថ្លែងការនោះក៏បានចុះផ្សាយ ហើយបុគ្គលិកអង្គការលីកាដូ អាចចូលទៅក្នុងមជ្ឈមណ្ឌលព្រៃស្ពឺ នៅក្នុងខណ្ឌចោមចៅ រាជធានីភ្នំពេញជាលើកទីមួយបន្ទាប់ពីបានបដិសេធមិនឱ្យចូលអស់រយៈពេលជាច្រើនឆ្នាំ។ នៅខាងក្នុងពួកគេបានរកឃើញថា បុគ្គលិកមជ្ឈមណ្ឌលបានរលោភបំពានលើអ្នកជាប់ឃុំឃាំងក្នុងនោះយ៉ាងឃោឃៅកាលពីអតីតកាល ដូច្នេះហើយលីកាដូបានស្នើសុំឱ្យរដ្ឋា

ភិបាលអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត ទាំងស្រុង ដើម្បីបន្តធ្វើការនៅទីនោះ។

កំឡុងពេលចុះទៅ បុគ្គលិកលីកាដូបានចងក្រងឯកសារ ពាក្យដែលបានសរសេរដោយដៃនៅលើជញ្ជាំង (ខាងស្តាំ) ថា "ជាប់គុគទាំងវេទនា រាងហើយឈប់ស្គាល់គុកជាលើកទីពីរទៀត" មានហត្ថលេខានៅខាងក្រោមពាក្យនោះ ប៉ុន្តែឈ្មោះមិនអាចមើលឃើញ។

**នគរបាលស្រុក ត្រូវឃុំខ្លួនដោយនគរបាលក្រសួងមហាផ្ទៃ:** នគរបាលស្រុកម្នាក់ នៅឯក្រុងកែប ត្រូវចាប់ និង ឃុំឃាំងដោយខុសច្បាប់ អស់រយៈពេលជាង ៦ សប្តាហ៍ ចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ដល់ថ្ងៃទី២ ខែមេសា ដោយអនុវត្តតាមបញ្ជារបស់ លោក ហុក ឡង់ឌី។ នគរបាលឈ្មោះ ព្រាប ពៅ ត្រូវគេធ្វើទារុណកម្មកំឡុងពេលជាប់ឃុំ។ លោកត្រូវបានឃុំខ្លួនដោយនគរបាលសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ បើទោះបីជាមិនមានបណ្តឹងណាមួយប្តឹងមកគាត់ឡើយ។ ប៉ុន្តែនេះដោយសារគ្រួសាររបស់លោកមានជាប់ពាក់ព័ន្ធជម្លោះដីធ្លីជាមួយម្ចាស់ក្សត្រិយ៍ ម៉ារី។ បន្ទាប់ពីការឃុំខ្លួនច្រើនជាងមួយខែមក លោក ព្រាប ពៅ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដោយមានបញ្ហាសុខភាពនៃប្រព័ន្ធដកដង្ហើម និងពិបាកក្នុងការដើរ ដោយសារការឃុំខ្លួនគាត់មានរយៈពេលយូរ ហើយ ពីរ-បីថ្ងៃក្រោយមកគាត់ក៏ត្រូវបានគេដោះលែងវិញ។ មន្ត្រីនគរបាលបាននិយាយថា គាត់នឹងនៅតែប្រឈមការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដោយការបំផ្លាញទ្រព្យសម្បត្តិលើដីជម្លោះ។

## ការគ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មាន

**អ្នកសារព័ត៌មានត្រូវគេគម្រាមសំលាប់:** នៅដើមខែឧសភា អ្នកយកព័ត៌មានឱ្យវិទ្យុអាស៊ីសេរី លោក ឡឹម ពិសិដ្ឋ បានរត់គេចខ្លួនទៅប្រទេសថៃឡង់ដ៏ជាថ្មីម្តងទៀត ក្រោយពីត្រូវគេគម្រាមសម្លាប់ដល់អាយុជីវិតរបស់លោក។ លោក ឡឹម ពិសិដ្ឋ ធ្លាប់ធ្វើការស្រាវជ្រាវលើករណីជួញដូរថ្នាំញៀន និងករណីឃាតកម្ម ដែលភាគច្រើនមានការជាប់ពាក់ព័ន្ធជាមួយមន្ត្រីជាន់ខ្ពស់។

នៅថ្ងៃទី១០ ខែមេសា កូនស្រីរបស់លោក បានរកឃើញគ្រាប់កាំភ្លើងអាកា-៤៧ ចំនួន ៦គ្រាប់ នៅខាងមុខផ្ទះដែលលោកជួលក្នុងខេត្តបាត់ដំបង ហើយកាលពីថ្ងៃទី១៣ ខែមេសា នៅទីក្រុងភ្នំពេញ មានមនុស្ស ៨នាក់បានធ្វើដំណើរតាមពីក្រោយម៉ូតូលោក។ កាលពីឆ្នាំ២០០៧ លោក ឡឹម ពិសិដ្ឋ ធ្លាប់រត់គេចទៅប្រទេសថៃឡង់ដ៏ម្តងរួចមក ហើយក្រោយពីលោកទទួលបានទូរស័ព្ទគម្រាមលោកឱ្យឈប់សរសេរអត្ថបទអំពីការកាប់បំផ្លាញឈើខុសច្បាប់។



**ចាងហ្វាងសារព័ត៌មានជំទាស់ត្រូវចាប់ខ្លួន:** កាលពីថ្ងៃទី០៨ ខែមិថុនា លោក ដាំ សិទ្ធិ ចាងហ្វាងសារព័ត៌មានមនសិការខ្មែរ និងជាបេក្ខជនតំណាងរាស្ត្ររបស់

គណបក្ស សម រង្ស៊ី ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ពន្ធនាគារព្រៃស ក្រោមការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងបរិហាកេរ្តិ៍។ លោក ដាំ សិទ្ធិ ត្រូវចោទប្រកាន់ បន្ទាប់ពីលោក ហោ ណាំហុង បានដាក់ពាក្យបណ្តឹង ដោយសារលោកបានដកស្រង់សំដីប្រធានគណបក្សជំទាស់មក ចុះផ្សាយអំពីលោកទេសរដ្ឋមន្ត្រី។ ប៉ុន្តែ ពីរសប្តាហ៍ក្រោយមក លោក ដាំ សិទ្ធិ ត្រូវបានធានាឱ្យនៅក្រៅឃុំ ហើយក្រោយមកលោក ហោ ណាំហុង បានបញ្ជាក់ថាលោកនឹងដកពាក្យបណ្តឹងដែល ចោទប្រកាន់លោកចាងហ្វាងសារព័ត៌មាន។

**ការសម្លាប់អ្នកសារព័ត៌មានបានគ្រោងទុកពេលបោះឆ្នោត:** មុន២សប្តាហ៍ថ្ងៃបោះឆ្នោតសភាជាតិ អ្នកសារព័ត៌មាន លោក ឃឹម សំបូរ និងកូនប្រុសអាយុ២១ឆ្នាំ ត្រូវបានគេបាញ់សម្លាប់ខណៈពេលកំពុងធ្វើដំណើរដោយម៉ូតូ កាលពីថ្ងៃទី១១ ខែកក្កដា ក្នុងរាជធានីភ្នំពេញ។ លោក សំបូរ គឺជាអ្នកសារព័ត៌មានឱ្យសារព័ត៌មាន មនសិការខ្មែរ ដែលមាននិន្នាការទៅលើគណបក្សជំទាស់ ដែលលោកចាងហ្វាងសារព័ត៌មានមនសិការខ្មែរ លោក ដាំ សិទ្ធិ ក៏ត្រូវបានចាប់ខ្លួនមួយខែមុន ក្រោមការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ (មើលខាងលើ)។ លោក ឃឹម សំបូរ ត្រូវបានគេស្គាល់ ដោយលោកបានចុះផ្សាយអត្ថបទស៊ើបអង្កេតរិះគន់លើរដ្ឋាភិបាល និងមន្ត្រីមានអំណាចមួយចំនួន។ ករណីសម្លាប់ លោក សំបូរ គឺជាការសម្លាប់មនុស្សទី១០ លើអ្នកកាសែតកំឡុងពេល១៥ឆ្នាំ កន្លងមកនេះ ហើយនរគបាលនៅតែពុំទាន់រកឃើញមូលហេតុនៃការសម្លាប់នេះ ឬកំណត់អត្តសញ្ញាណជនសង្ស័យនៅឡើយ។

## ការរឹតបន្តឹងលើសង្គមស៊ីវិល

**ការទាមទារឱ្យមានច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល :** ចាប់តាំងពីឆ្នាំ១៩៩៦ រដ្ឋាភិបាលកម្ពុជាបានទាមទារឱ្យមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ជាទូទៅស្គាល់ថាច្បាប់អង្គការមិនមែនរដ្ឋាភិបាល) ដែលមានសេចក្តីព្រៀងយ៉ាងច្រើនបានរៀបចំរួចហើយកាលពី ១២ឆ្នាំ កន្លងមក។ កាលពីខែកញ្ញា ឆ្នាំ២០០៨ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងជាសាធារណៈថា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវតែអនុម័តជាបន្ទាន់ក្នុងចំណោមច្បាប់សំខាន់ៗ ៣ផ្សេងទៀតហើយស្នើសុំឱ្យក្រសួងមហាផ្ទៃធ្វើសេចក្តីព្រៀងច្បាប់នេះឱ្យបានកាន់តែឆាប់។

អង្គការក្នុងស្រុក និងអង្គការអន្តរជាតិបានបង្ហាញពីការព្រួយបារម្ភលើគោលបំណង និងដំណើរការធ្វើសេចក្តីព្រៀងច្បាប់នេះ ដោយអង្គការទាំងនោះមានការព្រួយបារម្ភថា ច្បាប់នេះ និងប្រើដើម្បីគ្រប់គ្រង និងកំណត់ឯករាជ្យភាពអង្គការសង្គមស៊ីវិលទេ ដែលមិនគ្រាន់តែអង្គការមិនមែនរដ្ឋាភិបាលប៉ុណ្ណោះទេ គឺរួមទាំងអង្គការមានមូលដ្ឋាននៅសហគមន៍ ក្រុមសកម្មជនសហគមន៍ និងក្រុមដទៃទៀងដូចជា សិស្ស/និសិត្ស សមាគមព័ត៌មាន។ ជាពិសេសលើក្រុមមនុស្សសំខាន់ៗ ដែលជាអ្នកធ្វើការតស៊ូមតិដើម្បីនីតិរដ្ឋ និងបញ្ហាសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ឬក្រុមដែលផ្តល់ជំនួយដល់ជនរងគ្រោះ ដែលរំលោភបំពានដោយមន្ត្រីជួររដ្ឋាភិបាល។

## ការបោះឆ្នោតជាតិ

**ការបោះឆ្នោតមិនមានបទដ្ឋានអន្តរជាតិ:** កាលពីថ្ងៃទី២៧ ខែកក្កដា ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតសភាជាតិលើកទី៤ របស់ខ្លួន ចាប់តាំងពីមានការបោះឆ្នោតលើកទី១ក្នុងឆ្នាំ១៩៩៣ ដែលបានរៀបចំឡើងដោយអាជ្ញាធរអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (អ៊ុនតាក់) បន្ទាប់ពីថ្ងៃបោះឆ្នោត មានរបាយការណ៍អំពីអំពើហិង្សាបន្តិចបន្តួចប៉ុណ្ណោះបើប្រៀបធៀបជាមួយពេលបោះឆ្នោតកន្លងមក អ្នកសង្កេតការណ៍អន្តរជាតិបានចាត់ទុកការបោះឆ្នោតនេះពុំបានឆ្លើយតបទៅ និងបទដ្ឋានអន្តរជាតិ។



មុនកំឡុងពេលធ្វើយុទ្ធនាការបោះឆ្នោតមានព័ត៌មានលេចឮជាច្រើនថា មានការផ្តល់ជាអំណោយ និងថវិកាដោយបេក្ខជនឈរឈ្មោះបោះឆ្នោត និងការគម្រាមកំហែងទៅលើសមាជិកគណបក្សជំទាស់ ការប្រើធនធានរបស់រដ្ឋដោយគណបក្សកាន់អំណាច ដើម្បីធ្វើយុទ្ធនាការ ចំណែកប្រព័ន្ធផ្សាយព័ត៌មានត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច ដែលផ្ទុយពីគោលការណ៍នៃការទទួលបានសិទ្ធិស្មើគ្នា និងដោយសេរី។ អ្វីដែលគួរឱ្យចម្លែកនោះ គឺថាមានចំនួនអ្នកចុះចូល ដែលមិនធ្លាប់មានកាលពីមុនមកនៃគណបក្សជំទាស់លទៅចុះចូលជាមួយគណបក្សកាន់អំណាច។ ការចុះចូលនេះ គឺបានផ្តល់ជាថវិកា និងការសន្យាផ្តល់តំណែង។ លីកាដូក៏បានធ្វើការចងក្រងនូវករណីមួយចំនួននៃការចុះចូល ដោយសារមូលហេតុនៃការគំរាមកំហែង និងបំភិតបំភ័យ (រួមមានការគម្រាមសម្លាប់) និងយុទ្ធវិធីបញ្ចុះបញ្ចូលផ្សេងៗទៀត។

នៅថ្ងៃបោះឆ្នោត មានអ្នកបោះឆ្នោតជាច្រើនអ្នកគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ដូច្នេះពួកគេពុំអាចបោះឆ្នោតបានឡើយ។ គណៈកម្មាធិជាតិរៀបចំការបោះឆ្នោតក្រោយមកបានទទួលស្គាល់ថា មានឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីត្រូវបានកាត់ចោលពីក្នុងបញ្ជីដោយកំហុសឆ្គង ទោះបីជាយ៉ាងក៏ដោយ គណបក្សជំទាស់បានអះអាងថា មានចំនួនជិត១លាននាក់ដែលបានកាត់ចោល។ បន្ថែមពីលើនេះ គណបក្សជំទាស់បានអះអាង ទៀតថា មានចំនួនអ្នកគ្មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវជាច្រើនគួរឱ្យកត់សម្គាល់ត្រូវបានអនុញ្ញាតឱ្យចូលបោះឆ្នោត។

លទ្ធផលចុងក្រោយនៃការបោះឆ្នោតបានបង្ហាញថាគណបក្សកាន់អំណាចនៅតែកាន់កាប់រដ្ឋសភា ដែលបានឈ្នះ ៥៨%នៃលទ្ធផលការបោះឆ្នោត ដោយទទួលបាន ៩០អសុនៈ លើ ១២៣អសុនៈ។ ចំណុចសំខាន់ដែលគណបក្សកាន់អំណាចឈ្នះ គឺដោយសារមានការផ្លាស់ប្តូររដ្ឋធម្មនុញ្ញកាលពីខែមីនា ឆ្នាំ២០០៦ ដែលបានអនុញ្ញាតឱ្យរដ្ឋាភិបាលអាចបង្កើតរដ្ឋាភិបាលដោយខ្លួនឯងដោយមានចំនួន៥១% ដែលមានន័យថា ឥឡូវនេះគណបក្សកាន់

អំណាចអាចកាន់កាប់រដ្ឋសភាបានទាំងស្រុង ហើយអាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញកម្ពុជា ដោយមិនចាំបាច់មានការចូលរួមពីគណបក្សជំទាស់គាំទ្រ។ គណបក្សកាន់អំណាចថ្មីៗ នេះបានប្រកាសផងដែរថា គ្មានសមាជិកគណបក្សជំទាស់ត្រូវទទួលបានកៅអីក្នុងរដ្ឋសភាឡើយ។

## កង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការ

**ការចាប់ខ្លួនសកម្មជនគណបក្ស សម រង្ស៊ី លោក ទូត សារ៉ន:** មេឃុំ ខេត្តកំពង់ធំ នៃគណបក្ស សម រង្ស៊ី ត្រូវចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែមីនា ក្រោមបទចោទប្រកាន់ថាបានឃុំឃាំងដោយខុសច្បាប់លើសមាជិកគណបក្ស សម រង្ស៊ី ដែលចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។ ការចាប់ខ្លួននេះធ្វើឡើងមួយថ្ងៃបន្ទាប់ពីលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាជាសាធារណៈ ដោយលោកបានសន្មត់ថាទង្វើនេះជាការឃុំឃាំងដោយខុសច្បាប់ ត្រូវតែចាត់វិធានការលើករណីនេះ។ ទោះជាយ៉ាងណាក្តី ដោយយោងតាមការស្រាវជ្រាវរបស់បុគ្គលិកសិទ្ធិមនុស្ស បង្ហាញថា ស្ត្រីរូបនោះពិតជាចុះចូលគណបក្សប្រជាជនកម្ពុជាមែន ប៉ុន្តែក្រោយមកគាត់បានផ្លាស់ប្តូរគំនិតវិញ ហើយបានស្នើឱ្យលោក ទូត សារ៉ន ជួយការពារគាត់បន្ទាប់ពីគាត់សំរេចចិត្តត្រឡប់មកគណបក្ស សម រង្ស៊ី វិញ។

ការិយាល័យសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ក៏បានធ្វើការស្រាវជ្រាវលើករណីនេះដែរ ហើយបានប្រកាសជាសាធារណៈថា មិនមានភស្តុតាងណាមួយដែលដាក់បន្ទុកលើលោក ទូត សារ៉ន ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយខណៈពេលសរសេរបាយការណ៍នេះ លោកមេឃុំនៃគណបក្ស សម រង្ស៊ី រូបនេះ នៅជាប់ឃុំក្នុងពន្ធនាគារនៅឡើយដើម្បីរង់ចាំសវនាការពីតុលាការ។



**ការរួចផុតពីការដាក់ទោស (និទ្ទណ្ឌភាព) លើនគរបាល និង កងកម្លាំងយោធាកម្ពុជា:** នៅក្នុងឆ្នាំនេះគេបានដឹងថា ប្រទេសកម្ពុជាមានករណីបាញ់ប្រហារយ៉ាងច្រើន ដែលបានប្រព្រឹត្តដោយនគរបាល ឬកងយោធពលខេមរភូមិន្ទ។ ឧប្បត្តិហេតុបាញ់ប្រហារបែបនេះច្រើនកើតមានឡើងនៅពេលបំពេញការងារក្រៅម៉ោង ឬក្រៅតួនាទី ដូចជាបំពេញតួនាទីជាអង្គរក្ស ហើយមានយកកាំភ្លើងទៅជាមួយ។ រាល់ការបាញ់ប្រហារជនប្រព្រឹត្តទាំងនេះ ត្រូវបានរួចផុតពីការកាត់ទោសទាំងអស់ ពីព្រោះពួកគេត្រូវបានការពារដោយអ្នកមានអំណាចខ្ពស់ ដែលបានបង់ប្រាក់សំណងតាមរយៈតុលាការឱ្យទៅជនរងគ្រោះដើម្បីមិនឱ្យដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ហើយឱ្យអ្នកទាំងនោះអាចលាក់ខ្លួនបានទៀត។

**បុរសជាប់ពន្ធនាគារគ្មានទោសត្រូវបានដោះលែងឱ្យនៅក្រៅឃុំ:** នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ប៊ន សំណាង និង សុខ សំអឿន ត្រូវបាន តុលាការកំពូលបានប្រកាសដោះលែង ឱ្យនៅក្រៅឃុំ បន្ទាប់ពីជាប់ពន្ធនាគារ

ដោយខុសច្បាប់អស់រយៈពេលជិត៥ឆ្នាំ ដោយបញ្ជាឱ្យសាលាឧទ្ធរណ៍រៀបចំស៊ើបអង្កេតសារជាថ្មីទៅលើករណី អ្នកទាំងពីរ។ បុរសទាំងពីរនាក់ត្រូវបានឃុំខ្លួនទៅពន្ធនាគារ ប៉េហ្ស៊ី អស់រយៈពេលជិត៥ឆ្នាំ បន្ទាប់ពីការកាត់ទោសពុំមានបទដ្ឋានច្បាប់ត្រឹមត្រូវលើករណីសំលាប់លោក ជា វិជ្ជា មេដឹកនាំសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។




បន្ទាប់ពីការវិនិច្ឆ័យទោសដោយអយុត្តិធម៌មក ឃាតករសិប្បនិម្មិត ប៊ិន សំណាង និងសុខ សំអឿន ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២០ ឆ្នាំ ពីបទមនុស្សឃាត។ មានការពន្យារពេល២០ខែមុនពេលសាលាឧទ្ធរណ៍សវនាការករណីនេះ ហើយបានបន្តការចោទប្រកាន់លើបុរសទាំងពីរដដែល បើទោះបីជាប្រធានព្រះរាជអាជ្ញាទទួលស្គាល់ថា គ្មានភស្តុតាងជាក់លាក់ក៏ដោយ។ សវនាការ សលាឧទ្ធរណ៍ទទួលរងការរិះគន់សហគមន៍អន្តរជាតិថា ជារឿងពាក់ព័ន្ធនឹងនយោបាយ ដែលមិនបានបើកការស៊ើបអង្កេតរកភស្តុតាងជាថ្មី។ សាលាឧទ្ធរណ៍ ក៏បានបដិសេធចោលមិនព្រមទទួលយកការសន្និដ្ឋានរបស់ព្រះរាជអាជ្ញាខ្លួន ដែលបានទទួលស្គាល់ថា ការស៊ើបអង្កេតរបស់នគរបាលមិនបានពេញលេញ ហើយគ្មានភស្តុតាងដែលយកជាការបាន ថាមានជាប់ពាក់ព័ន្ធទៅនឹងបុរសទាំងពីរលើករណីសម្លាប់ លោក ជា វិជ្ជា នោះទេ ហើយគាត់បានផ្តល់អនុសាសន៍ត្រូវបើកការស៊ើបអង្កេតបន្ថែមទៀត។

ក្រុមសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ មហាជន និងសម្តេចមហាវីរៈក្សត្រ នរោត្តម សីហនុបានប្រកាសឱ្យដឹងម្តងហើយម្តងទៀតថា បុរសទាំងពីរមិនមែនជាឃាតករសម្លាប់ លោក ជា វិជ្ជា នោះទេ។ ក្រុមគ្រួសាររបស់លោក ជា វិជ្ជា បានប្រកាសជាសាធារណៈមិនទទួលយកសវនាការ លើការកាត់ទោសលើបុរសទាំងពីរ និងបដិសេធមិនទទួលយកសំណង៥,០០០ពាន់ដុល្លារអាមេរិក ដែលតុលាការបញ្ជាឱ្យបុរសទាំងពីរបង់ជាសំណង។

សវនាការឡើងវិញលើករណី ប៊ិន សំណាង និងសុខ សំអឿន ដោយសាលាឧទ្ធរណ៍ គឺជាសញ្ញាបង្ហាញថា តុលាការកម្ពុជាបានប្តេជ្ញាអនុវត្តដំណើរការផ្លូវច្បាប់ឱ្យមានបទដ្ឋានអន្តរជាតិត្រឹមត្រូវ និងឯករាជ្យពីរដ្ឋាភិបាល។ គេមានសង្ឃឹមថាអាជ្ញាធរ និងប្រើប្រាស់ឱកាសនេះ ដើម្បីបើកការស៊ើបអង្កេតឡើងវិញឱ្យបានហ្មត់ចត់ និងប្រកបដោយប្រសិទ្ធិភាព ដើម្បីប្រមូលនូវភស្តុតាង និងបង្ហាញភស្តុតាងនោះដើម្បីចាប់ខ្លួនអ្នកដែលបានសម្លាប់លោក ជា វិជ្ជា មកទទួលទោស។

□□□

# សេចក្ដីផ្ដើម

### ប្រវត្តិ និងការពណ៌នាពីអង្គការ

### ១៩៩២-១៩៩៩ : កំណើរកំណើត និងការពង្រីកខ្លួន

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ត្រូវបានបង្កើតឡើងដោយលោកស្រីវេជ្ជ. ពុង ឈីវកេក និងជនជាតិកម្ពុជា ដែលរស់នៅបរទេសមួយចំនួនទៀត បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១។ បានទទួលស្គាល់ជាផ្លូវការថា ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងខែកក្កដា ឆ្នាំ១៩៩២ អង្គការ លីកាដូ បានសហការយ៉ាងជិតស្និទ្ធ ជាមួយអាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ដើម្បីផ្ដល់ការអប់រំដល់អ្នកបោះឆ្នោត និងឃ្លាំមើលការរំលោភបំពាន ដែលទាក់ទងនឹងការបោះឆ្នោតឆ្នាំ១៩៩៣។ នៅក្នុងដំណើរការនេះ បុគ្គលិកលីកាដូបានរកឃើញនូវអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនានា ដែលកើតឡើងនៅទូទាំងប្រទេស។

បញ្ហានេះ បាននាំឱ្យមាននូវដំណាក់កាលពង្រីករវាងឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៩ ក្នុងកំឡុងពេលដែល លីកាដូ បង្កើតឡើងនូវសេវាកម្មជាច្រើនថែមទៀត ប៉ុន្តែកម្មវិធីភាគច្រើន គឺផ្ដោតទៅលើការអប់រំបណ្ដុះបណ្ដាល និងលើក កម្ពស់ការយល់ដឹង ស្រាវជ្រាវឯកសារ ឃ្លាំមើល និងស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្សនៅកម្ពុជាតែប៉ុណ្ណោះ។ ក្នុងកំឡុងពេលនោះ លីកាដូ ក៏បានបង្កើនសមត្ថភាពរបស់ខ្លួនដើម្បីឆ្លើយតបជាយុទ្ធសាស្ត្រចំពោះករណីជាក់លាក់ មួយចំនួន និងតំរូវការឆ្លើយតបជាប្រចាំ និងដោយផ្ទាល់ទៅដល់ក្រុមគោលដៅ។ គម្រោងជំនាញមួយចំនួនបានវិវឌ្ឍ និងនាំឱ្យមានការបង្កើតឡើងនូវការិយាល័យពេទ្យ ដែលបម្រើគ្រប់ការិយាល័យកម្មវិធីទាំងអស់ក្នុងអង្គការលីកាដូ ក៏ដូចជាការិយាល័យសិទ្ធិស្ត្រី ការិយាល័យសិទ្ធិកុមារ និងក្រុមស្រាវជ្រាវពន្ធនាគារនៅក្នុងការិយាល័យស៊ើបអង្កេត ការិយាល័យតស៊ូមតិ និងសេវាសង្គមនៅក្នុងគម្រោងប្រឆាំងអំពើទារុណកម្ម។

### ២០០០-២០០៥ : ការបង្រួបបង្រួម

ចូលមកដល់សហសវត្សរ៍ថ្មី លីកាដូបានចូលមកដល់ដំណាក់កាលបង្រួបបង្រួម ដែលផ្ដោតទៅលើការពង្រឹង សមត្ថភាព និងប្រសិទ្ធភាពទូទៅរបស់អង្គការ បុគ្គលិក និងគម្រោងនានា។ កិច្ចការទាំងនេះរួមមាន ការបង្កើត ឡើងនូវទស្សនៈវិស័យ បេសកកម្ម និងគោលការណ៍ដែលជាមាគ៌ាសម្រាប់អង្គការក្នុងការកសាងផែនការយុទ្ធសាស្ត្រ និងធ្វើសេចក្ដីសម្រេចចិត្ត ក្នុងការអភិវឌ្ឍន៍បុគ្គលិក ឧបករណ៍ និងរចនាសម្ព័ន្ធគ្រប់គ្រងព័ត៌មានដើម្បីឱ្យការអនុវត្តន៍ និងការវាយតម្លៃគម្រោងកាន់តែមានប្រសិទ្ធភាពថែមទៀត ហើយនិងការរៀបចំគ្រប់គ្រងលើការគ្រប់គ្រងករណី ការបែងចែកព័ត៌មាន និងសេវាបញ្ជូនដោយបង្កើតឱ្យមានឧបករណ៍នានាដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និង

គេហទំព័រៈ www.licadho-cambodia.org ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីទាក់ទាញមតិគាំទ្រ និងធ្វើសមាហរណកម្ម កម្មវិធីទាំងអស់។ ការហ្វឹកហ្វឺនជំនាញសេវាសង្គម ក៏ត្រូវបានរៀបចំឡើងដើម្បីឱ្យបុគ្គលិកអាចអនុវត្តការងារឱ្យកាន់តែល្អប្រសើរ ជាជាងការប្រើប្រាស់តែច្បាប់ជាប្រពៃណីលើការងារសិទ្ធិមនុស្ស និងឆ្លើយតបឱ្យប្រសើរជាងមុនទៅនឹងតម្រូវការទាំងអស់របស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេដើម្បីគាំទ្រដល់ការស្តារឡើងវិញនូវអារម្មណ៍ និងសង្គមរបស់ពួកគេ។

ក្នុងកំឡុងពេលនោះ អង្គការលីកាដូក៏បានចាប់ផ្តើមយកចិត្តទុកដាក់ទៅលើផែនការរយៈពេលវែងដែលនាំទៅរកការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ ដែលអនុវត្តកម្មវិធី និងសកម្មភាពសម្រាប់ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨។ ក្នុងចំណោមគោលបំណងនានា ផែនការយុទ្ធសាស្ត្រនេះបានតំរូវឱ្យលីកាដូប្រកាន់ខ្ជាប់នូវបទពិសោធន៍ និងព័ត៌មាន ដែលទទួលបាននៅក្នុងការងារមូលដ្ឋានរបស់ខ្លួន និងសកម្មភាពជំនាញដើម្បីបង្កើតតំបន់អាទិភាព និងយុទ្ធសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត និងដើម្បីធ្វើសមាហរណកម្មការងារទាំងនេះជាមួយនឹងដៃគូថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដូចជាអង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ី សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស វេទិកាអាស៊ី និងអង្គការលើកលែងទោសអន្តរជាតិ ព្រមទាំងសម្ព័ន្ធភាពជាតិជាច្រើន ដូចជាក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) អនុសញ្ញាសិទ្ធិកុមារនៃអង្គការមិនមែនរដ្ឋាភិបាល (NGO CRC) និងគណកម្មាធិការស្ត្រីកម្ពុជា (CAMBOW) ហើយក៏បានរួមសហការជាមួយសម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា (AFEC) ផងដែរ។

## ២០០៦-២០០៨ វិជ្ជាជីវៈ និងកំណែទម្រង់រចនាសម្ព័ន្ធ

ក្រោយពីបង្រួបបង្រួមបទពិសោធន៍ការងារសិទ្ធិមនុស្សអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមក អង្គការលីកាដូបច្ចុប្បន្នកំពុងស្ថិតក្នុងសករាជនៃការស្វែងរកវិជ្ជាជីវៈនៅគ្រប់លំដាប់ថ្នាក់ដើម្បីឱ្យមានការរីកចម្រើនឆ្ពោះទៅរកការបង្កើតវិធីសាស្ត្រជាប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យ ការគ្រប់គ្រង និងការវិភាគតាមរយៈការបង្កើតការិយាល័យទាក់ទាញមតិគាំទ្រ និងធនធានឯកសារ (ADRO)។

ការទាក់ទាញមតិគាំទ្រ និងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធអំពីបញ្ហាសំខាន់ៗមួយចំនួន ដូចជា នីតិរដ្ឋ សេរីភាពក្នុងការបញ្ចេញមតិ និងជួបប្រជុំ និងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានដោះស្រាយតាមរយៈសកម្មភាពទាក់ទាញមតិគាំទ្ររួមគ្នា ដែលនាំឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងគោលនយោបាយជាតិ និងស្ថាប័ននានា។ អង្គការលីកាដូមានផែនការកសាងនូវភាពជោគជ័យនេះ និងប្តេជ្ញាបន្តខិតខំតទៅទៀត ព្រមទាំងបន្តវិវឌ្ឍដើម្បីឆ្លើយតបក្នុងខណៈដែលស្ថានភាពនៅកម្ពុជាកំពុងរីកចម្រើន។

នៅដើមឆ្នាំ២០០៨ លីកាដូបានអនុវត្តជំហានដំបូងនៃផែនការកំណែទំរង់រចនាសម្ព័ន្ធរបស់ខ្លួន ដែលមានគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងនូវគម្រោង និងថ្នាក់គ្រប់គ្រងកំរិតកណ្តាល និងកំរិតខ្ពស់។ គ្រប់ការិយាល័យត្រូវបានធ្វើកំណែទំរង់រចនាសម្ព័ន្ធជាបួនផ្នែក គឺផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្ស ផ្នែកទំនាក់ទំនង និងទាក់ទាញមតិគាំទ្រ ផ្នែកធនធានមនុស្ស និងរដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ ផ្នែកនិមួយៗមាននាយករងម្នាក់ ដែលត្រូវបានជ្រើសរើសតំលើងឋានៈពីខាងក្នុងអង្គការ។ ក្រោមផែនការកំណែទម្រង់រចនាសម្ព័ន្ធនេះ រាល់គម្រោងទាំងអស់ប្រតិបត្តិនៅក្រោមការគ្រប់គ្រងរបស់ផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្ស និងផ្នែកទំនាក់ទំនង និងទាក់ទាញមតិគាំទ្រ។

ផ្នែកធនធានមនុស្ស និងរដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ រក្សាទុកនៅដដែលដោយគ្មានការផ្លាស់ប្តូរពីការិយាល័យចាស់ឡើយ ចំណែកផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្ស និងផ្នែកទំនាក់ទំនង និងទាក់ទាញគាំទ្រ មានការផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងការគ្រប់គ្រងបុគ្គលិក។ ផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សបានដាក់បញ្ចូលអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងអ្នកស្រាវជ្រាវពន្ធនាគារពីការិយាល័យសិទ្ធិកុមារ ការិយាល័យសិទ្ធិស្ត្រី កម្មវិធីពន្ធនាគារ និងការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ការិយាល័យមេធាវី និងការិយាល័យពេទ្យ។ ចំណែកឯ ផ្នែកទំនាក់ទំនង និងទាក់ទាញមតិគាំទ្រ ដាក់បញ្ចូលអ្នកទាក់ទាញមតិគាំទ្រទាំងអស់ពីការិយាល័យសិទ្ធិកុមារ ការិយាល័យសិទ្ធិស្ត្រី និងបុគ្គលិកពីការិយាល័យទាក់ទាញមតិគាំទ្រ និងធនធានឯកសារ ព្រមទាំងការិយាល័យអប់រំសិទ្ធិមនុស្ស។

| ផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្ស | ផ្នែកទំនាក់ទំនង និងទាក់ទាញមតិគាំទ្រ |
|---|---|
| ការិយាល័យឃ្លាំមើលរំលោភសិទ្ធិមនុស្ស: អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អ្នកប្រឹក្សាផ្នែកច្បាប់ និងមេធាវី | ការិយាល័យសិទ្ធិកុមារៈ គ្រូបណ្តុះបណ្តាល និងអ្នកទាក់ទាញមតិគាំទ្រ និងមន្ត្រីយុទ្ធនាការ |
| ការិយាល័យសិទ្ធិកុមារៈ អ្នកឃ្លាំមើលការរំលោភសិទ្ធិកុមារ និងអ្នកបំរើសេវាសង្គមកិច្ច | ការិយាល័យអប់រំសិទ្ធិមនុស្ស: គ្រូបណ្តុះបណ្តាល និងអ្នកទាក់ទាញមតិគាំទ្រ |
| ការិយាល័យសិទ្ធិស្ត្រី: អ្នកឃ្លាំមើលរំលោភសិទ្ធិស្ត្រី | ការិយាល័យសិទ្ធិស្ត្រី: អ្នកទាក់ទាញមតិគាំទ្រ |
| កម្មវិធីពន្ធនាគារ: អ្នកស្រាវជ្រាវពន្ធនាគារ | ការិយាល័យទាក់ទាញមតិគាំទ្រ និងធនធានឯកសារ: មន្ត្រីឯកសារ-ទិន្នន័យ និងអ្នកបញ្ចូលទិន្នន័យ |
| ការិយាល័យពេទ្យ: វេជ្ជបណ្ឌិត គលានុបដ្ឋាយិការ និងឆ្មប | |
| ការិយាល័យប្រឆាំងអំពើទារុណកម្ម: អ្នកពិគ្រោះបញ្ហា និងអ្នកផ្តល់សេវាសង្គមកិច្ច | |

(២០) របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់អង្គការលីកាដូ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨

ជាមួយនឹងកំណែទម្រង់រចនាសម្ព័ន្ធនៃដំណាក់កាលដំបូង លីកាដូបានធ្វើការទៅលើសេចក្តីព្រៀង និងពង្រឹងការទទួលខុសត្រូវការងារ និងធ្វើឱ្យប្រសើរឡើងដោយធ្វើសេចក្តីព្រៀងគោលនយោបាយថ្មីការត្រួតពិនិត្យឡើងវិញ លើកាំប្រាក់បៀវត្សរ៍ និងរៀបចំការវាយតម្លៃលើការអនុវត្តន៍ នៅចុងឆ្នាំ២០០៨ ដោយមានជំនួយពីទីប្រឹក្សាអភិវឌ្ឍន៍អង្គការធ្វើការក្រៅម៉ោង លីកាដូ ខិតខំប្រឹងប្រែងទទួលបាននូវប្រព័ន្ធផ្តល់វិញ្ញាប័នបត្រដោយស្ម័គ្រចិត្តសម្រាប់អង្គការមិនមែនរដ្ឋាភិបាល (ជាគម្រោងមួយរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា) នៅពាក់កណ្តាលឆ្នាំ២០០៩ រួមទាំងការពិនិត្យឡើងវិញ និងការអនុម័តរបស់ប្រធានក្រុមប្រឹក្សាភិបាលថ្មី។

នៅពាក់កណ្តាលឆ្នាំចុងក្រោយ ការិយាល័យអប់រំសិទ្ធិមនុស្ស និងកម្មវិធីប្រឆាំងអំពើទារុណកម្មត្រូវបានបិទដោយសារតែវិបត្តិហិរញ្ញវត្ថុ ការខ្វះខាតធនធានមនុស្ស និងតំរូវការសម្រាប់កម្មវិធីអប់រំសិទ្ធិមនុស្សមានការផ្លាស់ប្តូរ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីសុវត្ថភាពនៃកម្មវិធីផ្តល់ហិរញ្ញវត្ថុបន្ថែមនៅឆ្នាំ២០០៨ សម្រាប់គម្រោងសំខាន់ទាំងពីរនេះ លីកាដូនៅតែបន្តពុះពារទៅនឹងគម្លាតហិរញ្ញវត្ថុដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃករណីរំលោភសិទ្ធិមនុស្ស និងព្រឹត្តិការណ៍នយោបាយនៅឆ្នាំ២០០៨ ។ ដៃគូម្ចាស់សំខាន់ពីរ ICCO និង Diakonia បានបង្កើនមូលនិធិប្រចាំឆ្នាំលើកិច្ចព្រមព្រៀងនៃកិច្ចសន្យាដែលមានស្រាប់នៅឆ្នាំ២០០៨-២០០៩ ហើយនិងដៃគូផ្តល់ជំនួយពីរផ្សេងទៀតក៏បានអនុម័តយល់ព្រមឱ្យមានការ ប្រើប្រាស់ផ្នែកនៃថវិកាដែលមានស្រាប់សម្រាប់ការចំណាយលើសកម្មភាព និងការងារផ្នែករដ្ឋបាលដែលអាចឱ្យលីកាដូឆ្លើយតបទៅនឹងការចំណាយសម្រាប់ឆ្នាំ២០០៨ និងបន្តលើកកម្ពស់និងការពារសិទ្ធិមនុស្សពេញមួយឆ្នាំ។

នៅក្នុងឆ្នាំ២០០៩ អង្គការលីកាដូមានផែនការពិនិត្យឡើងវិញលើផែនការហិរញ្ញវត្ថុ ផែនការយុទ្ធសាស្រ្តរយៈពេល ៣ឆ្នាំ របស់ខ្លួន ដែលនឹងរួមមានការត្រួតពិនិត្យកម្មវិធីផ្សេងៗកាលពីអតីតកាល និងបង្ហាញផែនការហិរញ្ញវត្ថុពីឆ្នាំ២០០៩-២០១១។

**កំនត់សំគាល់:** របាយការណ៍សកម្មភាពនេះនៅតែបែងចែកអំពីសកម្មភាពប្រតិបត្តិការរបស់អង្គការលីកាដូ ដោយប្រើនូវរចនាសម្ព័នរបស់អង្គការពីមុន (ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ការិយាល័យសិទ្ធិស្រ្តី ការិយាល័យសិទ្ធិកុមារ ។ល។) និងមិនប្រើរចនាសម្ព័ន្ធថ្មីទេ (ផ្នែកឃ្លាំមើលនិងការពារសិទ្ធិមនុស្ស និងផ្នែកទំនាក់ទំនងនិងទាក់ទាញមតិគាំទ្រ) ខណៈពេលដែលសកម្មភាពទាំងនេះបានកំពុងដំណើរការរហូតដល់ចុងឆ្នាំ២០០៨។ សកម្មភាពនានាដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធថ្មីនឹងត្រូវបានពន្យល់នៅក្នុងរបាយការណ៍សកម្មភាពឆ្នាំ២០០៩។

## ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរបស់លីកាដូ

អាទិភាពខ្ពស់បំផុតរបស់លីកាដូ គឺដើម្បីធានាធ្វើយ៉ាងណាឱ្យការប្តេជ្ញាចិត្តនានាឆ្លើយតបទៅនឹងតំរូវការរបស់អតិថិជន និងជនរងគ្រោះ ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនានា និងបុគ្គលិក។ មានន័យថា ការ

កែលំអតតឈប់ឈរ ដូចជាការវិវឌ្ឍន៍ថ្មីៗនេះ ឆ្ពោះទៅរកផលប៉ះពាល់ប្រកបដោយគុណភាពដែលរចនាសម្ព័ន្ធគ្រប់គ្រង និងដំណើរការគ្រប់គ្រងករណីកំពុងត្រូវបានពង្រឹង។ ការទាមទារសេវាកម្មនៅតែមានកំរិតខ្ពស់នៅឡើយ ហើយលីកាដូប្តេជ្ញារក្សានូវបទដ្ឋានខ្ពស់របស់ខ្លួនចំពោះការប្រឈមមុខជាមួយនឹងការកើនឡើងករណីដ៏ច្រើន និងបរិយាកាសសិទ្ធិមនុស្សកាន់តែស្មុគស្មាញឡើង។ ការប្តេជ្ញាចិត្តខាងក្រោម ត្រូវបានដាក់តាំងឱ្យឃើញយ៉ាងច្បាស់ជាភាសាខ្មែរ និងអង់គ្លេសនៅតាមការិយាល័យទាំង ១៣ របស់លីកាដូ:




លីកាដូទទួលស្គាល់ពីសារៈប្រយោជន៍នៃការពង្រឹងជាបន្តបន្ទាប់លើអភិបាលកិច្ចនៅក្នុងអង្គការ។ លក្ខន្តិកៈត្រូវបានពិនិត្យឡើងយ៉ាងទូលំទូលាយដោយមានការចូលរួមពីគ្រប់សមាជិកបុគ្គលិកទាំងអស់ ចាប់ពីអ្នកសំអាត និងអ្នកយាម រហូតដល់គណៈគ្រប់គ្រងកំរិតខ្ពស់ ព្រមទាំងលោកស្រីប្រធានអង្គការផងដែរ។ សវនកម្មប្រចាំឆ្នាំត្រូវបានធ្វើឡើងដោយក្រុមហ៊ុន PriceWaterHouse។ ថ្វីត្បិតតែការធ្វើសវនកម្មនេះផ្តោតជាសំខាន់លើភាពត្រឹមត្រូវនៃផ្នែកហិរញ្ញវត្ថុក៏ដោយ ពួកគេក៏បានរួមបញ្ចូលធាតុក្នុងការធានាគុណភាពសំណើរ និងអនុសាសន៍លើការគ្រប់គ្រង និងការអនុវត្តន៍កិច្ចសន្យា។

ការគ្រប់គ្រងហិរញ្ញវត្ថុ (នៅកម្ពុជា វាជាវប្បធម៌អំពើពុករលួយ) ជាផ្នែកដែលលីកាដូបានយកចិត្តទុកដាក់ជាខ្លាំងតាំងតែពីបង្កើតអង្គការមកម្លេះ។ នីតិវិធីត្រូវបានរៀបចំ និងកែតម្រូវឱ្យស្របទៅនឹងម្ចាស់ជំនួយនិងសវនករខាងក្រៅ។ នីតិវិធីហិរញ្ញវត្ថុ និងការទិញសម្ភារៈបរិក្ខា គឺមានតម្លាភាព និងទាមទារឱ្យមានការចុះហត្ថលេខាពីការិយាល័យពាក់ព័ន្ធមួយចំនួន។ ការគ្រប់គ្រងនៅតាមបណ្តាខេត្តត្រូវបានរៀបចំដើម្បីប្រតិបត្តិតាមរបៀបដូចគ្នា

(តែដើម្បីធានានូវការត្រួតពិនិត្យល្អ លីកាដូមានក្រុមចល័តពិសេសមួយដែលមានតួនាទីផ្តល់ការគាំទ្រ និងរៀបចំកម្មវិធីអធិការកិច្ចសម្រាប់ការិយាល័យទាំងអស់)។

## ទស្សនៈវិស័យ និងបេសកកម្មរបស់អង្គការលីកាដូ

ដើម្បីឱ្យស្របទៅនឹងការប្តេជ្ញាចិត្តរបស់អង្គការលីកាដូក្នុងការអភិវឌ្ឍន៍ខ្លួនទៅជាអង្គការមួយ នៅកំឡុងឆ្នាំ២០០៦ បុគ្គលិកបានធ្វើសេចក្តីព្រៀង និងបោះឆ្នោតជ្រើសរើសយកសេចក្តីថ្លែងទស្សនៈវិស័យ និងបេសកកម្មថ្មី។ សេចក្តីថ្លែងនេះ ឆ្លុះបញ្ចាំងពីការវិវឌ្ឍរបស់អង្គការលីកាដូ ជាអង្គការមួយដែលធ្វើការឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ផ្តល់វគ្គបណ្តុះបណ្តាល និងធ្វើសកម្មភាពទាក់ទាញមតិគាំទ្រឆ្ពោះទៅរកការកសាងសមត្ថភាពបុគ្គលិក ដើម្បីពង្រឹងអំណាចអតិថិជនតាមរយៈការរៀបចំឱ្យមានចលនាសង្គមលក្ខណៈទូលំទូលាយ និងសកម្មភាពទាក់ទាញមតិគាំទ្រនៅតាមសហគមន៍។




□□□

# ព័ត៌មានទូទៅ និងការងាររដ្ឋបាល

នៅខែធ្នូ ឆ្នាំ២០០៨ មានបុគ្គលិកចំនួន១៣៥នាក់ ដែលបានធ្វើការពេញម៉ោង និង៤នាក់ មិនពេញម៉ោង (៤២នាក់ ជាបុគ្គលិកស្ត្រី) ដែលកំពុងធ្វើការនៅការិយាល័យអង្គការលីកាដូភ្នំពេញ និងការិយាល័យអង្គការលីកាដូទាំង ១២ខេត្ត-ក្រុង។ អង្គការលីកាដូ មានទីប្រឹក្សាចំនួន៥នាក់ បានធ្វើការពេញម៉ោង និងទីប្រឹក្សាក្រៅម៉ោងម្នាក់ទៀត ក៏បានជួយការងារដៃគូក្នុងតំបន់ជាច្រើនដូចជា ផ្នែកច្បាប់ ការទាក់ទាញមតិគាំទ្រ ធនធានឯកសារ ហិរញ្ញវត្ថុ ផ្នែកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងសកម្មភាពអភិវឌ្ឍន៍របស់អង្គការផងដែរ។ បុគ្គលិកថ្មីចំនួន ១៩នាក់ (៣នាក់ជាស្ត្រី) ត្រូវបានជ្រើសរើសនៅឆ្នាំនេះ ខណៈពេលដែលបុគ្គលិក ២៥នាក់ បានលាឈប់ ឬក៏មិនបានបន្តកិច្ចសន្យាជាថ្មីម្តងទៀត។ លើសពីនេះទៅទៀតមានបុគ្គលិកចំនួន ១១នាក់ ត្រូវបានផ្លាស់ប្តូរទៅតាមការិយាល័យផ្សេងៗ និងមួយចំនួនទៀតត្រូវបានតំឡើងឋានៈ។

គណៈគ្រប់គ្រងរបស់អង្គការលីកាដូមានដូចជា នាយិកា នាយករង ៤នាក់ និងអ្នកសម្របសម្រួលតាមផ្នែក បានជួបប្រជុំគ្នា ៣២ ដង នៅរៀងរាល់រសៀលថ្ងៃសុក្រ ដើម្បីដោះស្រាយឧបសគ្គនានា ដែលជះឥទ្ធិពលលើប្រតិបត្តិការការងាររបស់ការិយាល័យនីមួយៗ។ អ្នកសម្របសម្រួលខេត្តនៃអង្គការលីកាដូ បានជួបប្រជុំជាមួយអ្នកសម្របសម្រួលភ្នំពេញ១០ដង ហើយជាធម្មតា ការប្រជុំនេះធ្វើឡើងជារៀងរាល់ចុងខែ ក្នុងរវាងមួយថ្ងៃទៅបីថ្ងៃដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ ព្រមទាំងកំណត់យកយុទ្ធសាស្ត្រថ្មីដើម្បីអនុវត្តគម្រោងការងារ។

នៅឆ្នាំ២០០៨ បុគ្គលិកអង្គការលីកាដូបំពេញបេសកកម្មបានចំនួន ១៣៧ ក្នុង ១៧ ខេត្ត-ក្រុង (រួមទាំងខេត្តចំនួនប្រាំទៀតដែលអង្គការលីកាដូមិនមានការិយាល័យអចិន្ត្រៃយ៍នៅទីនោះ ប៉ុន្តែយើងទទួលការស្នើសុំពីអង្គការ ដៃគូផ្សេងៗទៀត) ដើម្បីធ្វើការស៊ើបអង្កេត និងជួយដល់ជនរងគ្រោះដោយករណីរំលោភសិទ្ធិមនុស្ស និងដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃទៀត ដែលជាប់ទាក់ទងក្នុងរឿងទាំងអស់នេះ។

នៅខែមេសា ឆ្នាំ២០០៨ លីកាដូបានរៀបចំកិច្ចប្រជុំរយៈពេលមួយថ្ងៃកន្លះ ជាមួយម្ចាស់ជំនួយសំខាន់ៗរបស់ខ្លួនដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងការខិតខំប្រឹងប្រែងទាក់ទាញមតិគាំទ្រ ដើម្បីរៀបចំផែនការកំណែទម្រង់រចនាសម្ព័ន្ធឡើងវិញ។ ពីថ្ងៃទី២០ ដល់ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ លីកាដូបានរៀបចំសិក្ខាសាលាមួយសំរាប់បុគ្គលិក និងដំណើរកំសាន្តនៅខេត្តព្រះសីហនុផងដែរ។

អង្គការលីកាដូ គឺជាប្រធាននៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ស្តីពីអនុសញ្ញានៃការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (NGO CEDAW) និងជាសហប្រធាននៃគណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW)។ អង្គការលីកាដូ គឺជាសមាជិកសកម្មរបស់សហព័ន្ធអន្តរជាតិដើម្បីឯអ្នកការពារសិទ្ធិមនុស្ស

(FIDH) អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល (NGO-CRC) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អង្គការវេទិកាអាស៊ី និងវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា។

នៅឆ្នាំ២០០៨ មានបុគ្គលិកលីកាដូចំនួន ៧៥នាក់ បានទទួលប្រយោជន៍ពីកម្មវិធីបណ្តុះបណ្តាលរបស់អង្គការលីកាដូ។ លើសពីនេះទៅទៀត អង្គការលីកាដូបានបញ្ជូនបុគ្គលិកចំនួន ១៣នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅខាងក្រៅអង្គការ ដែលបានរៀបចំដោយអង្គការដៃគូ។ ហើយប្រធានបទនិមួយៗមានដូចជាៈ វគ្គក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីសិទ្ធិរបស់ជនពិការ ច្បាប់ភូមិបាល ការវិភាគអំពីច្បាប់ មូលដ្ឋានគ្រឹះនៃការញៀនគ្រឿងញៀន ក្រមរដ្ឋប្បវេណី វគ្គគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់អាពាហ៍ពិពាហ៍ និងវគ្គស្តីពីការវាយតម្លៃ។

បុគ្គលិកចំនួន ៣ នាក់ បានធ្វើដំណើរទៅបរទេសដើម្បីចូលរួមវគ្គបណ្តុះបណ្តាល និងសន្និសីទ។ វគ្គបណ្តុះបណ្តាលនោះមានដូចជា វគ្គស្តីអំពីសិទ្ធិមនុស្ស សន្តិភាព និងសុវត្ថិភាព ដែលរៀបចំឡើងនៅក្នុងទីក្រុងស្តុកហោមនៃប្រទេសស៊ុយអែត សន្និសីទថ្នាក់តំបន់ស្តីពីវិជ្ជាជីវៈមេធាវីសម្រាប់សង្គមយុត្តិធម៌ និងសិទ្ធិមនុស្ស នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន និងសន្និសីទអន្តរជាតិមួយទៀតស្តីពីគោលការណ៍ក្នុងភាពស្មើគ្នា និងអភិវឌ្ឍន៍បទដ្ឋានច្បាប់លើភាពស្មើគ្នានៅក្នុងទីក្រុងឡុងដ៏នៃប្រទេសអង់គ្លេស។

ក្រៅពីយុទ្ធនាការដែលបានគ្រោងទុកនៅក្នុងកម្មវិធីនិមួយៗ (ទិវាសិទ្ធិស្ត្រីអន្តរជាតិ ថ្ងៃទី០៨ ខែមីនា ទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ទិវាសារព័ត៌មានពិភពលោកអន្តរជាតិ ថ្ងៃទី០៣ ខែឧសភា ទិវាសិទ្ធិកុមារអន្តរជាតិ ថ្ងៃទី០១ ខែមិថុនា ទិវាប្រឆាំងអំពើទារុណកម្មអន្តរជាតិថ្ងៃទី២៦ ខែមិថុនា យុទ្ធនាការ ១៦ថ្ងៃ ប្រឆាំងអំពើហិង្សាលើយេនឌ័រ ថ្ងៃទី២៦ ខែវិច្ឆិកា ដល់ ថ្ងៃទី១០ ខែធ្នូ) អង្គការលីកាដូក៏បានធ្វើសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលដទៃទៀត និងបានចូលរួមក្នុងព្រឹត្តិការណ៍ជាសាធារណៈមួយចំនួន ដូចជាៈ

- នៅថ្ងៃទី២៨ ខែមករា រៀបចំពិធីបុណ្យខួបលើកទី៤ នៃការជាប់ពន្ធនាគាររបស់ ប៊ិន សំណាង និង សុខ សំអឿន ធ្វើនៅវត្តស្វាយពពែក្នុងរាជធានីភ្នំពេញដែលមានអ្នកចូលរួមចំនួន ១៣៥ នាក់ មកពីអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។
- នៅថ្ងៃទី១៩ ខែកុម្ភៈ រៀបចំសន្និសីទសារព័ត៌មាននៅក្លឹបអ្នកឆ្លើយឆ្លងព័ត៌មានអន្តរជាតិ (FCC) ដើម្បីផ្សព្វផ្សាយរបាយការណ៍ស្តីអំពីការការពារសិទ្ធិសេដ្ឋកិច្ច និងសង្គម ដែលរៀបចំឡើងក្រោមការសហការជាមួយអង្គការអាដហុក និងអង្គការសហព័ន្ធអន្តរជាតិដើម្បីការពារសិទ្ធិមនុស្ស។
- នៅថ្ងៃទី២០ ខែកុម្ភៈ រៀបចំសន្និសីទសារព័ត៌មានមួយ នៅភូមិអណ្តូង កន្លែងតាំងលំនៅឋានថ្មីដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហព័ន្ធអន្តរជាតិដើម្បីអ្នក

ការពារសិទ្ធិមនុស្ស ដោយលើកយកពីការបណ្តេញចេញពីដីធ្លី ហើយមានអ្នកភូមិចូលរួមចំនួន ១៥៥ នាក់ ។

- នៅថ្ងៃទី២៣ ខែកញ្ញា ប្រារព្ធធ្វើនូវព្រឹត្តិការណ៍ប្រលែងប៉េងប៉ោងចំនួន ១,៧០០ នៅពន្ធនាគារ ប៉េហ្ស៊ី ដើម្បីកំនត់ថ្ងៃទី ១,៧០០ ដែលលោក ប៊ន សំណាង និងលោក សុខ សំអឿន ស្ថិតនៅក្នុង ពន្ធនាគារ ដោយមានការចូលរួមពីអង្គការផ្សេងៗ ។
- នៅថ្ងៃទី១០ ខែធ្នូ មានការប្រារព្ធធ្វើទិវាសិទ្ធិមនុស្សទូទាំងប្រទេស និងខួបលើកទី៦០ នៃសេចក្តី ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ អង្គការលីកាដូ និងអង្គការដទៃទៀតបានជួយធ្វើការសម្រប សម្រួលព្រឹត្តិការណ៍ទាំង ២៦ នៅទូទាំង ១៤ ខេត្ត និងបានចែកផងដែរនូវខិត្តប័ណ្ណចំនួន ៥,០០០ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ ។

សេចក្តីប្រកាសព័ត៌មាន របាយការណ៍សង្ខេប និងរបាយការណ៍មួយចំនួនបានបោះពុម្ពផ្សាយក្នុងកំឡុងពេល កន្លងមកនេះ ក្នុងគោលបំណងអប់រំមន្ត្រីរាជរដ្ឋាភិបាល សង្គមស៊ីវិល និងសាធារណៈជនទូទៅឱ្យបានដឹងអំពីច្បាប់ និងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយរបាយការណ៍ទាំងអស់នេះក៏បានរៀបចំឡើងក្រោមការសហការជាមួយ អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ លោកអ្នកអាចមើលបញ្ជីរាយឈ្មោះនៃសកម្មភាពទាំងអស់នេះ នៅក្នុង ឧបសម្ព័ន្ធនៃរបាយការណ៍នេះ។ បញ្ជីឈ្មោះខាងក្រោមនេះមានរួមទាំងរបាយការណ៍ និងរបាយការណ៍សង្ខេបដែល បានបោះពុម្ព និងចេញផ្សាយដោយអង្គការលីកាដូនៅក្នុងឆ្នាំ២០០៨ :

- ការសិក្សាស្រាវជ្រាវៈ ពលករកុមារនៅសិប្បកម្មឡឥដ្ឋ មូលហេតុ និងផលវិបាក ( ខែឧសភា)
- ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញៈ នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្រប់គ្រង ប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជា ដោយរបៀបណា ( ខែឧសភា)
- ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ ២០០៧ៈ រឿងនិទានម្តាយ និងកូនស្រីម្នាក់ ( ខែមីនា)
- របាយការណ៍សកម្មភាពប្រចាំឆ្នាំអង្គការលីកាដូ ឆ្នាំ២០០៧ ( ខែមីនា)
- របាយការណ៍លីកាដូ និងលីកាដូកាណាដាៈ សេចក្តីពន្យល់ករណីដីធ្លីនៅសហមន៍ដីក្រហម ( ខែមករា)
- ការវាយប្រហារ និងការគំរាមកំហែងប្រឆាំងនឹងក្រុមអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៧ ( ខែកញ្ញា)
- ខិត្តប័ណ្ណផ្សព្វផ្សាយទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០០៨ ( ខែធ្នូ)

(២៦) របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់អង្គការលីកាដូ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨






















□□□

# ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស




**គោលបំណង**

- រកឱ្យឃើញនូវការរំលោភសិទ្ធិមនុស្ស និងឱ្យអាជ្ញាធរបានដឹងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។
- បង្កើតនូវវិធីសាស្ត្រដ៏មានប្រសិទ្ធភាព ដែលការរំលោភសិទ្ធិមនុស្សត្រូវបានគេបង្ហាញ ចងក្រងជាឯកសារ រក្សាទុក ស៊ើបអង្កេត និងកែតម្រូវកំហុសដែលបានរកឃើញ។
- ជួយជនងាយរងគ្រោះបំផុតនៅក្នុងសង្គម និងលាតត្រដាងនូវការរំលោភបំពានដែលកើតមានចំពោះពួកគេ។
- បង្កើត និងអនុវត្តយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាព ដើម្បីផ្សារភ្ជាប់ការចូលរួមរបស់អាជ្ញាធរអនុវត្តច្បាប់ ជំនួសឱ្យជនរងគ្រោះ ដើម្បីពង្រឹងការអនុវត្តជំនាញវិជ្ជាជីវៈរបស់ខ្លួន និងដើម្បីទប់ស្កាត់អំពើរំលោភបំពាននាពេលខាងមុខ។
- បង្កើតជំនាញជាក់លាក់ក្នុងការចំណាត់ប្រភេទសិទ្ធិមនុស្ស ដែលនេះជាការព្រួយបារម្ភជាពិសេសសម្រាប់អង្គការលីកាដូ ដែលមានដូចជាៈ ការសម្លាប់ក្រៅប្រព័ន្ធច្បាប់ ការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងនគរបាល ការឃុំខ្លួនខុសច្បាប់ ការបាត់ខ្លួន ការចាប់ជំរិត ការគំរាមកំហែង ការបំភិតបំភ័យ ការរឹបអូសដីធ្លី ការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ។
- ប្រមូល និងរក្សាទុកឯកសារ និងទិន្នន័យសម្រាប់ស្រាវជ្រាវ និងវិភាគទៅលើករណីរំលោភសិទ្ធិមនុស្ស រួមទាំងការភ្ជាប់ធនធានព័ត៌មានថ្នាក់ជាតិ និងអន្តរជាតិក្នុងគោលបំណងទាក់ទាញមតិគាំទ្របញ្ហាផ្នែកច្បាប់ និងសង្គម។
- រក្សាអ្នកជំនាញផ្នែកច្បាប់នៅក្នុងអង្គការ និងទទួលអ្នកការពារច្បាប់ពីអង្គការដទៃទៀត។
- ផលិតរបាយការណ៍ទាក់ទាញមតិគាំទ្រ សេចក្តីថ្លែងការណ៍ របាយការណ៍សង្ខេបខ្លីៗដែលមានគុណភាពល្អសម្រាប់អង្គការលីកាដូ គណៈកម្មាធិការប្រព្រឹត្តិកម្មកម្ពុជា គណៈកម្មាធិការស្ត្រីកម្ពុជា ក្រុមអ្នកការពារសិទ្ធិលំនៅឋាន វេទិកាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងសន្និសញ្ញាអង្គការមិនមែនរដ្ឋាភិបាលស្តីពីសិទ្ធិកុមារ ដែលនិងផ្តល់ព័ត៌មានលើករណីធ្ងន់ធ្ងរ ឬទំរង់នៃការរំលោភបំពាន និងកែប្រែជាបន្ទាន់ និងរកវិធានការទប់ស្កាត់ជាមុន។

**លទ្ធផលសំរេចបាន**

សកម្មភាពចំបងរបស់ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សត្រូវបានបែងចែកជាបីផ្នែកសំខាន់ៗ គឺៈ

- **ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស**

  ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សធ្វើការជាចំបងលើការឃ្លាំមើល និងការស្រាវជ្រាវករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយមន្ត្រីរាជរដ្ឋាភិបាល និងដោយស្ថាប័នរាជរដ្ឋាភិបាល។ ការិយាល័យនេះក៏ផ្តល់ជំនួយដល់ជនរងគ្រោះតាមរយៈការផ្តល់យោបល់ផ្នែកច្បាប់ និងធ្វើអន្តរាគមន៍ទៅអាជ្ញាធរមូលដ្ឋាន និងមន្ត្រីមូលដ្ឋាន។

- **កម្មវិធីស្រាវជ្រាវពន្ធនាគារ**

  កម្មវិធីស្រាវជ្រាវពន្ធនាគារ សម្ភាសន៍ទណ្ឌិត និងពិរុទ្ធជន ព្រមទាំងឃ្លាំមើលការរំលោភសិទ្ធិមនុស្សក្នុងពន្ធនាគារចំនួន ១៨ ក្នុងចំណោម ពន្ធនាគារទាំង ២៦ ក្នុងប្រទេសកម្ពុជា។ អ្នកស្រាវជ្រាវពន្ធនាគារក៏សហការជាមួយការិយាល័យពេទ្យរបស់អង្គការលីកាដូ ដែលបានចុះពិនិត្យ និងព្យាបាលអ្នកទោសក្នុងពន្ធនាគារចំនួន១២។

- **កម្មវិធីមេធាវីការពារសិទ្ធិមនុស្ស**

  កម្មវិធីមេធាវីការពារសិទ្ធិមនុស្ស ជាកម្មវិធីថ្មីដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ និងធ្វើជាតំណាងចំពោះប្រភេទករណីរំលោភសិទ្ធិមនុស្សដែលត្រូវបានជ្រើសរើសមួយចំនួន។

***ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស***

នៅក្នុងឆ្នាំ២០០៨នេះ ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស បានស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្សសរុបចំនួន ៣៧៩ ករណី (កើនឡើង ១៧% បើប្រៀបធៀបជាមួយឆ្នាំ២០០៧) ក្នុងនោះមានបទល្មើស សរុប ៥២៦ ករណី (កើនឡើង ៧០% បើប្រៀបធៀបជាមួយឆ្នាំ២០០៧) ហើយមានជនរងគ្រោះចំនួន ១៦,៧២៥ នាក់។ ករណីរំលោភយកដីធ្លីជាប្រភេទករណីដែលកើតមានឡើងច្រើនជាងគេបំផុតក្នុងចំណោមប្រភេទករណីរំលោភសិទ្ធិមនុស្សផ្សេងទៀត ដែលមានជនរងគ្រោះ ចំនួន ១៤,៦៥០ នាក់ (កើនឡើង ៤២%ប្រៀបធៀប ឆ្នាំ២០០៧)។ ចំនួនច្រើនបន្ទាប់ជាជនរងគ្រោះដោយសារករណីបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំ ដែលជាទូទៅជាប់ពាក់ព័ន្ធនឹងការជំទាស់នឹងការរំលោភយកដីធ្លី។ លើសពីនេះទៀត ករណីមនុស្សឃាត បង្ករបួសស្នាម ការចាប់ និងឃុំខ្លួនខុសច្បាប់



ក៏មានការជាប់ពាក់ព័ន្ធនឹងករណីរំលោភយកដីធ្លីផងដែរ ។ ករណីរំលោភយកដីធ្លី គឺជាករណីមួយស្ថិតក្នុងចំណោមករណីធ្ងន់ធ្ងរបំផុត ពីព្រោះវាមានផលប៉ះពាល់ចំពោះសន្តិសុខ និងជីវភាពរស់នៅរបស់គ្រួសារ និងសហគមន៍ទាំងមូល ។ ភាពគ្មានដីធ្លីនៅប្រទេសកម្ពុជាមានសភាពដូចគ្នានឹងភាពក្រីក្រធ្ងន់ធ្ងរ ការធ្វើចំណាកស្រុកទៅទីក្រុងការបែកបាក់ និងការបំផ្លិចបំផ្លាញគ្រួសារ និងសហគមន៍ ហើយក្នុងស្ថានភាពធ្ងន់ធ្ងរបំផុតនោះ រហូតឈានដល់ការខ្វះខាតអាហារូបត្ថម្ភ ការអត់ឃ្លាន និងស្លាប់ថែមទៀតផង ។

**ករណីរំលោភសិទ្ធិមនុស្ស ដែលការិយាល័យឃ្លាំមើលសិទ្ធិមនុស្សទទួលបានពីខែមករា ដល់ខែមិថុនា ឆ្នាំ២០០៨**




| | |
|---|---|
| K = មនុស្សឃាត | HTL = ការជួញដូរមនុស្សដើម្បីពលកម្ម |
| AK = ប៉ុនប៉ងធ្វើមនុស្សឃាត | OFEA = ការបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ/ការជួបជុំគ្នា |
| MK = ការសម្លាប់ដោយហ្វូងមនុស្ស | DAP = ការបំផ្លិចបំផ្លាញទ្រព្យ ឬរឹបអូសទ្រព្យសម្បត្តិដោយអំពើ ខុសច្បាប់ |
| DT = ការគំរាមកំហែងដល់អាយុជីវិត | LG = ការរំលោភយកដីធ្លី |
| T = ទារុណកម្ម | FE = ការបណ្តេញចេញដោយបង្ខំ |
| PA = បង្ករបួសស្នាម | FPP = មិនអនុវត្តតួនាទី |
| THI = ការគំរាមកំហែង និងបំភិតបំភ័យ | SC = ករណីផ្សេងៗ/ករណីពិសេស |
| A = ការចាប់ជំរិត | FPA = ការបង្ខំឱ្យស្បថ |
| IAD = ការចាប់ និងឃុំខ្លួនខុសច្បាប់ | SI = ការរំខានក្នុងការលើកផ្លាកគណបក្ស |

ក្នុងកំឡុងឆ្នាំ២០០៨ អ្នកស៊ើបអង្កេតក៏បានតាមដានករណីចាស់ៗពីឆ្នាំមុន ដើម្បីពិនិត្យមើលថាតើជនរងគ្រោះត្រូវការជំនួយបន្ថែមទៀត ឬការអន្តរាគមន៍នៅតែបន្ត។ អ្នកស៊ើបអង្កេតក៏រិតខ្ពស់ និងទីប្រឹក្សាបរទេសបីនាក់ត្រូវតែឆ្លើយតបទៅនឹងករណីលំបាកមួយចំនួនដែលទាមទារឱ្យមានស្វែងរកសិទ្ធិជ្រកកោន និងសេវាការពារ។

តារាងខាងក្រោមបង្ហាញពីចំនួននៃប្រឹក្សាយោបល់ផ្នែកច្បាប់ និងអង្កេតការ (បាតុកម្ម និងព្រឹត្តិការណ៍សិទ្ធិមនុស្សផ្សេងៗ) និងការអន្តរាគមន៍ ដែលការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សបានធ្វើ។

## ការផ្តល់យោបល់ផ្នែកច្បាប់ និងការធ្វើអន្តរាគមន៍ដោយការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សក្នុងឆ្នាំ២០០៨

| ការិយាល័យ | យោបល់ផ្នែកច្បាប់ | អង្កេតការ | ការធ្វើអន្តរាគមន៍ | | | | |
|---|---|---|---|---|---|---|---|
| | | | តុលាការ | អាជ្ញាធរ | គណៈកម្មាធិការជីវិ | ការប្រជុំ | សរុប |
| បាត់ដំបង | ៧៣ | ២២ | ២ | ៥ | | ២១ | ២៨ |
| បន្ទាយមានជ័យ | ៨៧ | ១ | | ១១ | ១៣ | ២០ | ៤៤ |
| កំពង់ធំ | ១០៧ | ៧០ | ៩ | ២ | ១០ | ៣ | ២៤ |
| កំពង់ឆ្នាំង | ៧៩ | ១៣ | ២ | ២ | ៤ | ៩ | ១៧ |
| កំពង់ស្ពឺ | ១០១ | ១០ | ៦ | | | ១០ | ១៦ |
| ព្រះសីហនុ | ១២៧ | ១២ | ១ | ៦ | ១ | ២១ | ២៩ |
| កំពត | ១០៧ | ៣២ | ៣ | | | ២៩ | ៣២ |
| កោះកុង | ៧១ | ៦ | ២ | | | ៩ | ១១ |
| កំពង់ចាម | ១០០ | ៥ | | | | ៣០ | ៣០ |
| ភ្នំពេញ | ៦១៦ | ៥៣ | ៤ | ១១ | | ៤៥ | ៦០ |
| ពោធិ៍សាត់ | ១១២ | ៧ | ១០ | ៦ | ១ | ២ | ១៩ |
| សៀមរាប | ១០៤ | ២៧ | ២ | ១២ | | ៤៦ | ៦០ |
| ស្វាយរៀង | ៦៤ | ៥ | ៣ | ៥ | ២ | ៨ | ១៨ |
| ក្រចេះ * | | | | | | ២ | ២ |
| ព្រះវិហារ * | | | | | | ២ | ២ |
| តាកែវ * | | | | | | ៣ | ៣ |
| ព្រៃវែង * | | | | | | ៣ | ៣ |
| **សរុប** | **១,៧៤៨** | **២៦៣** | **៤៤** | **៦០** | **៣១** | **២៦៣** | **៣៩៨** |

*ខេត្តគ្មានការិយាល័យលីកាដូ

### *កម្មវិធីស្រាវជ្រាវពន្ធនាគារ*

អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ ចុះទៅពន្ធនាគារនីមួយៗ យ៉ាងហោចណាស់ មួយដង ក្នុង ១ សប្តាហ៍ ឬ ពីរដងក្នុង ១ ខែ ដើម្បីសម្ភាសន៍អ្នកទោស។ ការធ្វើសម្ភាសន៍ចំណាយពេលប្រហែលជាពី ២-៣ ម៉ោង ហើយអាចសម្ភាសន៍បានអ្នកទោសពី ៣-៥ នាក់។ អ្នកស្រាវជ្រាវពន្ធនាគារបានប្រើទម្រង់សំណួរដែលមានស្រាប់

សម្រាប់សួរអ្នកទោសអំពីព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ការព្យាបាល ស្ថានភាពរស់នៅក្នុងពន្ធនាគារ ការធ្វើបណ្តឹងផ្នែកច្បាប់ និងព័ត៌មានសំខាន់ៗទៀត។

នៅក្នុងឆ្នាំ២០០៨ អ្នកស្រាវជ្រាវពន្ធនាគារបានសម្ភាសន៍ អ្នកទោសចំនួន ១,៩៨៣ នាក់ ទាំងពិរុទ្ធជន និងទណ្ឌិត រួមទាំងអ្នកទោសស្ត្រី ចំនួន ១៧៤ នាក់។ យោងតាមការធ្វើសម្ភាសន៍ មានអ្នកទោស ៨៥ នាក់ (ស្ត្រីម្នាក់) ត្រូវបានគេត្រូវគេធ្វើទារុណកម្ម ក្នុងនោះមាន ៧៨ ករណី បានកើតឡើង ខណៈពេលជាប់ក្នុងមន្ទីរឃុំឃាំងរបស់នគរបាល និង ៧ ករណីនៅក្នុងពន្ធនាគារ ។ អ្នកទោស ៣៩ នាក់បានស្លាប់នៅក្នុងពន្ធនាគារទាំង១៣។

**ករណីសិក្សាកម្មវិធីស្រាវជ្រាវពន្ធនាគារ**

*ក្នុងកំឡុងពេលចុះសួរសុខទុក្ខអ្នកទោសនៅពន្ធនាគារខេត្តកំពង់ឆ្នាំង អ្នកស្រាវជ្រាវពន្ធនាគារនៃ អង្គការលីកាដូ បានសង្កេតឃើញថា ក្មេងប្រុសអាយុ១២ឆ្នាំ ម្នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគារ (អាយុ១៣ឆ្នាំ គឺជាអាយុអតិបរមាដែលអនីតិជនអាចត្រូវបានឃុំខ្លួន)។*

*ក្មេងប្រុសនេះត្រូវបានចាប់ខ្លួនជាមួយនឹងក្មេងប្រុសអាយុ ១៤ និង ១៥ ឆ្នាំ នៅដើមឆ្នាំនេះ។ នៅពេលដែលក្មេងប្រុសនាំយកទៅតុលាការ គាត់បានឆ្លើយប្រាប់ព្រះរាជអាជ្ញាថាគាត់មានអាយុ១៣ ឆ្នាំ។ ក្មេងប្រុសទាំង៣នាក់ ត្រូវបានចោទប្រកាន់ពីបទលួចទ្រព្យសម្បត្តិ និងត្រូវបញ្ជូនឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ឆ្នាំង។*

*ក្រោយពេលស៊ើបអង្កេត នៅក្នុងខែតុលា អង្គការលីកាដូបានធ្វើលិខិតអន្តរាគមន៍ទៅព្រះរាជអាជ្ញាដោយមានបញ្ជាក់ពីអាយុរបស់ក្មេងប្រុសនោះ។ នៅក្នុងខែវិច្ឆិកា ព្រះរាជអាជ្ញាបានទាក់ទងមកអង្គការ លីកាដូ និងស្វាគមន៍ចំពោះការយកចិត្តទុកដាក់របស់អង្គការ លីកាដូក្នុងការស្រាវជ្រាវករណីជំនួសគាត់ ហើយបានអញ្ជើញអង្គការលីកាដូឱ្យទៅជួបគាត់ និងចៅក្រមស៊ើបអង្កេតនៅថ្ងៃបន្ទាប់។*

*នៅក្នុងអង្គប្រជុំ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតបានថ្លែងអំណរគុណដល់អង្គការលីកាដូ ចំពោះការស្រាវជ្រាវលើករណីនេះ ហើយសូមឱ្យមានកិច្ចសហប្រតិបត្តការបន្ថែមទៀត។ បីថ្ងៃក្រោយមក ក្មេងប្រុសទាំងបីនាក់ត្រូវបានដោះលែងឱ្យទៅរស់ជួបជុំក្រុមគ្រួសាររបស់ពួកគាត់វិញ។*

**គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ**

គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគាររបស់អង្គការលីកាដូ បានចាប់ផ្តើមនៅឆ្នាំ២០០៣ ដើម្បីជួយសម្របសម្រួលក្នុងការផ្តល់ជំនួយម្ហូបអាហារ និងសម្ភារៈសម្រាប់កុមារ និងម្តាយ

របស់ពួកគេ និងស្ត្រីមានផ្ទៃពោះដែលរស់នៅក្នុងពន្ធនាគារ ដោយមានការសហការជាមួយអង្គការដៃគូ និងម្ចាស់ជំនួយឯកជន។

**ចំនួនកុមារ និងស្ត្រីមានផ្ទៃពោះ រស់នៅក្នុងពន្ធនាគារ ក្នុងខែធ្នូ ឆ្នាំ២០០៨**

| ពន្ធនាគារ | មណ្ឌលអប់រំកែប្រែទី២ | តាខ្មៅ | ប៉ៃលិន | បាត់ដំបង | បន្ទាយមានជ័យ | ស្វាយរៀង | សៀមរាប | កោះកុង | កំពង់ឆ្នាំង | កំពង់ចាម | កំពង់ធំ | ពោធិ៍សាត់ | ព្រះសីហនុ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កុមារ | ១៧ | ៨ | ០ | ២ | ៤ | ៣ | ៧ | ៣ | ២ | ៣ | ១ | ៣ | ១ | ៥៤ |
| ស្ត្រីមានផ្ទៃពោះ | ៤ | ១ | ១ | ១ | ០ | ០ | ១ | ១ | ១ | ១ | ០ | ១ | ០ | ១២ |
| សរុប | ២១ | ៩ | ១ | ៣ | ៤ | ៣ | ៨ | ៤ | ៣ | ៤ | ១ | ៤ | ១ | ៦៦ |

## កម្មវិធីមេធាវីការពារសិទ្ធិមនុស្ស

ថ្វីត្បិតតែមេធាវីមានចំនួនកំណត់ក៏ដោយនៅក្នុងឆ្នាំ២០០៨ (មេធាវីធ្វើការពេញម៉ោងមានចំនួន ៣ នាក់ និងមេធាវីម្នាក់ទៀតត្រូវបានជ្រើសរើសក្នុងខែវិច្ឆិកា ឆ្នាំ២០០៨) ក៏កម្មវិធីមេធាវីការពារសិទ្ធិមនុស្សបានធ្វើការលើករណីថ្មីចំនួន ៣៨ ករណី និងតំណាងផ្នែកច្បាប់ជូនជនរងគ្រោះចំនួន៦៨នាក់ទូទាំង ១១ ខេត្ត។ ចំនួនដ៏ច្រើនលើសលុបនៃករណីទាំងនោះ ជាប់ពាក់ព័ន្ធនឹងករណីរំលោភយកដីធ្លី ចំនួន ១៨ករណី និងអំពើហិង្សាលើស្ត្រី ១៤ ករណី។ ជនរងគ្រោះភាគច្រើនជាជនរងគ្រោះដោយករណីហិង្សាធ្ងន់ធ្ងរ។

## ចំនួនករណីរំលោភសិទ្ធិមនុស្ស ដែលទទួលជំនួយពីកម្មវិធីមេធាវីក្នុងឆ្នាំ២០០៨

| ល.រ | ខេត្ត | ជនរងគ្រោះ | ប្រភេទករណី | ថ្ងៃសវនាការ | លទ្ធផល | សរុបករណី |
|---|---|---|---|---|---|---|
| ១ | កំពត | ៤ | រំលោភសេពសន្ថវៈ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ៤ |
| ២ | កំពង់ឆ្នាំង | ១ | រំលោភសេពសន្ថវៈ | បញ្ជូនទៅអង្គការការពារយុត្តិធម៌កុមារ | បិទសំណុំរឿង | ១ |
| ៣ | កំពត | ១ | អំពើហិង្សាក្នុងគ្រួសារ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ៤ | ស្វាយរៀង | ២ | រំលោភយកដីធ្លី | បិទសំណុំរឿង | បិទសំណុំរឿង | ១ |
| ៥ | ស្វាយរៀង | ១ | អំពើជួញដូរមនុស្ស | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ៦ | បន្ទាយមានជ័យ | ២ | រំលោភយកដីធ្លី | កំពុងដំណើរការីវិធី | កំពុងដំណើរការនីតិវិធី | ២ |
| ៧ | កំពង់ធំ | ១៥ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ៣ |
| ៨ | កំពង់ស្ពឺ | ៣ | រំលោភយកដីធ្លី | បិទសំណុំរឿង | បិទសំណុំរឿង | ៣ |
| ៩ | កំពត | ៨ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ៥ |
| ១០ | ភ្នំពេញ/កណ្តាល | ៧ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ៣ |
| ១១ | ភ្នំពេញ/កណ្តាល | ៤ | ការពារសិទ្ធិមនុស្ស | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ២ |
| ១២ | ភ្នំពេញ/កណ្តាល | ១ | ផ្សេងៗ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ១៣ | ភ្នំពេញ/កណ្តាល | ១ | រំលោភសេពសន្ថវៈ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ១៤ | បាត់ដំបង | ៣ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ១៥ | ព្រះសីហនុ | ២ | រំលោភសេពសន្ថវៈ | កំពុងដំណើរការ ១/ បិទសំណុំរឿង ១ | កំពុងដំណើរការ ១/ បិទសំណុំរឿង ១ | ២ |
| ១៦ | ពោធិ៍សាត់ | ១ | អំពើហិង្សាក្នុងគ្រួសារ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ១៧ | ពោធិ៍សាត់ | ៣ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ១៨ | ពោធិ៍សាត់ | ៣ | រំលោភសេពសន្ថវៈ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ៣ |
| ១៩ | សៀមរាប | ៤ | រំលោភយកដីធ្លី | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ១ |
| ២០ | កំពត | ៣ | ផ្សេងៗ | កំពុងដំណើរការនីតិវិធី | កំពុងដំណើរការនីតិវិធី | ២ |
| **សរុប** | | **៦៨** | | | | **៣៨** |

## ករណីសិក្សា: តំណាងផ្អែកច្បាប់លើករណីរំលោភដីធ្លី

ប្រជាពលរដ្ឋនៅក្នុងភូមិវាលទន្សាយ ឃុំមានជ័យ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានរស់នៅលើដីរបស់ពួកគាត់តាំងពីឆ្នាំ១៩៧៩ ហើយនៅក្នុងឆ្នាំ១៩៨៦ ពួកគាត់បានយល់ព្រមដោះដូរដីជាមួយនឹងសាលាឃុំមានជ័យ ហើយបានទៅរស់នៅក្នុងភូមិទំពូង ។ នៅក្នុងឆ្នាំ១៩៩២ សាលាឃុំបានប្តូរទីតាំងថ្មី ហើយប្រជាពលរដ្ឋទាំងអស់បានទៅរស់នៅក្នុងដីចាស់របស់ពួកគាត់វិញ ។

នៅក្នុងឆ្នាំ២០០៦ លោកប្រធានឃុំមានជ័យ ឈ្មោះ ផេង ប៉ាល់ មានបំណងរំលោភយកដីនោះ ដោយផ្អែកលើប្លង់ដីដែលគាត់បានធ្វើដោយខ្លួនឯងនៅក្នុងឆ្នាំ១៩៩៥ ។ ជម្លោះរវាងមន្ត្រីឃុំ និងសហគមន៍បានឮសុសសាយ ហើយករណីត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តកំពង់ស្ពឺ ។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ជនរងគ្រោះ២នាក់ ដែលជាតំណាងឱ្យគ្រួសាររងគ្រោះទាំង៣៥ គ្រួសារ ត្រូវបានចាប់ខ្លួននៅក្នុងភូមិទំពូង ដោយចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនបង្កឡើងនៅក្នុងឆ្នាំ២០០៦ ។ ដោយផ្អែកលើការស្នើសុំពីជនរងគ្រោះ លីកាដូបានយល់ព្រមទទួលការពារក្តីឱ្យប្រជាពលរដ្ឋទាំងពីរនាក់នេះ ។ ដោយសហការជាមួយអ្នកស៊ើបអង្កេតប្រចាំខេត្តកំពង់ស្ពឺ មេធាវីអង្គការលីកាដូបានប្រមូលភស្តុតាង និងជួបជាមួយជនរងគ្រោះនៅពន្ធនាគារ ដើម្បីរៀបចំការពារក្តីរបស់ពួកគេ ។ ពាក្យស្នើសុំឱ្យជនរង គ្រោះនៅក្រៅឃុំ ត្រូវបានបញ្ជូនទៅតុលាការ ប៉ុន្តែត្រូវបានបដិសេធចោល ។

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ តុលាការខេត្តកំពង់ស្ពឺបានបើកសវនាការ ។ ចៅក្រមបានសំរេចផ្តន្ទាទោសបុរសទាំងពីរនាក់ ដាក់ពន្ធនាគារ ១ ឆ្នាំ ព្យួរទោស ៨ ខែ និងទោសសាកល្បង ៥ឆ្នាំ ។ តុលាការក៏បានបង្គាប់តំណាងប្រជាពលរដ្ឋទាំងពីរ ផ្តល់សំណងចំនួន ១លានរៀល (២៥០ ដុល្លាអាមេរិក) ទៅឱ្យមន្ត្រីសាលាឃុំមានជ័យ ។ ប៉ុន្តែ ព្រះរាជអាជ្ញាមិនយល់ព្រមនឹងការសំរេចចិត្តនោះឡើយ ដូច្នេះគាត់បានប្តឹងឧទ្ធរណ៍ ដែលនាំឱ្យប្រជាពលរដ្ឋទាំងពីរនាក់នោះនៅត្រូវបានឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំសវនាការឧទ្ធរណ៍ ។

សវនាការសាលាឧទ្ធរណ៍បានបើកនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៨ និងសម្រេចកាត់បន្ថយទោសឃុំឃាំងនៅក្នុងពន្ធនាគារត្រឹមតែ ៩ ខែ កន្លះ ប៉ុណ្ណោះ ។ ក្រោយពីសវនាការ លីកាដូបានស្នើឱ្យតុលាការចេញសាលក្រមឱ្យបានលឿនដើម្បីដោះលែងបុរសទាំងពីរឱ្យបានលឿន ។ ជាចុងក្រោយ បុរសទាំងពីរត្រូវបានដោះលែងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយអាចត្រលប់ទៅសហគមន៍របស់ពួកគាត់ ដើម្បីតំណាងប្រជាពលរដ្ឋ ដែលកំពុងតែតស៊ូដើម្បីឱ្យសិទ្ធិដីធ្លីរបស់គេទទួលស្គាល់ ។

## ការកសាងសមត្ថភាពបុគ្គលិក

ការិយាល័យឃ្លាំមើលសិទ្ធិមនុស្ស បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ជូនដល់អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អ្នកស្រាវជ្រាវពន្ធនាគារ មេធាវី អ្នកឃ្លាំមើលការរំលោភសិទ្ធិកុមារ អ្នកឃ្លាំមើលរំលោភសិទ្ធិស្ត្រី និងអ្នកសម្របសម្រួលខេត្តចាប់ពីថ្ងៃទី២៣-២៥ ខែមករា ឆ្នាំ២០០៨ ដែលមានបុគ្គលិកចូលរួមសរុបចំនួន ៥០ នាក់។ នៅថ្ងៃទី៣-៥ ខែកញ្ញា ឆ្នាំ២០០៨ អ្នកសម្របសម្រួលខេត្ត និងអ្នកស្រាវជ្រាវពន្ធនាគារសរុបចំនួន ៣៧ នាក់បានចូលក្នុងវគ្គបណ្តុះបណ្តាលស្តីពី ក្រមរដ្ឋប្បវេណី និងច្បាប់អាពាហ៍ពិពាហ៍។

មេធាវីម្នាក់បានសិក្សាភាសាអង់គ្លេសសម្រាប់រយៈពេល ១ វគ្គ នៅមជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការបណ្តុះបណ្តាល (ACE) ដែលការសិក្សានេះមានទំនាក់ទំនងនឹងការទទួលខុសត្រូវការងាររបស់គាត់។

## ឥទ្ធិពល

- ដំណោះស្រាយទាន់ពេលវេលាបានផ្តល់ភាពជឿជាក់ និងការការពារជាមូលដ្ឋានចំពោះជនរងគ្រោះ និងសហគមន៍ ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងហិង្សា ។
- ជនរងគ្រោះត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីរកដំណោះស្រាយតាមមធ្យោបាយផ្នែកច្បាប់ ហើយជួយគាំទ្រជនរងគ្រោះផ្សេងទៀតនៅក្នុងសហគមន៍របស់ពួកគេ បន្ទាប់ពីទទួលបានសេវាផ្នែកស៊ើបអង្កេត ផ្នែកច្បាប់ និងការតស៊ូមតិ។
- សហប្រតិបត្តិការ និងការឧបត្ថម្ភគាំទ្រជម្រុញសហគមន៍សិទ្ធិមនុស្ស ឱ្យឆ្លើយតបចំពោះការរំលោភសិទ្ធិមនុស្ស។ អង្គការលីកាដូធ្វើការផ្ទាល់ចំពោះការឃុំខ្លួន និងការការពារអ្នកការពារសិទ្ធិមនុស្ស។
- តាមរយៈប្រព័ន្ធផ្សាយព័ត៌មាន សាធារណៈជន និងសហគមន៍អន្តរជាតិបានទទួលបានព័ត៌មានអំពីករណី និងបញ្ហារំលោភសិទ្ធិមនុស្សជាទៀតទាត់។
- សហគមន៍បានចូលរួមយ៉ាងទូលំទូលាយក្នុងយុទ្ធនាការនានា និងផ្តល់អំណាចដល់ជនរងគ្រោះ និងអ្នកតស៊ូមតិក្នុងសហគមន៍។
- ការចុះសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារ អាចឱ្យអ្នកស្រាវជ្រាវពន្ធនាគារ និងបុគ្គលិកពេទ្យ ធានាបានថាអ្នកទោសទទួលបានការពារផ្នែកច្បាប់ សុខភាពមូលដ្ឋាន អនាម័យ និងមធ្យោបាយក្នុងការស្វែងរកដំណោះស្រាយ ពេលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។
- បង្កើនការចូលរួមពីសហគមន៍ អង្គការមានមូលដ្ឋាននៅសហគមន៍ គ្រិស្តបរិស័ទ អ្នកស្ម័គ្រចិត្ត និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ឱ្យឃើញពីការរំលោភសិទ្ធិមនុស្ស ជាពិសេសទាក់ទងទៅនឹងបាតុកម្មជម្លោះដី ធ្លី។

- បង្កើនការទុកចិត្តរបស់សាធារណៈជនចំពោះលីកាដូ ជាប្រភពព័ត៌មានទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងករណីរំលោភសិទ្ធិមនុស្សសំខាន់ៗ។ ព័ត៌មានទាំងនេះត្រូវបានស្នើសុំដោយអ្នកបង្កើតគោលនយោបាយ សហគមន៍អន្តរជាតិ ម្ចាស់ជំនួយ និងប្រព័ន្ធផ្សាយព័ត៌មាន។

□□□

# ការិយាល័យសិទ្ធិស្ត្រី

**គោលបំណង**



- ធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិស្ត្រី និងច្បាប់ដែលពាក់ព័ន្ធទៅនឹងការការពារស្ត្រីជាពិសេសក្រុមគោលដៅ ដូចជាស្ត្រីដែលបានជ្រើសរើសនៅក្នុងឃុំ និងអាជ្ញាធរមូលដ្ឋាន ។
- ធ្វើការស៊ើបអង្កេតរាល់ឯកសារដែលពាក់ព័ន្ធហិង្សាលើស្ត្រី ដូចជាអំពើហិង្សាក្នុងគ្រួសារ ការរំលោភ សេពសន្ថវៈ ការបៀតបៀនផ្លូវភេទ និងការជួញដូរមនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ ។
- ផ្តល់ជំនួយផ្នែកផ្លូវច្បាប់ និងជួយដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេដើម្បីដាក់ពាក្យបណ្តឹង ទៅតុលាការ ឬនគរបាល ។
- ផ្តល់ដល់ជនរងគ្រោះ និងក្រុមគ្រួសារគាត់ ដោយផ្តល់សេវាបង្អែកដើម្បីស្វែងរកជំរកស្នាក់នៅ ស្វែងរកអង្គការជំនួយផ្នែកច្បាប់ និងអង្គការក្រៅរដ្ឋាភិបាលដែលជួយផ្នែកស្តារលទ្ធភាពពលកម្ម និងវិជ្ជាជីវៈផ្សេងៗ ។
- ផ្តល់ចំណីអាហារ សម្ភារៈ ថ្នាំពេទ្យ និងការផ្តល់ប្រឹក្សាយោបល់ដល់អ្នកដែលត្រូវការ ។
- លើកកម្ពស់សមភាពរវាងបុរស និងស្ត្រីតាមរយៈការធ្វើយុទ្ធនាការទាក់ទាញមតិគាំទ្រ ។
- ធ្វើការបញ្ចុះបញ្ចូលអ្នកតំណាងរាស្ត្រ ដើម្បីបញ្ចូលបញ្ហាយេនឌ័រចូលទៅក្នុងគោលនយោបាយ និងច្បាប់ជាតិ ។
- ធ្វើការបញ្ចុះបញ្ចូលនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិសម្រាប់ការធ្វើកំណែទំរង់ច្បាប់ និងសង្គម ដើម្បីការពារស្ត្រី ។

**លទ្ធផលសំរេចបាន**

សកម្មភាពជាចំបងរបស់ការិយាល័យសិទ្ធិស្ត្រីគឺ :

- ឃ្លាំមើល និងស៊ើបអង្កេតទៅលើករណីដែលសិទ្ធិស្ត្រីដែលត្រូវគេរំលោភបំពាន
- ធ្វើការអប់រំដល់ស្ត្រី និងអាជ្ញាធរមូលដ្ឋានអំពីសិទ្ធិស្ត្រី និងច្បាប់ផ្សេងៗដែលទាក់ទងនឹងសិទ្ធិស្ត្រីនៅកម្ពុជា
- ផ្តល់ការគាំទ្រ និងផ្តល់ជំនួយដល់បណ្តាញការងារសហគមន៍ និងក្រុមគោលដៅ ដោយផ្តោតលើបញ្ហាស្ត្រី
- ធ្វើការទាក់ទាញមតិគាំទ្រដើម្បីលើកកម្ពស់បុព្វហេតុស្ត្រីកម្ពុជា ។
- ផ្តល់វគ្គហ្វឹកហ្វឺនដល់បុគ្គលិកដើម្បីបង្កើនគុណភាពការងារ ដែលបានរៀបចំធ្វើឡើងដោយការិយាល័យសិទ្ធិស្ត្រី

## សកម្មភាព

## ការឃ្លាំមើល និងការស៊ើបអង្កេត

នៅក្នុងឆ្នាំ២០០៨ អ្នកឃ្លាំមើលការរំលោភសិទ្ធិស្ត្រីនៃការិយាល័យសិទ្ធិស្ត្រីក្រុងភ្នំពេញ និងអ្នកឃ្លាំមើលការរំលោភសិទ្ធិស្ត្រីនៃការិយាល័យលីកាដូតាមបណ្តាខេត្ត ចំនួន១២ បានស៊ើបអង្កេតករណីរំលោភសិទ្ធិស្ត្រី សរុបចំនួន២៣៨ករណី។ នៅក្នុងនោះមានជនរងគ្រោះចំនួន២៣៨នាក់ និងជនល្មើសចំនួន២៥៣នាក់។ ករណីទាំងនោះរួមមានអំពើហិង្សាក្នុងគ្រួសារ ការចាប់រំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ និងការជួញដូរមនុស្ស ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ ក្នុងករណីនៃអំពើហិង្សាទាំងអស់នោះមាន ៦៧ភាគរយ ជាអំពើហិង្សាក្នុងគ្រួសារ។ នៅក្នុង ២៣៨ករណី ក្នុងនោះមានករណីថ្មី ១៧៨ករណី នៅតែដំណើរការបើក និង៦០ករណី ត្រូវបានបិទ។

បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧ ការិយាល័យសិទ្ធិស្ត្រីបានស៊ើបអង្កេតទៅលើ ៣០២ករណី នៃការរំលោភបំពានសិទ្ធិស្ត្រី នៅក្នុងនោះមានជនរងគ្រោះចំនួន៣១២នាក់ និងជនល្មើសចំនួន ៣៣៣នាក់។ មូលហេតុនៃការថយចុះនូវករណីមួយចំនួននៅ ឆ្នាំ២០០៨ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧ ដោយសារតែអង្គការខិតខំប្រឹងប្រែងក្នុងការតាមដាននូវករណីចាស់ៗ និងកង្វះបុគ្គលិកសិទ្ធិស្ត្រី និងអវត្តមានដោយការឈប់សម្រាកមាតុភាព ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់អង្គការ ការកង្វះថវិកាក្នុងការតាមដាន ថ្លៃធ្វើដំណើរ និងការកើនឡើងចំនួនការរំលោភបំពានសិទ្ធិមនុស្ស ដូចជាការរឹបអូសយកដីដែលត្រូវទទួលខុសត្រូវពីបុគ្គលិកឃ្លាំមើល និងបុគ្គលិកពេទ្យ។ សូមមើលសេចក្តីបន្ថែមលើផ្នែក "ឧបសគ្គ"។

ឆ្នាំ២០០៨នេះដែរ ស្ត្រី៨នាក់ បានស្លាប់ដោយសារតែអំពើហិង្សា (អំពើហិង្សានៅក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ) ហើយស្ត្រី៧នាក់ ត្រូវបានគេរាយការណ៍ថា បានរងគ្រោះដោយអំពើរំលោភសេពសន្ថវៈជាក្រុម ព្រមទាំង៣ករណីទៀត ត្រូវបានរងការរំលោភបំពានដោយសាច់ញាតិ (បង/ប្អូនប្រុសថ្លៃ បងប្អូនជីដូនមួយ បង្កើត និងឪពុកមា)។

## ចំនួនករណីរបស់ការិយាល័យសិទ្ធិស្ត្រី ឆ្នាំ២០០៨ ទៅតាមប្រភេទករណី និងខេត្ត

| | PP | KD | KN | PS | BB | BM | KS | KP | SV | KK | KC | KT | SP | SR | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| DV | ៣១ | ១២ | ៤ | ៧ | ៧ | ១៦ | ១៦ | ២២ | ៧ | ៧ | ៨ | ៥ | ៤ | ២២ | ១៦៨ |
| RA | ៣ | ៦ | ៧ | ៦ | ៤ | ១ | ៥ | ៧ | ៣ | ៣ | ៨ | ៦ | | ៨ | ៦៧ |
| IA | | | | | | ១ | | | | | | | | | ១ |
| HTS | | | | | | | | ១ | | ១ | | | | | ២ |
| សរុប | ៣៤ | ១៨ | ១១ | ១៣ | ១១ | ១៨ | ២១ | 30 | ១០ | ១១ | ១៦ | ១១ | ៤ | ៣០ | ២៣៨ |

## ករណីដែលមិនទាន់សម្រេចនៅការិយាល័យសិទ្ធិស្ត្រី ឆ្នាំ២០០៨

| ប្រភេទ | អធិការ | ស្រុក | នគរបាលឃុំ | តុលាការកំពូល | កំពុងដំណើរការនៅតុលាការ | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | | | ករណីបើក រត់គេចខ្លួន | ករណីបើក មិនមាន ដីកាចាប់ខ្លួន | ករណីបើក | |
| DV | ៦ | ១៦ | ១០ | | ៣ | ១០ | ៧១ | ១១៦ |
| RA | ២ | ១ | ៧ | | ៧ | ២៧ | ១៥ | ៥៩ |
| IA | | | ១ | | | | | ១ |
| HTS | ១ | | | | ១ | | | ២ |
| សរុប | ៩ | ១៧ | ១៨ | 0 | ១១ | ៣៧ | ៨៦ | ១៧៨ |

## ករណីនៅការិយាល័យសិទ្ធិស្ត្រីដែលបានបិទ ឆ្នាំ២០០៨

| ល.រ | ប្រភេទ | សវនាការ | លើកលែងចោទប្រកាន់ | សម្របសម្រួលដោយប៉ូលីស | សម្របសម្រួលដោយស្រុក | សម្របសម្រួលដោយតុលាការ | សម្របសម្រួលដោយអធិការ | ដកពាក្យបណ្ដឹង | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | DV | ២ | ១៦ | ២២ | ៦ | ១ | ១ | ៤ | ៥២ |
| ២ | RA | ៣ | ៣ | | ២ | | | | ៨ |
| ៣ | HTS | | | | | | | | |
| សរុប | | ៥ | ១៩ | ២២ | ៨ | ១ | | ៥ | ៦០ |

## សេវាកម្មច្បាប់ និងសេវាកម្មបញ្ជូន

គម្រោងជំនួយផ្នែកច្បាប់របស់អង្គការលីកាដូ បានតំណាងដល់អតិថិជនចំនួន១៤ ក្នុងឆ្នាំ២០០៨។ អតិថិជនទាំងនេះ ត្រូវបានជ្រើសរើសជាអតិភាព និងជាករណីធ្ងន់ធ្ងរបំផុតនៃអំពើហឹង្សាលើស្ត្រី។

អ្នកឃ្លាំមើលការិយាល័យសិទ្ធិស្ត្រី និងអ្នកឃ្លាំមើលតាមបណ្តាខេត្តបានបញ្ជូនអតិថិជន ចំនួន១០នាក់ ទៅអង្គការដៃគូរផ្សេងៗ ក្នុងនោះ ស្ត្រីរងគ្រោះ៤នាក់ ដោយអំពើរំលោភសេពសន្ថវៈ (២ករណី បញ្ជូនទៅអង្គការស្ត្រីមានវិបត្តិ ១ករណី បញ្ជូនទៅអង្គការសេវាសង្គម និង១ករណី ទៀតបញ្ជូនទៅអង្គការហាហ្គា) និងស្ត្រីចំនួន ៥នាក់ រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ (២ករណីបញ្ជូនទៅអង្គការស្ត្រីមានវិបត្តិ ១ករណីបញ្ជូនទៅ Renacer និង១ករណីទៀតបញ្ជូនទៅអង្គការហាហ្គា) និងស្ត្រីម្នាក់ទៀត រងគ្រោះដោយអំពើជួញដូរផ្លូវភេទ ត្រូវបានបញ្ជូនទៅអង្គការហាហ្គា។

## ការផ្តល់ជំនួយជនរងគ្រោះ

ក្នុងកំឡុងពេលធ្វើរបាយការណ៍ ការិយាល័យសិទ្ធិស្ត្រីបានផ្តល់ជំនួយផ្នែកសម្ភារៈ និងថ្លៃធ្វើដំណើរដល់អតិថិជន ៣៥នាក់។ ក្នុងនោះមានអតិថិជន ២២នាក់ ដែលបានរាយការណ៍ថា ជារងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ១២នាក់ រងគ្រោះអំពើរំលោភសេពសន្ថវៈ និងអតិថិជនម្នាក់ទៀតទទួលរងគ្រោះអំពើជួញដូរ។ ជំនួយទាំងនោះរួមមានសម្ភារៈប្រើប្រាស់ដូចជា មុង ទឹកសណ្តែក ទឹកត្រី មី អំបិល ប្រេងឆា ទឹកដោះគោកូនក្មេង អង្ករ ត្រីខកំប៉ុង សាប៊ូ និងថ្លៃស្នាក់នៅ។ ថ្លៃធ្វើដំណើរមានរួមទាំងថ្លៃធ្វើដំណើរត្រលប់ទៅផ្ទះវិញ ថ្លៃថ្នាំពេទ្យ និងធ្វើដំណើរទៅកាន់កន្លែងស្នាក់នៅ។

## បណ្តាញសកម្មភាពសហគមន៍ និងការផ្សព្វផ្សាយ

នៅក្នុងឆ្នាំ២០០៨ ការិយាល័យសិទ្ធិស្ត្រីបានបន្តធ្វើគម្រោងកម្មវិធីសាកល្បងសិទ្ធិស្ត្រី នៅក្នុងសហគមន៍ (គម្រោងសាកល្បង)។ វគ្គហ្វឹកហ្វឺនសិក្ខាសាលាជាផ្លូវការ សម្រាប់ជនបង្គោល (ស្ត្រីសហគមន៍ ដដែលជាគោលដៅសំខាន់បានបង្រៀនទៅលើបញ្ហាសិទ្ធិស្ត្រី) និងអាជ្ញាធរមូលដ្ឋានដែលបានជ្រើសរើសកាលពីឆ្នាំ២០០៧។

ក្នុងឆ្នាំ២០០៨ ជនបង្គោលបានបើកវគ្គចំនួន៣១លើក នៅខេត្តកំពត ស្តីពីការលើកកម្ពស់ការយល់ដឹង និងវគ្គផ្សព្វផ្សាយនៅក្នុងសហគមន៍ពួកគេ ស្តីអំពីហិង្សាប្រឆាំងស្ត្រី ដែលមានអ្នកចូលរួមសរុបចំនួន ២,៤៣១នាក់ ចំណែកនៅខេត្តកំពង់ធំក៏មានបើកវគ្គនេះផងដែរ ដែលមានចំនួន ៣៧លើក និងមានអ្នកចូលរួមសរុបចំនួន ១,៧៥២ នាក់។ វគ្គសិក្សានេះធ្វើឡើងជាវគ្គផ្លូវការ និងមិនផ្លូវការ ហើយវគ្គសិក្សាមិនផ្លូវការ មានទាំងការជួបប្រជុំជាមួយ

មនុស្សនៅទីផ្សារ ការពិភាក្សាអំពីហិង្សាប្រឆាំងស្ត្រីកំឡុងពេលអាហារ និងការសន្ទនា រវាងអ្នកជិតខាង មិត្តភក្តិ និងគ្រួសារ។ ចំណែកវគ្គសិក្សាផ្លូវការវិញ រៀបចំដោយក្រុមជនបង្គោលដោយបានអញ្ជើញសមាជិកសហគមន៍ និង អាជ្ញាធរមូលដ្ឋានឱ្យចូលរួមក្នុងវគ្គសិក្សានេះ។

ពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០០៨ ជនបង្គោលបានផ្សព្វផ្សាយចំណេះដឹងរបស់ពួកគេទាំងការអប់រំផ្លូវការ និងការអប់រំមិនផ្លូវការទៅដល់ប្រជាជននៅក្នុងភូមិ អំពីអំពើហិង្សាលើស្ត្រីដែលមានអ្នកចូលរួម ៤,៥៩៤ នាក់ នៅខេត្តកំពត និង១,៤៦០នាក់ នៅខេត្តកំពង់ធំ។

## វេទិកាសហគមន៍

នៅក្នុងខេត្តកំពត នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ និងនៅក្នុងខេត្តកំពង់ធំ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ អង្គការលីកាដូបានរៀបចំកម្មវិធីវេទិកាសហគមន៍ ដើម្បីកំនត់នូវសេចក្តីសន្និដ្ឋាន អំពីសកម្មភាពគម្រោងសាកល្បង នៅក្នុងខេត្តទាំងពីរនេះ ហើយវេទិកានិមួយៗមានអ្នកចូលរួមប្រហែល ៧៥ នាក់។

គោលបំណងនៃវេទិកាសហគមន៍នេះ គឺដើម្បីបង្ហាញនូវកែតំរូវពីអ្នកចូលរួមក្នុងវគ្គហ្វឹកហ្វឺន និងគម្រោងសាកល្បង។ លទ្ធផលនៃគម្រោងសាកល្បង បានបង្ហាញដោយអ្នកចូលរួមតាមរយៈការសំដែងរឿង ខ្លីនៅលើឆាក ដែលការសំដែងនេះមានលក្ខណៈប្រហាក់ប្រហែលនឹងការសំដែងនៅខេត្តកណ្តាលដែរ។

## វគ្គបណ្តុះបណ្តាលសម្រាប់ជនបង្គោល

ស្ត្រីចំនួន៣៧នាក់ នៅក្នុងខេត្តកំពត និង ៣៥នាក់ទៀត នៅក្នុងខេត្តកំពង់ធំ បានទទួលការបណ្តុះបណ្តាល ដើម្បីក្លាយជាក្រុមជនបង្គោលសម្រាប់គម្រោងសាកល្បងសិទ្ធិស្ត្រី នៅក្នុងឆ្នាំ២០០៧ កន្លងទៅនេះ។ កំឡុង ឆ្នាំ២០០៨ នេះ មានការតាមដានវគ្គបណ្តុះបណ្តាលទាំងនេះ នៅក្នុងរយៈ១ថ្ងៃ ដែលមានចំនួន៦ដង ត្រូវបានធ្វើ ឡើងតាមខេត្តនិមួយៗ។ គោលបំណងនៃវគ្គនេះ គឺដើម្បីតាមដាន នូវសំនួរ ឬបញ្ហា ដើម្បីពង្រឹងបញ្ហាទាំងនោះ ដោយធ្វើការបង្រៀននៅក្នុងវគ្គហ្វឹកហ្វឺនដំបូង និងដើម្បីផ្តល់ការគាំទ្រជនបង្គោល ក្នុងការលើកកម្ពស់នូវការយល់ ដឹងនៅក្នុងសហគមន៍របស់ពួកគេ ការឃ្លាំមើលក្នុងសហគមន៍ និងសកម្មភាពទាក់ទាញមតិគាំទ្រ ទៅលើអំពើហិង្សា ក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរផ្លូវភេទ។



## វគ្គបណ្តុះបណ្តាលសម្រាប់អាជ្ញាធរមូលដ្ឋាន

នៅក្នុងឆ្នាំ២០០៧ មានអាជ្ញាធរមូលដ្ឋានចំនួន២៥នាក់ ដែលមកពី ខេត្តកំពត (២៣នាក់ ជាបុរស និងស្ត្រីមាន២នាក់) និងមានអាជ្ញាធរមូលដ្ឋាន

ចំនួន២២នាក់ ដែលមកពីខេត្តកំពង់ធំ (២០នាក់ ជាបុរស និង២នាក់ ទៀតជាស្ត្រី) បានទទួលការបណ្តុះបណ្តាលស្តីពីការអនុវត្តន៍ច្បាប់ ដើម្បីជួយជន រងគ្រោះដោយអំពើហិង្សា ក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរមនុស្សក្នុងគោលបំណងរកស៊ីផ្លូវភេទ។

ក្នុងឆ្នាំ២០០៨ ការតាមដានការប្រជុំត្រូវបានរៀបចំឡើង ជាមួយអាជ្ញាធរដែនដី ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល (ការប្រជុំ៧ដង) និងជាមួយអាជ្ញាធរដែនដី ដែលមិនបានចូលរួមវគ្គបណ្តុះបណ្តាល (ការប្រជុំ២ដង) ដើម្បីពិភាក្សាលើគម្រោងសាកល្បង និងរៀបចំផែនការក្នុងការសហការណ៍ រវាងក្រុមគោលដៅ និងអាជ្ញាធរដែន-ដី ស្តីពីករណីអំពើហិង្សាលើស្ត្រី។

## សម្ភារៈសម្រាប់ការទាក់ទាញមតិគាំទ្រ

នៅឆ្នាំ២០០៨ ការិយាល័យសិទ្ធិស្ត្រី(ដោយមានការជំនួយពីសមាជិកនៃការិយាល័យធនធានឯកសារ និងទាក់ទាញមតិគាំទ្ររបស់អង្គការលីកាដូ) បានរៀបចំ និងបង្កើតសៀវភៅរឿងរូបភាព ព្រមទាំងចែកចាយអស់ចំនួន៧១១ក្បាល ដែលមានចំណងជើងថា "ស្រមោលអន្ធកាល" ។

គោលបំណងនៃការបង្កើតសៀវភៅនេះ គឺដើម្បីពិភាក្សាលើបញ្ហាហិង្សាលើគ្រួសារ និងផលប៉ះពាល់លើខ្សែជីវិតរបស់គ្រួសារមួយនៅក្នុងប្រទេសកម្ពុជា ដែលនាំឱ្យមានអំពើរំលោភសេពសន្ថវៈ ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ការស្លាប់ និងការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ សៀវភៅនេះរៀបចំឡើងជាលក្ខណៈសៀវភៅរូបភាពក្នុងគោលបំណងដើម្បីផ្តល់ឱ្យសមាជិកសហគមន៍ដែលមិនចេះអក្សរងាយយល់។ សៀវភៅរឿងនេះ បានបោះពុម្ពក្នុងខែមិថុនា ឆ្នាំ២០០៨ ហើយបានចែកចាយដល់ជនបង្គោល អាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលនៅក្នុងសហគមន៍។

## យុទ្ធនាការទាក់ទាញមតិគាំទ្រ



### *យុទ្ធនាការ១៦ថ្ងៃ ប្រឆាំងនឹងអំពើហិង្សា*

លីកាដូ បានផ្តល់ជំនួយដល់ស្ត្រីដែលក្រុមគោលដៅរបស់គម្រោងសាកល្បង ដើម្បីរៀបចំទស្សនកិច្ចផ្ទាល់ ក្នុងកំឡុងពេលយុទ្ធនាការ១៦ថ្ងៃ នៅខេត្តកណ្តាល (៦ភូមិ) ខេត្តកំពត (៨ភូមិ) និងខេត្តកំពង់ធំ (៨ភូមិ)។ គោលបំណងនៃសកម្មភាពនេះ គឺដើម្បីជួបជាមួយ អ្នកភូមិ និងជនរងគ្រោះដោយអំពើហិង្សា នៅតាមតំបន់គោលដៅ ព្រមទាំងជួយជាមួយអាជ្ញាធរដែនដី ដើម្បីពិភាក្សាលើស្ថានភាពអំពើហិង្សាផងដែរ។ អ្នកចូលរួមទាំងអស់ បានពាក់បូណិស និង

បានទទួលព័ត៌មានស្តីពីយុទ្ធនាការ១៦ថ្ងៃ ព្រមទាំងសៀវភៅរឿងរូបភាពផងដែរ។ ផ្ទាំងបដាដែលទាក់ទងនឹងការការពារស្ត្រី ក៏ត្រូវបានបង្ហាញ និងចងតាមដងផ្លូវសំខាន់ៗជាច្រើន តាមសាលា និងឃុំនានា។

**គណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW) និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ស្តីពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO CEDAW)**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធាននៃអង្គការលីកាដូ នៅតែជាប្រធានដឹកនាំគណៈកម្មាធិការស្ត្រីកម្ពុជា (អង្គការចំរុះដែលមានសមាជិក៣៦ ដើម្បីធ្វើការលើកកំពស់បុព្វហេតុស្ត្រីនៅក្នុងប្រទេសកម្ពុជា) និងនៅក្នុងខែឧសភា ឆ្នាំ២០០៨នេះ លោកស្រីក៏ត្រូវបានគេបោះឆ្នោតជាប្រធាន នៃ NGO CEDAW (អង្គការចំរុះដែលមានសមាជិក៦៨ ដើម្បីធ្វើការស៊ើបអង្កេតក្នុងការអនុវត្តនៃ អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅក្នុងប្រទេសកម្ពុជា )។ ការិយាល័យសិទ្ធិស្ត្រី បានជួយដល់គណៈកម្មាធិការស្ត្រីកម្ពុជា និង NGO CEDAW ជាច្រើននៅក្នុងសកម្មភាព ក្នុងឆ្នាំ២០០៨។

**កិច្ចប្រជុំរបស់អង្គការចម្រុះ និងព្រឹត្តការណ៍ទាក់ទាញមតិគាំទ្រ ដែលទាក់ទងនឹងសិទ្ធិស្ត្រី ឆ្នាំ២០០៨**

| ល.រ | កាលបរិច្ឆេទ | ប្រធានបទ | រៀបចំដោយ | ទីកន្លែង |
|---|---|---|---|---|
| ១ | ថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៨ | សមាជិកគណៈកម្មាធិការស្ត្រីកម្ពុជាបានរៀបចំទិវានារីអន្តរជាតិខួបទី ៩៨ | គណៈកម្មាធិការស្ត្រីកម្ពុជា | ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល |
| ២ | ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាសហការជាមួយអង្គការលីកាដូចុះចែកសម្ភារៈមួយចំនួន ដល់ស្ត្រី និងកុមារ។ | គណៈកម្មាធិការស្ត្រីកម្ពុជា និងអង្គការលីកាដូ | ពន្ធនាគារប៉េហ្ស៊ី និង ពន្ធនាគារតាខ្មៅ |
| ៣ | ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាបានរៀបចំកិច្ចប្រជុំដែលស្តីអំពីសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃដើម្បីផ្អាកការផ្តល់សិទ្ធិដល់ ស្ត្រីខ្មែររៀបការជាមួយជនបរទេស | គណៈកម្មាធិការស្ត្រីកម្ពុជា | ការិយាល័យលីកាដូ |
| ៤ | ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាសហការជាមួយ អង្គការលីកាដូចុះចែកសម្ភារៈដល់កុមារនៅ ក្នុងពន្ធគារ | គណៈកម្មាធិការស្ត្រីកម្ពុជានិងអង្គការលីកាដូ | មណ្ឌលអប់រំកែប្រែទី២ និង ពន្ធនាគារតាខ្មៅ |
| ៥ | ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាសហការជាមួយ លោកស្រី Silk Studziusky និង បណ្ឌិត. Setheci Andreas បានរៀបចំការបង្ហាញមួយស្តីពីស្ត្រី ដែលរងគ្រោះដោយអំពើហិង្សានៅក្នុងសម័យប៉ុលពត | គណៈកម្មាធិការស្ត្រីកម្ពុជា | ការិយាល័យលីកាដូ |

| | | | | |
|---|---|---|---|---|
| ៦ | ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាសហការជាមួយ លោកស្រី Silk Studziusky និង បណ្ឌិត Setheci Andreas បានរៀបចំកិច្ចប្រជុំមួយ ដើម្បីពិភាក្សាស្តីពីការជួយស្ត្រី ដែលរងគ្រោះដោយអំពើហិង្សានៅក្នុងសម័យប៉ុលពត | គណៈកម្មាធិការស្ត្រីកម្ពុជា | ការិយាល័យលីកាដូ |
| ៧ | ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ | គណៈកម្មាធិការស្ត្រីកម្ពុជាសហការជាមួយ លោកស្រី Silk Studziusky និង បណ្ឌិត Setheci Andreas បានរៀបចំសន្និសីទកាសែត ស្តីពីអំពើហិង្សានៅក្នុងសម័យប៉ុលពត | គណៈកម្មាធិការស្ត្រីកម្ពុជា | ការិយាល័យលីកាដូ |
| ៨ | ខែមករា ដល់ ខែធ្នូ | កម្មវិធីវិទ្យុ ស្តីអំពីហិង្សាក្នុងគ្រួសារ មានចំនួន ២៦លើក | គណៈកម្មាធិការស្ត្រីកម្ពុជា និង NGO CEDAW | វិទ្យុសំបុកឃ្មុំ FM 105 MHz |

## ទិវានារីអន្តរជាតិ

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៨ មានការសំដែងសិល្បៈជាសាធារណៈមួយដែលបានរៀបចំឡើងដោយអង្គការលីកាដូ ក្រោមជំនួយឧបត្ថម្ភដោយអង្គការ MCC និងអង្គការស្ពានសន្តិភាព ដើម្បីអបអរទិវានារីអន្តរជាតិ ។ ក្នុងនោះ មានមនុស្សជាងមួយពាន់នាក់ចូលរួមនៅឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ហើយនៅក្នុងចំណោមពួកគេមានអ្នកតំណាងជាច្រើននាក់មកពីអង្គការដែលជាសមាជិករបស់គណៈកម្មាធិការស្ត្រីកម្ពុជា ផងដែរ ។

ក្នុងកំឡុងពេលបង្ហាញភាពយន្តល្បីៗ មានការសំដែងសិល្បៈដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើការអប់រំព័ត៌មានអំពីការធ្វើជំនួញ ។ វាក៏ផ្តោតទៅលើការទទួលខុសត្រូវ របស់សមាជិកទាំងអស់នៅក្នុងសហគមន៍ និងជាពិសេស អាជ្ញាធរដែនដី ដើម្បីធ្វើការកាត់បន្ថយអំពើហិង្សាលើស្ត្រីភេទ គឺសំខាន់អំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអនុវត្តនូវច្បាប់អំពើហិង្សាក្នុងគ្រួសារ ។

នៅថ្ងៃសៅរ៍ទី៨ ខែមីនា ឆ្នាំ២០០៨ អង្គការលីកាដូ និងអង្គការដៃគូផ្សេងទៀត បានប្រារព្ធទិវានារីអន្តរជាតិ ដោយបានចែកចំណីអាហារ ភេសជ្ជៈ សំលៀកបំពាក់ និងសម្ភារៈមួយចំនួនដល់ស្ត្រី និងកុមារនៅក្នុងពន្ធនាគារ និងឆ្នាំគុកជាស្ត្រីនៅបណ្តា ២០ពន្ធនាគារ នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនោះមានការសំដែងឈុតឆាកកំប្លែងដោយអ្នកកំប្លែង និងអ្នកតន្ត្រីករ នៅក្នុងពន្ធនាគារពីរក្នុងទីក្រុងភ្នំពេញ ។




ក្នុងថ្ងៃទិវានារីអន្តរជាតិនេះអង្គការលីកាដូបានចេញនូវរបាយការណ៍ចុងក្រោយបំផុតអំពីលក្ខខណ្ឌ នៅក្នុងពន្ធនាគារ មានចំណងជើងថា " រឿង និទានម្តាយ និងកូនស្រីម្នាក់ " ។ របាយការណ៍នេះនិយាយអំពីរឿងរ៉ាវរបស់ម្តាយ និងកូនរស់នៅក្នុងពន្ធនាគារអស់ជាច្រើនឆ្នាំ

ហើយរបាយការណ៍នេះបានលាតត្រដាងនូវជីវិតពិតដ៏សែន លំបាកនៅក្នុងពន្ធនាគារប្រទេសកម្ពុជា ដែលជាកន្លែងក៏រិតនូវរាល់ការទទួលបានចំណីអាហារ ទឹកស្អាត បន្ទប់ ចង្កៀត និងការមិនទទួលបានសេវាថែទាំសុខភាពដែលមានគុណភាព និងទទួលរងនូវហិង្សាពីសំណាក់ឆ្មាំគុក និងអ្នកទោស ផ្សេងទៀត។

## ការកសាងសមត្ថភាពបុគ្គលិក

### បុគ្គលិកការិយាល័យសិទ្ធិស្ត្រី ដែលបានចូលរួមវគ្គសិក្ខាសាលាបណ្តុះបណ្តាល ឆ្នាំ២០០៨

| ឈ្មោះ | កាលបរិច្ឆេទ | ប្រធានបទ | រៀបចំដោយ |
|---|---|---|---|
| កើត មាឃភក្ត្រា | ថ្ងៃទី២៣-២៥ ខែមករា ឆ្នាំ២០០៨ | ក្រមច្បាប់ព្រហ្មទណ្ឌ | លីកាដូ (ការិយាល័យស៊ើបអង្កេត) |
| កើត មាឃភក្ត្រា<br>ឆេង សុខឡៃ<br>ជឹម ចាន់នាង | ថ្ងៃទី១០ ខែមករា ដល់ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៨ | វគ្គភាសាអង់គ្លេស នៅមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការអប់រំ ក៏រិត២ និងក៏រិត៩ A-B | លីកាដូ |
| កើត មាឃភក្ត្រា<br>ប៊ុន សៅរ៉ា | ថ្ងៃទី៤-៨ ខែកុម្ភៈ ឆ្នាំ២០០៨ | ជំនាញបច្ចេកទេសក្នុងការស៊ើបអង្កេត សម្រាប់ករណីសិទ្ធិកុមារ | លីកាដូ (ការិយាល័យសិទ្ធិកុមារ) |
| សរ បុប្ផ | ថ្ងៃទី៦-៨ ខែឧសភា ឆ្នាំ២០០៨ | វគ្គបណ្តុះបណ្តាលស្តីពី យេនឌ័រ | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| សរ បុប្ផ<br>លឹម អ៊ី | ថ្ងៃទី២៤-២៦ ខែកញ្ញា ឆ្នាំ២០០៨ | ឥទ្ធិពលនៃយេនឌ័រ | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| ជឹម ចាន់នាង | ថ្ងៃទី២៦-២៨ ខែមីនា ឆ្នាំ២០០៨<br>ថ្ងៃទី៤-៨ ខែសីហា ឆ្នាំ២០០៨<br>ថ្ងៃទី១៥-១៩ ខែកញ្ញា ឆ្នាំ២០០៨ | RBA | ជំនួយសង្គ្រោះព្រះវិហារដាណាម៉ាក |
| ឆេង សុខឡៃ | ថ្ងៃទី៣-៥ ខែកញ្ញា ឆ្នាំ២០០៨ | ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ | លីកាដូ (ការិយាល័យស៊ើបអង្កេត) |
| កើត មាឃភក្ត្រា<br>ប៊ុន សៅរ៉ា | ថ្ងៃទី១០-១២ ខែកញ្ញា ឆ្នាំ២០០៨ | ក្រមរដ្ឋប្បវេណី ( ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ) | លីកាដូ (ការិយាល័យស៊ើបអង្កេត) |
| ជឹម ចាន់នាង<br>ឆេង សុខឡៃ<br>ប៊ុន សៅរ៉ា | ថ្ងៃទី២-៣ ខែតុលា ឆ្នាំ២០០៨ | ច្បាប់ជួញដូរមនុស្ស | ជំនួយសង្គ្រោះព្រះវិហារដាណាម៉ាក |

(៤៨) របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់អង្គការលីកាដូ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨

| | | | |
|---|---|---|---|
| សរ បុប្ផ<br>សេត វណ្ណៈ<br>លឹម អ៊ី<br>យិវ ស៊ូរ័ក្យ | ថ្ងៃទី២-៣ ខែតុលា ឆ្នាំ២០០៨ | ជំនាញទំនាក់ទំនង | លីកាដូ |
| សរ បុប្ផ<br>កើត មាឃភក្រ្តា | ថ្ងៃទី១៧-១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ | ក្រមរដ្ឋប្បវេណី ស្តីពីការលែងលះ និងការរៀបអាពាហ៍ពិពាហ៍ | អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| សរ បុប្ផ<br>សេត វណ្ណៈ<br>លឹម អ៊ី<br>ប៊ិន បុប្ផជាតិ<br>ឆេង សុខឡៃ<br>កើត មាឃភក្រ្តា<br>ប៊ុន សៅរ៉ា | ថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ | ក្រមច្បាប់រដ្ឋប្បវេណី ស្តីពីការបែងចែកកេរ្តិ៍មរតក និងទ្រព្យសម្បត្តិគ្រួសារ | លីកាដូ |
| ជឹម ចាន់នានង | ខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០០៨ (៣សប្តាហ៍) | ការគ្រប់គ្រង អង្គការក្រៅរដ្ឋាភិបាល | វិទ្យាស្ថានគ្រប់គ្រង-បូព៌ាបច្ចិម |
| ឆេង សុខឡៃ | ថ្ងៃទី២២-២៦ ខែធ្នូ ឆ្នាំ២០០៨ | ការស៊ើបអង្កេតលើករណីជួញដូរមនុស្ស | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា |

**ឥទ្ធិពល**

- ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេមានភាពប្រសើរក្នុងការផ្សព្វផ្សាយសិទ្ធិរបស់ពួកគេ ហើយពួកគេមានការជឿជាក់ក្នុងការសំរេចចិត្តចំពោះការដោះស្រាយតាមផ្លូវច្បាប់។
- សហគមន៍ដែលបានជ្រើសរើស និងស្ត្រីបង្គោលនៅក្នុងសហគមន៍ បានទទួលព័ត៌មានទាក់ទងនឹងសិទ្ធិស្ត្រី និងបានដឹងនូវវិធីសាស្រ្តជាមូលដ្ឋានដើម្បីការពារស្ត្រី។
- ប្រជាពលរដ្ឋមានការយល់ដឹងច្រើនអំពីសិទ្ធិស្ត្រី និងហិង្សាដែលប្រព្រឹត្តឡើងប្រឆាំងស្ត្រី និងនារីទូទៅ តាមរយៈវិទ្យុ និងប្រព័ន្ធផ្សាយព័ត៌មានផ្សេងទៀត ដែលធ្វីឱ្យស្ត្រីអាចលើកឡើងអំពី ចំនុចច្បាប់សំខាន់ៗ ដល់អ្នកបង្កើតច្បាប់ និងសាធារណៈជនឱ្យបានដឹង។

- អង្គការក្រៅរដ្ឋាភិបាល និងសមាជិកផ្សេងទៀតនៃសង្គមស៊ីវិលអាចធ្វើការទាក់ទាញមតិ គាំទ្រទៅលើច្បាប់ចំបង និងការកែទម្រង់សង្គមឡើងវិញទាក់ទាក់ទងទៅនឹងស្ត្រី និងនារីទូទៅ ។
- អាជ្ញាធរក៏ទទួលបាននូវចំណេះដឹង និងយល់ពីការអនុវត្តន៏តួនាទីរបស់ខ្លួនក្នុងការការពារសិទ្ធិស្ត្រីក្រោមច្បាប់នៃប្រទេសកម្ពុជា ។
- អ្នកដឹកនាំសហគមន៏ដែលជាស្ត្រី ត្រូវបានផ្តល់ជាចំណេះដឹង និងឧបករណ៍ឧបទ្ទេស ដើម្បីជាការគាំទ្រគ្រួសារ និងសហគមន៏របស់ពួកគាត់ ឱ្យបានកាន់តែប្រសើរឡើង ។

□□□

# ការិយាល័យសិទ្ធិកុមារ

**គោលបំណង**



- កំណត់នូវការរំលោភបំពានសិទ្ធិកុមារ និងថែរក្សានូវចំណេះដឹងជាធំអំពីស្ថានភាពសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។
- ផ្តល់នូវសម្ភារៈជំនួយ ការពារ និងផ្តល់នូវការគាំទ្រយ៉ាងពិសេស រួមមានតំណាងផ្នែកច្បាប់ដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ ជាពិសេសគឺជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ មនុស្សឃាត និងបង្ករបួសស្នាម
- ផ្តួចផ្តើមគំនិត និងសហការជាមួយអង្គការដៃគូ និងសមាជិកសហគមន៍ ដើម្បីផ្សព្វផ្សាយសិទ្ធិកុមារក្នុងគោលបំណងដើម្បីទទួលបានលទ្ធផលរួមជាអតិបរមា។
- ជួយសម្របសម្រួលគណៈកម្មការជាតិដើម្បីកុមារកម្ពុជាឆ្ពោះទៅរកយុទ្ធសាស្ត្រដែលមានស្ថេរភាពឱ្យលើសពីព្រឹត្តិការណ៍គ្រោងទុកដើម្បីដោះស្រាយបញ្ហាសង្គមចំបងៗ និងប្រធានបទជាច្រើនដូចជា ទេសចរផ្លូវភេទ និងវប្បធម៌ក្នុងស្រុកដែលនាំឱ្យបញ្ហាទាំងនេះនៅតែមាន។
- ប្រឆាំងនឹងការរំលោភបំពានពលកម្មកុមារតាមរយៈការពារ និងកាត់បន្ថយការចូលរួមរបស់កុមារនៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដោយបង្កើននូវការយល់ដឹង និងចាត់វិធានការដោះស្រាយបញ្ហាដែលកើតមានឡើង។
- បញ្ចុះបញ្ចូល និងលើកយកបញ្ហាសំខាន់ៗដែលទាក់ទងនឹងសិទ្ធិកុមារ និងទំរង់អាក្រក់បំផុតនៃពលកម្មកុមារដល់ក្រុមគោលដៅ។

**លទ្ធផលសំរេចបាន**

សម្មភាពចំបងៗរបស់ការិយាល័យសិទ្ធិកុមារគឺ:

- ស៊ើបអង្កេត និងផ្តល់ជំនួយដល់ជនរងគ្រោះ
- រៀបចំកម្មវិធីបណ្តុះបណ្តាល
- បង្កើត និងថែរក្សាក្រុមការពារកុមារ និងក្រុមសិស្ស
- រៀបចំសកម្មភាពទាក់ទាញមតិគាំទ្រ និងរៀបចំយុទ្ធនាការ

## ការឃ្លាំមើល និងស្រាវជ្រាវ

អ្នកឃ្លាំមើលនៃការិយាល័យសិទ្ធិកុមារនៅខេត្ត-ក្រុង បានបន្តសកម្មភាពរបស់ពួកគេក្នុងការផ្តល់ជំនួយផ្នែកច្បាប់ និងតម្រូវការចាំបាច់ផ្សេងៗដល់កុមារ និងគ្រួសារកុមារ ដែលជាជនរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ច។ សកម្មភាពទាំងនោះធ្វើឡើងនៅក្នុង ខេត្ត-ក្រុងទាំង១៣ និងក្នុងរាជធានីភ្នំពេញ។

កំឡុងឆ្នាំ២០០៨ ក្រុមអ្នកឃ្លាំមើលបានទទួលករណីថ្មី និងធ្វើការស្រាវជ្រាវបាន ២២៧ ករណី ដែលមានជនរងគ្រោះចំនួន ២៤៤ នាក់ (២៣២ នាក់ ជាកុមារី និង ១២ នាក់ ជាកុមារា) និងជនប្រព្រឹត្តល្មើសចំនួន ២៧២នាក់។ ករណីរំលោភសេពសន្ថវៈដែលបានរាយការណ៍មានចំនួនដល់ទៅ ៦៤ ភាគរយ នៃចំនួនករណីសរុប។

បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ការិយាល័យសិទ្ធិកុមារ ស្រាវជ្រាវបានករណីរំលោភលើសិទ្ធិកុមារបានចំនួន ២៨៤ករណី។ ក្នុងចំណោមករណីទាំងនោះ មានជនរងគ្រោះចំនួន ៣០៤ នាក់ និងជនល្មើសចំនួន ៣៣៧ នាក់។ ការថយចុះករណីដែលបានរាយការណ៍ចាប់ពីឆ្នាំ២០០៨ ទៅ ឆ្នាំ២០០៧ ដោយសារតែអ្នកឃ្លាំមើលខិតខំធ្វើការតាមដានលើករណីចាស់ៗកន្លងមក ដែលមានរយៈពេលយូរ ហើយករណីទាំងនោះមានលក្ខណៈស្មុកស្មាញ ពាក់ព័ន្ធនឹងកុមារ និងក្រុមគ្រួសារកុមារ និងការខិតខំផ្តល់សេវាជំនួយដល់កុមាររងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ និងដោយសារតែកង្វះខាតបុគ្គលិកឃ្លាំមើលនៃការិយាល័យសិទ្ធិកុមារ។

## ករណីរំលោភសិទ្ធិកុមារដែលទទួលបាន ឆ្នាំ២០០៨




| | |
|---|---|
| RA = រំលោភសេពសន្ថវៈ / ប៉ុនប៉ងរំលោភសេពសន្ថវៈ | T = ទារុណកម្ម |
| IA = បៀតបៀនកេរ្តិ៍ខ្មាស់ | PA = បង្ករបួសស្នាម |
| K = សម្លាប់ | IAD = ការចាប់ និងឃុំខ្លួនខុសច្បាប់ |
| HTS = ការជួញដូរមនុស្ស-ការជួញដូរភេទ | ED = ការបាត់ខ្លួន |
| HTL = ការជួញដូរមនុស្សដើម្បីពលកម្ម | CDV = ហិង្សាលើកុមារបំរើតាមផ្ទះ |
| HTA = ការជួញដូរមនុស្ស-កូនចិញ្ចឹម | SC = ករណីផ្សេងៗ / ករណីពិសេស |

## កំរិតអាយុរបស់ជនរងគ្រោះ

| កំរិតអាយុ ( ឆ្នាំ) | ករណី | ចំនួន | | |
|---|---|---|---|---|
| | | កុមារា | កុមារី | សរុប |
| ០-៥ | ២២ | ១៩ | ៣ | **២២** |
| ៦-៩ | ៣៦ | ៣៦ | ០ | **៣៦** |
| ១០-១២ | ៣៨ | ៣៥ | ៥ | **៤០** |
| ១៣-១៥ | ៨៨ | ៩១ | ១ | **៩២** |
| ១៦-១៧ | ៤៣ | ៥១ | ៣ | **៥៤** |
| **សរុប** | **២២៧** | **២៣២** | **១២** | **២៤៤** |

## កំរិតអាយុជនល្មើស

| កំរិអាយុ ( ឆ្នាំ) | ករណី | ចំនួន | | |
|---|---|---|---|---|
| | | បុរស | ស្ត្រី | សរុប |
| ១៤-១៥ | ១២ | ០ | ៩ | **៩** |
| ១៦-១៨ | ២២ | ០ | ២២ | **២២** |
| ១៩-២៥ | ៦៣ | ៤ | ៩២ | **៩៦** |
| ២៦-៤៥ | ១០២ | ១៥ | ១០២ | **១១៧** |
| លើពី ៤៦ | ២៨ | ៣ | ២៥ | **២៨** |
| **សរុប** | **២២៧** | **២២** | **២៥០** | **២៧២** |

## ករណីថ្មី និងករណីចាស់ដែលបានបិទ

| **ករណីបិទដោយ** | **ចំនួនករណី** |
|---|---|
| តាមគតិយុត្តិ / ធ្វើសវនាការ ( ជនល្មើសត្រូវកាត់ទោស / លើកលែងចោទប្រកាន់) | ១៨ |
| គ្មានចំណាត់ការច្បាប់/បង់ប្រាក់ជម្ងឺចិត្ត រៀបការ ឬព្រមព្រៀង | ២៨ |
| គ្មានចំណាត់ការពីតុលាការ ( គ្មានការចោទប្រកាន់ ដកពាក្យបណ្តឹង ស្លាប់) | ០ |
| ចំណាត់ការដោយលីកាដូ ( ជនរងគ្រោះដកពាក្យបណ្តឹង ឬផ្សេងៗ | ១៦ |
| **សរុប** | **៦២** |

## ការអន្តរាគមន៍ និងជំនួយផ្នែកច្បាប់

**ការអន្តរាគមន៍ និងជំនួយកំឡុងស្រាវជ្រាវករណី**

| ប្រភេទ | ករណី |
|---|---|
| នគរបាល / អាជ្ញាធរដែនដី | ៧២ |
| តុលាការ | ១២៦ |
| តំណាងផ្នែកច្បាប់របស់អង្គការក្រៅរដ្ឋាភិបាល | ៤ |
| **សរុប** | **២០២** |

**ករណីបញ្ជូនសំរាប់សេវាផ្នែកច្បាប់**

| ភ្នាក់ងារ / អង្គការក្រៅរដ្ឋាភិបាល | ករណី |
|---|---|
| អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) | ១៣ |
| អង្គការការពារយុត្តិធមិកុមារ (PJJ) | ១០ |
| អង្គការជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ | ៦ |
| អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) | ៤ |
| ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) | ១ |
| អង្គការ Action Pour Les Enfant (APLE) | ១ |
| **សរុប** | **៣៥** |

## សេវាសង្គម និងជំនួយសម្ភារៈ

ជំនួយផ្តល់ជូនបាន ២២០ ករណី មានកុមារចំនួន ៣៩៣ នាក់ (២០៩ ជាកុមារី និង១៨៤ ជាកុមារា)។ ភាគច្រើននៃកុមារទាំងនោះជាកុមាររងាយរងគ្រោះ ហើយកុមារទាំងនោះនៅតែជាជនរងគ្រោះនៃករណីដែលទទួលបាន។ មានកុមារចំនួន ៧៥ នាក់ បានទទួលជំនួយសម្ភារៈ នៅថ្ងៃប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិ។ ជំនួយដែលផ្តល់ឱ្យរួមបញ្ចូលទាំងការជួសជុលផ្ទះដែលធ្វើដោយសមាជិកក្រុមការពារកុមារ ផ្តល់សម្ភារៈសិក្សា លិខិតពេទ្យសំរាប់ប្រើប្រាស់ក្នុងផ្លូវច្បាប់ ទឹកដោះគោសម្រាប់ទារក ថ្លៃធ្វើដំណើរទៅសាលារៀន ទៅមន្ទីរពេទ្យ និងការផ្តល់ប្រឹក្សាយោបល់។

## សកម្មភាពហ្វឹកហ្វឺន

### សិក្ខាសាលាហ្វឹកហ្វឺន

វគ្គសិក្ខាសាលាតាមបែបចូលរួមដែលមានរយៈពេល២ថ្ងៃ មានអ្នកចូលរួមសរុបចំនួន ៧៣៧នាក់ ( ៣៣២ នាក់ជាស្ត្រី) ត្រូវបានរៀបចំឡើងនៅក្នុងតំបន់គម្រោងដោយអ្នកទាក់ទាញមតិគាំទ្រក្រោមការគាំទ្រពីអ្នកទាក់ទាញមតិគាំទ្រថ្នាក់ខ្ពស់នៅភ្នំពេញ។ គោលបំណងរបស់សិក្ខាសាលាហ្វឹកហ្វឺននេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងសិទ្ធិកុមារ ការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបញ្ហាសិទ្ធិកុមារផ្សេងៗទៀតនៅតំបន់និមួយៗ ក្នុងចំណោមឪពុកម្តាយកុមារដែលធ្វើការ គ្រូបង្រៀន កុមាររងាយរងគ្រោះ និងគ្រោះថ្នាក់របស់កុមារនៅក្នុងខេត្តចំនួន៥ នៃតំបន់គម្រោង។ ក្នុងវគ្គហ្វឹកហ្វឺននីមួយៗ មានអ្នកចូលរួមសរុប ២៥នាក់។



**ចំនួនវគ្គហ្វឹកហ្វឺនសិក្ខាសាលា និងចំនួនអ្នកចូលរួមដែលបែងចែកតាមតំបន់គម្រោង**

| ទីកន្លែង | ចំនួនអ្នកចូលរួម | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | LA | | | VC/VAC | | | PWC/SoE | | | T | | | S | | | សរុប | | |
| | # | ស | ប | # | ស | ប | # | ស | ប | # | ស | ប | # | ស | ប | # | ស | ប |
| កំពង់ចាម | ២ | ៧ | ៤៣ | ២ | ៣១ | ១៩ | ០ | ០ | ០ | ១ | ១១ | ១៤ | ១ | ១១ | ១៤ | ៦ | ៦០ | ៩០ |
| កណ្តាល | ២ | ២៥ | ១៧ | ២ | ២២ | ២៨ | ០ | ០ | ០ | ១ | ១៧ | ៨ | ១ | ១៥ | ១០ | ៦ | ៧៩ | ៦៣ |
| សៀមរាប | ១ | ៧ | ១៦ | ០ | ០ | ០ | ០ | ០ | ០ | ២ | ១៧ | ៣៣ | ៣ | ៤៧ | ៣០ | ៦ | ៧១ | ៧៩ |
| កោះកុង | ២ | ១២ | ៣២ | ១ | ១០ | ១៥ | ០ | ០ | ០ | ១ | ១២ | ១៣ | ២ | ២៣ | ២៧ | ៦ | ៥៧ | ៨៧ |
| ព្រះសីហនុ | ១ | ៨ | ១៧ | ២ | ២៦ | ២៥ | ១ | ១១ | ១៤ | ១ | ៤ | ២១ | ១ | ១៦ | ៩ | ៦ | ៦៥ | ៨៦ |
| សរុប | **៨** | **៥៩** | **១២៥** | **៧** | **៨៩** | **៨៧** | **១** | **១១** | **១៤** | **៦** | **៦១** | **៨៩** | **៨** | **១១២** | **៩០** | **៣០** | **៣៣២** | **៤០៥** |

**សំគាល់:** #: ចំនួនវគ្គហ្វឹកហ្វឺន VC/VAC: កុមាររងគ្រោះ/កុមារងាយរងគ្រោះ

LA: អជ្ញាធរមូលដ្ឋាន S: សិស្ស T: គ្រូបង្រៀន

PWC: ឪពុកម្តាយកុមារធ្វើការ SoE: បុគ្គលិកបង្កើត

## វគ្គហ្វឹកហ្វឺនផ្តល់ជូនអង្គការផ្សេងៗ

**វគ្គហ្វឹកហ្វឺនផ្តល់ជូនអង្គការផ្សេងៗ**

| ថ្ងៃខែ | អង្គការ និងគោលបំណង |
|---|---|
| ខែមីនា | ផ្តល់វគ្គសិក្ខាសាលា ៣ ដល់អង្គការមូលនិធិកុមារ អំពីសិទ្ធិកុមារ ការជួញដូរកុមារ និងពលកម្មកុមារ |
| ថ្ងៃទី៣-៤ ខែកញ្ញា | ផ្តល់វគ្គសិក្ខាសាលាអំពីសិទ្ធិកុមារ និងការរំលោភបំពានលើកុមារ ដល់អង្គការសហការ |
| ថ្ងៃទី២៧ ខែសីហា | ផ្តល់វគ្គសិក្ខាសាលាអំពីសិទ្ធិកុមារ និងការជួញដូរកុមារដល់ Community Care Coalition |
| ថ្ងៃទី២៨-២៩ ខែសីហា | ផ្តល់វគ្គសិក្ខាសាលាអំពីសិទ្ធិកុមារ និងការជួញដូរកុមារ ដល់អង្គការទស្សនៈពិភពលោកកម្ពុជា |

## ក្រុមការពារកុមារ និងតស៊ូមតិ

ក្រុមអ្នកការពារកុមារចំនួន ៦៥នាក់ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំទី១ នៃកម្មវិធីអង្គការប្រត្តិបត្តិការណ៍មួយថ្ងៃ។ ក្រុមអ្នកការពារកុមារមិនត្រូវបានបង្កើតថ្មីទៀតទេនៅក្នុងកំឡុងពេលនេះ។ ការិយាល័យសិទ្ធិកុមារ បានផ្តោតលើការកសាងសមត្ថភាពរបស់ក្រុមការពារកុមារដែលមានស្រាប់ ដើម្បីឱ្យពួកគេអាចធ្វើការតស៊ូមតិផ្សព្វផ្សាយ និងឆ្លើយតបនឹងការរំលោភបំពានទៅលើកុមារ។ ការិយាល័យសិទ្ធិកុមារនៅតែបន្តគាំទ្រដល់ក្រុមបណ្តាញការពារកុមារទាំង ៥៦ ដែលបានបង្កើតឡើងក្រោមជំនួយឧបត្ថម្ភរបស់ម្ចាស់ជំនួយមុន។

## ក្លឹបសិស្ស

ក្រុមសិស្សការពារកុមារចំនួន១២ ត្រូវបានប្តូរទៅចូលរួមក្នុងក្លឹបសិស្សចំនួនប្រាំបី។ សិស្សក្លិបត្រូវបានបង្កើតឡើងតាមរយៈការប្រជុំរបស់នាយកគ្រប់គ្រងសាលា អ្នកតំណាង និងក្រុមសិស្សការពារកុមារ។ ការពិភាក្សាស្តីអំពីដំណើរការក្លឹបដោយធ្វើការបង្ហាញកិច្ចស្វាគមន៍ដែលរៀបចំដោយបុគ្គលិកគម្រោង។ បន្ទាប់មកការបោះឆ្នោតរៀបចំឡើងដោយ១សម្លេងពីអ្នកថ្នាក់ដឹកនាំ ១សម្លេងពីអនុប្រធានដឹកនាំ និង១សម្លេងពីលេខាធិការដែលបោះឆ្នោតសម្រាប់ក្លិបនិមួយៗ។ ក្លិបនីមួយៗមានសមាជិកពី ១៤ ទៅ ៣៤នាក់ (លើកលែងម្នាក់នៅខេត្តកោះកុង ដែលសមាជិកសរុបមាន ៥៨នាក់) ដែលរួមបញ្ចូលទាំងគ្រប់សមាជិកក្លិបកុមារដែលមានស្រាប់ និងសិស្សពូកែដែលមកពីសាលាទាំងនោះ។ តំណាងម្នាក់ ត្រូវបានចាត់តាំងដោយសាលាដើម្បីធ្វើជាអ្នកទទួលខុសត្រូវក្លិប។

## ករណីសិក្សារបស់ក្រុមអ្នកការពារកុមារ

កុមារាសេង ចន្ទ័សុភាព កើតនៅឆ្នាំ១៩៩៣ គេជាកូនទីប្រាំនៅក្នុងបន្ទុក។ កុមារារស់នៅ ក្នុងស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ រស់នៅជាមួយឪពុកពិការ ម្តាយរបស់គេមិនមានការងារធ្វើ និងបងប្អូនចំនួន ៤នាក់ទៀត។ គ្រួសាររបស់សុភាពក្រណាស់។ សេង ចន្ទ័សុផល គឺជាកូនច្បង ហើយសព្វថ្ងៃគេជានិសិត្សឆ្នាំទី៤ នៃសកលវិទ្យាល័យច្បាប់ និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ហើយគេ គឺជាកូនតែម្នាក់គត់ ដែលបានរៀនដល់ថ្នាក់មហាវិទ្យាល័យ។

ក្នុងឆ្នាំ២០០៦ សេង ចន្ទ័សុភាព ត្រូវបានអញ្ជើញឱ្យចូលរួមវគ្គសិក្ខាសាលាហ្វឹកហ្វឺនអំពីសិទ្ធិកុមារ ដែលរៀបចំដោយអង្គការលីកាដូ។ នៅក្នុងសិក្ខាសាលា សុភាព ត្រូវបានជ្រើសរើសជាសមាជិកក្រុមការពារកុមារ ក្រោយពីគេមានក្តីរំភើបនៅខណៈពេលចូលរួមវគ្គហ្វឹកហ្វឺន ហើយបន្ទាប់មកទៀត គេត្រូវបានជ្រើសតាំងអ្នកប្រធានក្រុមការពារកុមារប្រចាំស្រុកស្ទឹងហាវ។ គេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលរូបគេត្រូវបានជ្រើសតាំង ហើយគេក៏មិននឹកស្មានដល់ថាគេមានឱកាសដើម្បីជួយដល់កុមារនៅក្នុងសហគមន៏របស់គេឡើយ។

ដោយសារតែរូបគេបានចូលរួមនៅក្នុងកម្មវិធីគម្រោងសិទ្ធិកុមារដូចជា វគ្គសិក្ខាសាលាវគ្គហ្វឹកហ្វឺនបង្កើនសមត្ថភាព និងកម្មវិធីវិទ្យុ កុមារាសុភាព បានកើនចំណេះដឹងយ៉ាងច្រើនទាក់ទងនឹងសិទ្ធិកុមារ។ ក្រោយមក កុមារាបានក្លាយទៅជាអ្នកដឹកនាំក្រុមដ៏សកម្ម ដែលទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ និងរាយការណ៍ករណីទៅអង្គការលីកាដូ និងភ្នាក់ងារដែលពាក់ព័ន្ធនៅក្នុងសហគមន៏របស់គេ។

នៅដើមឆ្នាំ២០០៧ កុមារាសុភាព ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គសិក្ខាសិលារយៈពេល៣ថ្ងៃអំពីលទ្ធផលសកម្មភាពឆ្នាំ២០០៦ និងធ្វើការអភិវឌ្ឍន៍លើផែនការការងារសំរាប់ឆ្នាំ២០០៧ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិសំរាប់កុមារ CNCC នៅឯក្រសួងសង្គមកិច្ច។ នៅពេលបិទអង្គសិក្ខាសាលា កុមារាត្រូវបានជ្រើសតាំងឱ្យឡើងថ្លែងអំពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ជូនឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា។ ក្រោយមក សុភាពត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំ ដោយអង្គការគណកម្មាធិការសិទ្ធិកុមារ ក្នុងគោលបំណងជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការថ្មីរបស់អង្គការគណកម្មាធិការសិទ្ធិកុមារ និងដើម្បីធ្វើការអភិវឌ្ឍន៍លើផែនការការងារសំរាប់ឆ្នាំ២០០៨ និងរៀបចំកម្មវិធីថ្នាក់ជាតិថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៨ សម្រាប់ថ្ងៃសិទ្ធិកុមារអន្តរជាតិ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨ និងថ្ងៃទិវាពិភពលោកប្រឆាំងពលកម្មកុមារ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨។ នៅក្នុងអង្គប្រជុំនោះ សុភាព ត្រូវជ្រើសរើសឱ្យថ្លែងសុន្ទរកថា ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៨។ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៨ សុភាពបានថ្លែងសុន្ទរកថាជូនឯឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី។

កុមារាសុភាព បានចាប់ផ្តើមឡើងពីចំនុចក្រោម ហើយបានត្រូវគេទទួលស្គាល់ និងកោតសរសើរដល់សមត្ថភាពបទពិសោធន៍ និងចំណេះដឹងផ្នែកសិទ្ធិកុមារយ៉ាងខ្លាំង។ ហេតុនេះ សុភាពត្រូវបានអញ្ជើញដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដើម្បីថ្លែងសុន្ទរកថាអំពីប្រធានបទផ្សេងៗទាក់ទងនឹងសិទ្ធិកុមារ ពលកម្មកុមារ ការជួញដូរកុមារ និងការចូលរួមរបស់កុមារ។

## ការតាមដាន វគ្គបណ្តុះបណ្តាល

វគ្គហ្វឹកហ្វឺនបណ្តុះបណ្តាលទាំង ១៧ ត្រូវបានរៀបចំឡើងសម្រាប់អ្នកដែលបានចូលរួមសិក្ខាសាលាកន្លងទៅ ដើម្បីឱ្យពួកគេនឹកឃើញអំពីប្រធានបទ ដូចជា សិទ្ធិកុមារ ពលកម្មកុមារ និងការជួញដូរកុមារ និងសំនួរផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិកុមារ។ អ្នកចូលរួម ចំនួន ៤១៤ នាក់ (ស្ត្រី ១៨១នាក់ និងបុរស ២៣៣ នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងទីតាំងចំនួន ៥ កន្លែង។

## វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពក្រុមការពារកុមារ

វគ្គហ្វឹកហ្វឺនបណ្តុះបណ្តាលចំនួន ១០៥ វគ្គ ត្រូវបានរៀបចំធ្វើឡើងសម្រាប់ក្រុមការពារកុមារ ដែលមានស្រាប់ផ្នែកកុមារ និងមនុស្សពេញវ័យ ដើម្បីកសាងសមត្ថភាព អំពីសិទ្ធិកុមារបញ្ហាពលកម្មកុមារ និងជំនាញក្នុងការផ្សព្វផ្សាយ។ សមាជិក ១,៦៤៩ នាក់ (ស្ត្រី ៧៩៦ នាក់ និង បុរស ៨៥៣ នាក់) បានចូលរួមវគ្គបណ្តុះបណ្តាល។

៣៧ វគ្គ សម្រាប់ក្រុមការពារកុមារផ្នែក មនុស្សពេញវ័យ និង៦៨វគ្គ សម្រាប់ក្រុមការពារកុមារផ្នែកកុមារ។ សមាជិកក្រុមការពារកុមារផ្នែកកុមារ ៥ នាក់ ត្រូវបានគាំទ្រដោយលីកាដូ និងបានចូលរួមជាសមាជិកក្លិបចលនាកុមារ និងយុវជនដែលត្រូវបានបង្កើតឡើងដោយមូលនិធិសិទ្ធិកុមារ។ ក្លិបនេះមានការប្រជុំមួយរៀងរាល់ខែ នៅការិយាល័យ មូលនិធិសិទ្ធិកុមារ នៅរាជធានីភ្នំពេញ ដែលពួកគេជួយអភិវឌ្ឍគម្រោងសកម្មភាពមួយនៅក្នុងតំបន់របស់ពួកគេ។

សមាជិកក្រុមការពារកុមារផ្នែកកុមារ ៥ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលដែលមានរយៈពេល ២ ថ្ងៃ ស្តីអំពីការតស៊ូមតិលើកុមារ ដែលរៀបចំឡើងដោយគណៈកម្មាធិការស្តីអំពីសិទ្ធិកុមាររបស់អង្គការក្រៅរដ្ឋាភិបាល។

## សកម្មភាពរបស់ក្រុមការពារកុមារ



ការប្រជុំចំនួន ១៦៦ របស់ក្រុមការពារកុមារផ្នែកកុមារ និងមនុស្សពេញវ័យ ត្រូវបានរៀបចំដោយក្រុមការពារកុមារដែលមានការគាំទ្រជំនួយពីមន្ត្រីសិទ្ធិកុមារជាន់ខ្ពស់ និងអ្នកទាក់ទាញមតិគាំទ្រដែលមានក្រុមការពារកុមារដែលមានស្រាប់ផ្នែកកុមារ និងមនុស្សពេញវ័យនៅតាមតំបន់ដើម្បីគាំទ្រ និងធ្វើសកម្មភាពតបតនឹងការចូលរួមរបស់ពួកគេនៅក្នុងការទប់ស្កាត់ និងការពារកុមារ (អង្គប្រជុំ ៨២ ដឹកនាំដោយក្រុមការពារកុមារផ្នែកកុមារ និង ៨៤ ទៀត ដឹកនាំដោយក្រុមការ

ពារកុមារផ្នែកមនុស្សពេញវ័យ) ។

វគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ ចំនួន ១៣៩ ត្រូវបានធ្វើឡើង ស្តីអំពីសិទ្ធិកុមារ ពលកម្មកុមារ ការជួញដូរកុមារ ទេសចរផ្លូវភេទកុមារ និងសុវត្ថិភាពរបស់កុមារនៅកន្លែងធ្វើការត្រូវបានរៀបចំធ្វើឡើងដោយសមាជិកក្រុមការពារកុមារដោយមានជំនួយពីមន្ត្រីទាក់ទាញមតិគាំទ្រសិទ្ធិកុមារ (៦៩ វគ្គ ដឹកនាំដោយក្រុមការពារកុមារផ្នែកកុមារ និង ៧០ ទៀត ដឹកនាំដោយក្រុមការពារកុមារផ្នែកមនុស្សពេញវ័យ) ។ ចំនួនមនុស្សសរុប ១០,២៣១ បានចូលរួមវគ្គផ្សព្វផ្សាយ រួមទាំងកុមារនៅតាមភូមិចំនួន ៤,៥៧៥ ផងដែរ ។

ក្នុងរយៈពេលពេញមួយឆ្នាំសំនុំរឿង ៨៨ ករណីដែលស្ថិតក្រោមអណត្តិ នៃការឃ្លាំមើលសិទ្ធិកុមារត្រូវបានរាយការណ៍ ទៅអ្នកឃ្លាំមើលរបស់អង្គការលីកាដូ និងមន្ត្រីទាក់ទាញមតិគាំទ្រ ដោយសមាជិកក្រុមការពារកុមារ ។ ករណីទាំងនោះរួមមាន កុមារបំរើការងារតាមផ្ទះ ការគំរាមសម្លាប់កុមារ/កុមាររងាយរងគ្រោះ/កុមារប្រឈមគ្រោះថ្នាក់ ករណីហិង្សាក្នុងគ្រួសារ ករណីសម្លាប់ ករណីរំលោភសេពសន្ថវៈ និងករណីបង្ករបួសស្នាម ។ ករណីជាច្រើនរាយការណ៍ដោយលោកគ្រូ-អ្នកគ្រូ អាជ្ញាធរមូលដ្ឋាន និងឪពុកម្តាយកុមារធ្វើការ ប៉ុន្តែបើយោងតាមសមាជិកក្រុមការពារកុមារផ្នែកកុមារបានរាយការណ៍ថា សំនុំរឿងមានចំនួនកើនឡើង ជាពិសេសនៅខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តសៀមរាប កោះកុង និងខេត្តព្រះសីហនុ ដែលណែនាំកុមារនៅក្នុងក្រុមទាំងនេះឱ្យមានទំនុកចិត្ត និងចេះការពារនៅក្នុងការចាត់វិធានការ និងធ្វើការរាយការណ៍ ។

លើសពីនេះទៅទៀត ក្រុមការពារកុមារបានជួយមន្ត្រីទាក់ទាញមតិគាំទ្រសិទ្ធិកុមារ បុគ្គលិកកិច្ចការសង្គម និងអ្នកឃ្លាំមើលជាច្រើនទៀត នៅក្នុងការស្វែងរកការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធដើម្បីធ្វើការស៊ើបអង្កេត វាយតម្លៃ និងផ្តល់ជំនួយផ្នែកសង្គមដល់ជនរងគ្រោះ កុមារដែលងាយរងគ្រោះ និងគ្រួសារក្រីក្រ ។

## សកម្មភាពតស៊ូមតិ

### ការតស៊ូមតិផ្នែកវិទ្យុ




ក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ ប្រធានអង្គការលីកាដូ លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក បានចូលរួម វេទិកាជជែកតាមវិទ្យុចំនួន២៦ (នៅប៉ុស្តិ៍វិទ្យុ FM ១០៥ និង FM ១០៣ ) ពិភាក្សាលើប្រធានបទអំពើហិង្សានៅក្នុងប្រទេសកម្ពុជា ។

កម្មវិធីវិទ្យុចំនួន ១៦ ត្រូវបានផ្សាយតាមវិទ្យុ FM 95.2 FM 102 និងវិទ្យុសារិកា អំពីសិទ្ធិកុមារជាទូទៅ និងបញ្ហាសិទ្ធិ

កុមារផ្សេងៗទៀត រួមមានប្រធានបទដូចជា ទិវាសិទ្ធិកុមារអន្តរជាតិ ពលកម្មកុមារ ការជួញដូរកុមារដើម្បីកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទលើកុមារ។ វាគ្មិន ដែលត្រូវបានអញ្ជើញ គឺជាអ្នកទាក់ទាញមតិគាំទ្រសិទ្ធិកុមារ អ្នកទាក់ទាញមតិគាំទ្រជាន់ខ្ពស់ និងការិយាល័យកិច្ចការវិជ្ជាជីវៈ និងពលកម្មរបស់ខេត្តកំពត ការិយាល័យជួញដូរកុមារ និងការពារអនីតិជន និងកុមារពេញវ័យរបស់ក្រុមការពារកុមារ។

អ្នកគ្រប់គ្រងការិយាល័យសិទ្ធិកុមារបានចូលរួមកម្មវិធីវិទ្យុចំនួន ៧ (ការពិភាក្សាតុមូលចំនួន ៤ នៅវិទ្យុ FM 102 និងមួយដងនៅវិទ្យុ FM 105 មួយដងនៅវិទ្យុសារិកា ១០៦.៥ និងមួយដងនៅវិទ្យុជាតិកម្ពុជា FM 102 MHz)។

លោកអនុប្រធានគ្រប់គ្រងផ្នែកតស៊ូមតិ និងទំនាក់ទំនងបានចូលរួមក្នុងកម្មវិធីវិទ្យុ (ការពិភាក្សាតុមូល) នៅវិទ្យុ ១០៦.៥ ក្នុងកម្មវិធីព្រឹត្តិការណ៍ប្រគំតន្ត្រីតស៊ូមតិអំពីកុមារបំរើតាមផ្ទះនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨។

មានកម្មវិធីវិទ្យុចំនួន ៥ (ការពិភាក្សាតុមូលនៅវិទ្យុ FM 105 និងFM 102) ធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០០៨ អំពីសិទ្ធិកុមារទូទៅ និងបញ្ហាសិទ្ធិកុមារផ្សេងៗទៀត រួមមានប្រធានបទៈ ថ្ងៃទិវាសិទ្ធិកុមារអន្តរជាតិ ពលកម្មកុមារ ការជួញដូរពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ វាគ្មិនដែលត្រូវបានអញ្ជើញ គឺជាអ្នកទាក់ទាញមតិគាំទ្រសិទ្ធិកុមារ អ្នកទាក់ទាញមតិគាំទ្រជាន់ខ្ពស់ និងការិយាល័យកិច្ចការវិជ្ជាជីវៈ និងពលកម្មរបស់ខេត្តកំពត និងក្រុមសង្គ្រោះកុមារ។ ការទូរស័ព្ទហៅចូលនៅក្នុងកម្មវិធីក៏មាន ប្រជាប្រិយភាពផងដែរ។

## សិក្ខាសាលា និងព្រឹត្តិការណ៍តស៊ូមតិ ស្តីអំពីកុមារធ្វើការនៅរោងចក្រឡឥដ្ឋ



ការបង្ហាញនៅសិក្ខាសាលាស្តីអំពីរបកគំហើញកុមារធ្វើការនៅរោងចក្រឡឥដ្ឋនៅខេត្តបាត់ដំបង ត្រូវបានរៀបចំធ្វើនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨ នៅខេត្តបាត់ដំបង។ មានសិក្ខាកាមចូលរួម ៩៧ នាក់ នៅក្នុងសិក្ខាសាលារួម មានអ្នកតំណាងមកពីអង្គការជាដៃគូទាំងពីរគឺ អង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា អភិបាលខេត្ត អភិបាលស្រុក ២ នាក់ អភិបាលរងស្រុក ២ នាក់ មកពីស្រុកថ្មគោល និងស្រុកសង្កែ ម្ចាស់រោងចក្រឡឥដ្ឋ ១១ នាក់ ឪពុកម្តាយដែលមានកូនធ្វើការ ១១ នាក់ កុមារធ្វើការនៅរោងចក្រឡឥដ្ឋ ៥ នាក់ និងអ្នកចូលរួម ៥៥ នាក់ ផ្សេងទៀតមកពីអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការស្រាវជ្រាវនេះ។

នៅក្នុងអង្គសិក្ខាសាលានោះ ក៏បានដាក់បង្ហាញនូវការស្រាវជ្រាវឆ្នាំ២០០៧ ដែលបានធ្វើរួចមកហើយអំពីកុមារធ្វើការនៅរោងចក្រឡូឥដ្ឋក្នុងខេត្តបាត់ដំបង។ ការស្រាវជ្រាវនេះធ្វើឡើងដោយអង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា។

បន្តមកទៀត គឺយុទ្ធនាការថ្នាក់ជាតិលើកទី ៣ ស្តីអំពីកុមារធ្វើការនៅរោងចក្រឡូឥដ្ឋ ត្រូវបានរៀបចំធ្វើនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៨ នៅឧទ្យានជាតិនាគបាញ់ទឹកខេត្តបាត់ដំបង។ គោលបំណងនៃព្រឹត្តិការណ៍ជាសាធារណៈនេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីកុមារធ្វើការនៅរោងចក្រឡូឥដ្ឋ តាមរយៈការផ្សព្វផ្សាយសៀវភៅរូបតូច ការប្រគំតន្ត្រី ការថ្លែងសុន្ទរកថា និងលេងល្បែងសម្រាប់កុមារ។ យុទ្ធនាការនេះត្រូវបានគេផ្សព្វផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុកគឺ សារព័ត៌មានកោះសន្តិភាព និងសារព័ត៌មានរស្មីកម្ពុជា រយៈពេល ២ ថ្ងៃ និងផ្សព្វផ្សាយតាមវិទ្យុ FM ១០៣.២៥ និង FM ៩១ MHz ព្រមទាំងបិទប្រកាសរូបថតអ្នកកំប្លែងដ៏ល្បីឈ្មោះរយៈពេល ២ ថ្ងៃមុន។

សាធារណៈជនចូលរួមក្នុងព្រឹត្តិការណ៍នោះត្រូវបានគេប៉ាន់ស្មានថាមានចំនួនប្រហែល ២.៥០០ នាក់។ មានពិធីករដែលមានបទពិសោធន៍ ២ រូប និងមានការសម្តែងរឿងកំប្លែងដោយ នាយខ្ចឹប និងនាងក្អយ ការលេងល្បែងកុមារនៅលើឆាក និងការថតសំលេងរបស់កុមារី និងកុមារាម្នាក់ដែលបាននិយាយ អំពីបទពិសោធន៍របស់ពួកគេដែលធ្វើការនៅឡូឥដ្ឋ។

ព្រឹត្តិការណ៍នៃយុទ្ធនាការនោះត្រូវបានចាក់ផ្សាយតាមវិទ្យុអាស៊ីសេរី វិទ្យុសំលេងសហរដ្ឋអាមេរិក និងគ្របដណ្តប់លើសារព័ត៌មានខាំបូដស័រ ភ្នំពេញប៉ុស្តិ៍ ឌឺ ឃែមបូឌា ដេលី និងសារព័ត៌មានកោះសន្តិភាព។

**ទិវាកុមារអន្តរជាតិ**

បានរៀបចំប្រារព្ធទិវាកុមារអន្តរជាតិ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨ ចំនួន ២ កន្លែង ( ស្រុកកៀនស្វាយ និងខេត្តកោះកុង)។ នៅតាមតំបន់និមួយៗ យុទ្ធនាការនេះបានជ្រើសរើសបញ្ហាដ៏ជាក់លាក់របស់កុមារក្នុងគោលបំណង ដើម្បីលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍។ បញ្ហាទាំងនោះរួមមាន ការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ព្រឹត្តិការណ៍សាធារណៈនេះត្រូវបានរៀបចំដោយអង្គការលីកាដូ សហការជាមួយអាជ្ញាធរមូលដ្ឋាន នគរបាល សិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូ អង្គការក្រៅរដ្ឋាភិបាល និងសមាជិកសហគមន៍ដ៏ទៃទៀត។ ព្រឹត្តិការណ៍ទាំងនេះបានចាប់ផ្តើមប្រព្រឹត្តទៅនៅម៉ោង ២ រសៀលរហូតដល់ល្ងាច រួមមាន :

- អភិបាលខេត្ត-ក្រុង និងស្រុក ជជែកអំពីសិទ្ធិកុមារ និងបញ្ហាកុមារ
- អ្នកតំណាងរបស់ក្រុមការពារសិទ្ធិកុមារ និងលីកាដូ បានថ្លែងសុន្ទរកថាស្តីអំពីសិទ្ធិកុមារ

- មានក្រុមការពារកុមារផ្នែកកុមារ និងអ្នកចំរៀងអាជីពបានច្រៀងចំរៀងស្តីពីបញ្ហាសិទ្ធិកុមារ
- រឿងល្ខោនសំដែងដោយក្រុមកំប្លែងមកពីទីក្រុងភ្នំពេញ
- មានឆ្លើយសំនួរយករង្វាន់អំពីបញ្ហាសិទ្ធិកុមារ
- ការបង្ហោះប៉ោងប៉ោង
- ការចែកសម្ភារៈអប់រំរួមមាន កូនសៀវភៅអត្ថបទ ផ្ទាំងរូបភាព ខិត្តប័ណ្ណ សៀវភៅកុមាររីករាយ ។
- បញ្ចាំងវីដេអូអប់រំអំពីពលកម្មកុមារ និងការជួញដូរកុមារ និងសិទ្ធិកុមារ
- ល្បែងប្រពៃណី និងល្បែងតាមតំបន់ រៀបចំដោយក្រុមការពារកុមារ ។



លទ្ធផលដែលទទួលបានពីសកម្មភាពទាំងនេះរួមមាន ការបង្កើនការយល់ដឹងស្តីអំពីបញ្ហាសិទ្ធិកុមារនៅក្នុងតំបន់ ការផ្សាយអប់រំឱ្យទស្សនិកជនបានដឹងអំពីសិទ្ធិកុមារនៅតាមតំបន់និមួយៗ ដែលចំនួនទស្សនិកជននៅគ្រប់ទីតាំងទាំងអស់សរុបប្រហែល ៨,០០០ នាក់ ។ ព័តិមាន និងរូបភាព ត្រូវបានចាក់ផ្សាយនៅក្នុងប្រព័ន្ធផ្សាយព័តិមានក្នុងស្រុករួមមានទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ស៊ីធីអិន និងសារព័តិមានក្នុងស្រុកផ្សេងទៀត។ ព្រឹត្តិការណ៍ទាំងនេះត្រូវបានគេជ្រើសរើសចាក់ផ្សាយផ្ទាល់នៅស្ថានីយវិទ្យុ FM ១០៥។

ជាមួយគ្នានេះផងដែរ នៅទិវាសិទ្ធិកុមារអន្តរជាតិ បុគ្គលិកការិយាល័យសិទ្ធិកុមារបានចូលរួមជាមួយដៃគូរបស់អង្គការលីកាដូ គឺមូលនិធិអនាគតកម្ពុជា ដែលជាស្ថាប័នក្រៅរដ្ឋាភិបាល និងបានជួយរៀបចំប្រារព្ធកម្មវិធីនៅភូមិអណ្តូង ដែលជាតំបន់ជម្លៀសនៃការតាំងទីលំនៅថ្មីខាងក្រៅរាជធានីភ្នំពេញ។ កុមារជាង ៦០០ នាក់ បានចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ ហើយបានលេងល្បែងកំសាន្ត ល្ខោន និងប្រគំតន្ត្រី ហែក្បួនតុក្កតា ការរាំ ការគូរគំនូរលើមុខ សិល្បៈឆ្លាក់ផ្អែក និងសកម្មភាពផ្សេងទៀត។

## ក្បួនតស៊ូមតិការជួញដូរកុមារនៅខេត្តកោះកុង




បុគ្គលិកលីកាដូ និងសមាជិកក្រុមការពារកុមារ បានចូលរួមក្នុងការដើរក្បួនតស៊ូមតិនៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ អំពីការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងខេត្តកោះកុង ក្រោមពាក្យស្លោក "ធ្វើការទាំងអស់គ្នាដើម្បីបញ្ឈប់ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ" ។

គោលបំណងនៃក្បួនតស៊ូមតិនេះ គឺដើម្បីពង្រីកការយល់ដឹងអំពីរាល់ទម្រង់រំលោភបំពាន និងផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារ និងជម្រុញឱ្យមន្ត្រីរដ្ឋាភិបាល នគរបាល និងសាធារណៈជន រួមទាំងអ្នកទេសចរ ចូលរួមទាំងអស់គ្នាការពារកុមារពីការរំលោភបំពាន។ មានអ្នកចូលរួម ៥០០នាក់ ក្នុងនោះមានអភិបាលខេត្ត នគរបាល និងមន្ត្រីពាក់ព័ន្ធជាច្រើននាក់ទៀត បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងគ្រប់សមាជិកក្រុមអ្នកការពារកុមារ។ ការដើរក្បួននេះ ចាប់ផ្តើមពីម៉ោង ៧ ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់។ សកម្មភាពរួមមាន៖

- ការចេញសេចក្តីថ្លែងការណ៍ ២ ថ្ងៃមុនដើរក្បួន
- ទូរទស្សន៍ក្នុងស្រុក វិទ្យុ (វិទ្យុអាស៊ីសេរី និងសម្លេងសហរដ្ឋអាមេរិក) និងសារព័ត៌មានជាតិ និងអន្តរជាតិ បានលើកយកពាក្យស្លោក គោលបំណង និងសារៈសំខាន់ ដោយមានដាក់នូវពាក្យពេចន៍សំខាន់ៗ ពីការសម្ភាសន៍អ្នករៀបចំកម្មវិធី និងមន្ត្រីមូលដ្ឋាន ដែលបានចូលរួមក្នុងការដើរក្បួននេះ។
- សុន្ទរកថា ដោយអភិបាលខេត្ត អំពីបញ្ហាសិទ្ធិកុមារ
- សុន្ទរកថាដោយតំណាងក្រុមអ្នកការពារកុមារ និងអង្គការលីកាដូ អំពីសិទ្ធិកុមារ
- សុន្ទរកថាដោយតំណាងអង្គការលីកាដូផ្នែកសិទ្ធិកុមារ
- ការចាក់សម្លេងរឿងរ៉ាវរបស់កុមាររងគ្រោះដោយការជួញដូរ

ខិត្តប័ណ្ណ ត្រូវបានចែកចាយនៅពេលដើរក្បួន ក្នុងខិត្តប័ណ្ណមានព័ត៌មានអំពីការការពារកុមារពីការរំលោភបំពាន។ អ្នកដើរក្បួនពាក់អាវយឺត មួក និងមានកុកត្តាតំណាងឱ្យសភាវៈអាក្រក់នៃការបំពានលើកុមារ និងបដាចំនួន ១៧ សរសេរថា "ផ្តល់អនាគតដល់កុមារ បញ្ឈប់ការជួញដូរកុមារ និងការបំពានផ្លូវភេទលើកុមារ" និងពាក្យស្លោកមួយទៀត" ការរំលោភបំពានផ្លូវភេទលើកុមារ ត្រូវជាប់ពន្ធនាគារ ពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ"។

មន្ត្រីមូលដ្ឋានបានបង្ហាញនូវការគាំទ្រ និងសហការល្អដោយបានអនុញ្ញាតឱ្យរៀបចំដើរក្បួន។ នគរបាលការពារត្រូវបញ្ជូនមកដើម្បីសម្រួលចរាចរ សុវត្ថិភាពរបស់អ្នកចូលរួម និងមន្ត្រីមូលដ្ឋានដែលបានចូលរួមក្នុងការដើរក្បួននេះ។

**ព្រឹត្តិការណ៍តស៊ូមតិអំពីកុមារបំរើការងារតាមផ្ទះ នៅរាជធានីភ្នំពេញ**



នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ យុទ្ធនាការថ្នាក់ជាតិលើកទី២ អំពីកុមារបំរើការងារតាមផ្ទះ ត្រូវបានប្រារព្ធឡើងនៅរមណីយដ្ឋានវត្តភ្នំ ក្នុងរាជធានីភ្នំពេញ។ គោលបំណងនៃព្រឹត្តិការណ៍សាធារណៈនេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីកុមារបំរើការងារតាមផ្ទះ តាមរយៈការផ្សព្វផ្សាយតាមការចែកកូនសៀវភៅរូបភាពតូច ការប្រគំតន្ត្រី ការថ្លែងសុន្ទរកថា និងល្បែងសម្រាប់កុមារ។ ព្រឹត្តិការណ៍គ្រោងធ្វើគាប់ជួននឹងថ្ងៃបុណ្យអុំទូក

ប្រចាំឆ្នាំ ដែលប៉ាន់ប្រមាណមានប្រជាជនមកលេងនៅរាជធានីភ្នំពេញប្រហែលជាងមួយលាននាក់ដើម្បីមកមើលការប្រណាំងទូក (ទូកងមួយត្រូវបានគាំទ្រដោយអ្នកប្រកួតទូកពាក់អាវយឺតអំពីកុមារបំរើការងារតាមផ្ទះ)។ ព្រឹត្តិការណ៍នេះ ត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុក ដូចជាសារព័ត៌មានកោះសន្តិភាព រស្មីកម្ពុជា និងតាមវិទ្យុ FM 102 FM 93.5 និង FM 105 ព្រមទាំងបិទប្រកាសនៅក្នុងរាជធានីភ្នំពេញទៀតផង។

អ្នកចូលរួមត្រូវគេប៉ាន់ប្រមាណប្រហែលជាង ៦,០០០នាក់។ មានពិធីករដែលមានបទពិសោធន៍ ២ រូប និងការសម្តែងច្រៀងរបស់តារាល្បី លោកខេមរៈ សេរីមន្ត អ្នកនាងយក់ ចិតរដ្ឋា មានការលេងល្បែងឆ្លើយសំណួរសម្រាប់កុមារនៅលើឆាក ការសម្តែងល្ខោនខ្មែរដោយក្រុមកុមារ ការសម្តែងរឿងកំប្លែងអប់រំដោយក្រុមកំប្លែងនាយកុយ និងការចាក់សម្លេងរបស់កុមារបំរើការងារតាមផ្ទះ និយាយរៀបរាប់អំពីការលំបាកនៅកន្លែងការងារ។

ព្រឹត្តិការណ៍នេះត្រូវបានចាក់ផ្សាយនៅក្នុងវិទ្យុអាស៊ីសេរី វិទ្យុសម្លេងសហរដ្ឋអាមេរិក វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងមានចុះនៅក្នុងសារព័ត៌មានកាំបូឌស័រ ភ្នំពេញប៉ុស្តិ៍ រស្មីកម្ពុជា និងកោះសន្តិភាព និងនៅស្ថានីយ៍ទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ ៣។

**សម្ភារៈ និងឧបករណ៍សម្រាប់ធ្វើការតស៊ូមតិ**

**សម្ភារៈដែលបានបោះពុម្ព និងបានធ្វើឱ្យប្រសើរឡើង**




- បានធ្វើការបោះពុម្ពឡើងវិញនូវខិត្តប័ណ្ណរូបភាពចំនួន ៤,៧៥០ សន្លឹកស្តីពីសិទ្ធិកុមារ
- បានធ្វើការបោះពុម្ពកូនសៀវភៅកុមាររីករាយចំនួន៤០០០ ក្បាល ដែលមានចំណងជើងថា តើអ្នកអាចធ្វើការប្រឆាំងនឹងការជួញដូរកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារយ៉ាងដូចម្តេច ?
- បានបោះពុម្ពអាវយឺតស្តីពីការជួញដូរកុមារ ចំនួន ៤០០ អាវ
- បានបោះពុម្ពឡើងវិញនូវខិត្តប័ណ្ណស្តីពីការជួញដូរកុមារ ចំនួន ៣,០០០ សន្លឹក
- បានបោះពុម្ពបដាមានសរសេរពាក្យពេចន៍ចំនួន ២ ផ្ទាំង សម្រាប់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨
- បានបោះពុម្ពវាំងននដែលព្យួរខាងក្រោយឆាក ២ សម្រាប់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨

**ការចែកជូនឯកសារ និងសម្ភារៈ**

ឯកសារ និងសម្ភារៈដែលបានរៀបជាតារាងខាងក្រោមនេះត្រូវបានចែកជូនដល់អ្នកចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ដែលត្រូវប្រើនៅក្នុងសកម្មភាពយុទ្ធនាការសិទ្ធិកុមារនៅថ្ងៃទី១ ខែមិថុនា និងដើម្បីផ្តល់វគ្គហ្វឹកហ្វឺនដល់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។

## តារាងឯកសារ និងសម្ភារៈ

| ល.រ | ឯកសារ និង សម្ភារៈ | ប្រើសម្រាប់ | | | | សរុប |
|---|---|---|---|---|---|---|
| | | វគ្គបណ្តុះបណ្តាល | យុទ្ធនាការ | ដើរក្បួន | អង្គការផ្សេងៗ | |
| ១ | សៀវភៅរូបភាព អំពីសិទ្ធិកុមារ (យោងតាមមាត្រានៃអនុសញ្ញាសិទ្ធិកុមារ) | ៤៣៣ | ៦០០ | ០ | ២៤០ | ៥១៧០ |
| ២ | ខិត្តប័ណ្ណរូបភាព អំពីសិទ្ធិកុមារ | ១២៧៥ | ១០០ | ០ | ២៤០ | ១៦១៥ |
| ៣ | កូនសៀវភៅតូចអំពីសិទ្ធិកុមារ និងការទទួលខុសត្រូវរបស់កុមារ | ៨៧៥ | ០ | ០ | ១៤០ | ១០១៥ |
| ៤ | កូនសៀវភៅកុមាររីករាយ តើអ្នកអាចធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានកុមារយ៉ាងដូចម្តេច? | ៣៥០០ | ៤០០ | ៥០០ | ១៧៥ | ៤៥៧៥ |
| ៥ | អនុសញ្ញា ILO លេខ ១៨២ និងទទួលស្គាល់លេខ១៩០ | ១១៧៥ | ០ | ០ | ១៥០ | ១៣២៥ |
| ៦ | អនុសញ្ញា ILO លេខ ១៣៨ | ១១៧៥ | ០ | ០ | ១៥០ | ១៣២៥ |
| ៧ | លិខិតបញ្ជាក់សំរាប់អ្នកចូលរួម | ៩០០ | ០ | ០ | ០ | ៩០០ |
| ៨ | លិខិតសរសើរសំរាប់ក្រុមអ្នកការពារកុមារ | ១៨០ | ០ | ០ | ០ | ១៨០ |
| ៩ | សៀវភៅសរសេរ (បោះពុម្ពភ្ជាប់សារសិទ្ធិកុមារ) | ៩២៥ | ០ | ០ | ០ | ៩២៥ |
| ១០ | អាវយឺតអំពីការជួញដូរកុមារ | ៨២ | ៨០ | ៥៥០ | ០ | ៧១២ |
| ១១ | មួក | ១០ | ៤០ | ៤២០ | ០ | ៤៧០ |
| ១២ | អនុសញ្ញាស្តីអំពីសិទ្ធិកុមារ | ១២៩៥ | ១២០ | ០ | ១៥០ | ១៥៦៥ |
| ១៣ | ប័ណ្ណប្រកាស អំពីនីតិវិធីច្បាប់ | ២៦០ | ០ | ២០០ | ០ | ៤៦០ |
| ១៤ | ក្រដាសបិទអំពីការជួញដូរកុមារ | ០ | ០ | ៣០០០ | ០ | ៣០០០ |
| ១៥ | សៀវភៅព័ត៌មានតូច " ការពារកុមារ និងសុវត្ថិភាពកុមារ " | ៤០០ | ០ | ០ | ១២០ | ៥២០ |
| ១៦ | ខិត្តប័ណ្ណអំពីសិទ្ធិកុមារ | ៣៣៥០ | ១០០០ | ៣០០០ | ០ | ៧៣៥០ |

## កុមារនៅក្នុងពន្ធនាគារ



នៅថ្ងៃទី១ មិថុនា ឆ្នាំ២០០៨ បុគ្គលិកលីកាដូបានប្រារព្ធទិវាកុមារអន្តរជាតិ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីពន្ធនាគាររបស់អង្គការលីកាដូ។ មានការចែកជូននូវសម្ភារៈប្រើប្រាស់សំខាន់ៗ ដូចជា មុង ស្បែកជើង សាប៊ូដុសខ្លួន សាប៊ូកក់សក់ ច្រាសដុសធ្មេញ ក្រាសសិតសក់ សារ៉ុង ទឹកផ្លែឈើ ចេក នំ បាល់ទាត់ ទឹក ព្រមទាំងម្ហូបអាហារដល់អនីតិជន កុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ និងស្ត្រីមានផ្ទៃពោះ នៅតាមបណ្តាពន្ធនាគារចំនួន ១២ ទូទាំងប្រទេសកម្ពុជា (ពន្ធនាគារខេត្ត ១០ និង ២ ពន្ធនាគារ នៅភ្នំពេញ) អ្នកដែលបានទទួលសម្ភារៈ និងម្ហូបអាហារ គឺ :

- កុមារ ៤១ នាក់ ដែលរស់នៅជាមួយឪពុកម្តាយនៅក្នុងពន្ធនាគារ
- អនីតិជន ៥៨២ នាក់
- អ្នកទោសស្ត្រីមានផ្ទៃពោះ ៤ នាក់
- កុមារ ៤៤១ នាក់ដែលជាកូនរបស់ឆ្មាំពន្ធនាគារ (ទទួលតែម្ហូបអាហារ និងទឹកផ្លែឈើប៉ុណ្ណោះ)។

## ការបង្កើនសមត្ថភាពបុគ្គលិក

វគ្គហ្វឹកហ្វឺនសិក្ខាសាលាដែលចូលរួមដោយបុគ្គលិកការិយាល័យសិទ្ធិកុមារ

- វគ្គហ្វឹកហ្វឺនក្រមនីតិវិធីព្រហ្មទណ្ឌថ្មីរយៈពេល ៥ថ្ងៃ ក្នុងខែមករា ឆ្នាំ២០០៨
- បុគ្គលិកការិយាល័យសិទ្ធិកុមារទាំងអស់ បានធ្វើការណែនាំអំពីសកម្មភាពគម្រោង និងអភិវឌ្ឍផែនការការងារប្រចាំឆ្នាំសម្រាប់ឆ្នាំ២០០៨ នៃអង្គការប្រត្តិការណ៍មួយថ្ងៃ។
- ការិយាល័យសិទ្ធិកុមារសិក្សាអំពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០០៨។
- បុគ្គលិកការិយាល័យសិទ្ធិកុមារ បានទទួលធ្វើការណែនាំអំពីការប្រើប្រាស់ទម្រង់ជំនួយសេវាសង្គមថ្មីដល់បុគ្គលិកអ្នកឃ្លាំមើលនៃអង្គការលីកាដូ ចំនួន ៤០នាក់ អ្នកស្រាវជ្រាវពន្ធនាគារ អ្នកទាក់ទាញមតិគាំទ្រ និងអ្នកសម្របសម្រួលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨។

## វគ្គហ្វឹកហ្វឺនសម្រាប់បុគ្គលិកនិមួយៗ

- អ្នកគ្រប់គ្រងស្តីទី និងអ្នកសម្របសម្រួលយុទ្ធនាការ បានចូលរួមវគ្គហ្វឹកហ្វឺនសរសេររបាយការណ៍ជាវិជ្ជាជីវៈពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ នៅសមាគមសិក្សាអាមេរិកភ្នំពេញ ។
- បុគ្គលិករដ្ឋបាលនៃការិយាល័យសិទ្ធិកុមារក៏បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញការិយាល័យរដ្ឋបាលដែលទទួលជោគជ័យ នៅសមាគមសិក្សាអាមេរិកភ្នំពេញ ពីថ្ងៃទី២១ ខែមករា ដល់ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ។

## ឥទ្ធិពល

- អ្នកចូលរួមទាំងឡាយបានគាំទ្រគំនិតក្នុងការលើកកម្ពស់សិទ្ធិកុមារនៅក្នុងសហគមន៍ដែលបង្ហាញការចាប់អារម្មណ៍នៅក្នុងការការពារកុមារ ។
- អ្នកចូលរួមភាគច្រើនបានបង្ហាញពីការជំរុញលើកទឹកចិត្តរបស់ពួកគេ និងចង់បន្តឱ្យមានការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសកម្មភាពបន្តបន្ទាប់ដោយលើកយកព្រឹត្តិការណ៍សំខាន់ៗដែលប្រជាជនចង់រៀនបន្ថែមទៀតអំពីសិទ្ធិកុមារ ។
- អ្នកចូលរួមទាំងឡាយបានពង្រីកនូវចំនេះដឹង និងការយល់ដឹងរបស់ពួកគេទៅដល់ សមាជិកដ៏ទៃទៀតនៃសហគមន៍របស់ពួកគេតាមរយៈការផ្សព្វផ្សាយអំពីសកម្មភាពដែលធ្វើឱ្យវគ្គបណ្តុះបណ្តាលក្លាយជាការអនុវត្តន៍ជាក់ស្តែង ។
- ក្រុមការពារកុមារធ្វើការតស៊ូមតិជាមួយមន្ត្រីរដ្ឋាភិបាលដើម្បីឱ្យមានការចូលរួម និងអភិវឌ្ឍផែនការការងារ និងកាលវិភាគសម្រាប់សហគមន៍របស់ពួកគេ ។
- សមាជិកនៃក្រុមការពារកុមារភាគច្រើនបានកោតសរសើរចំពោះសកម្មភាពគម្រោងពីព្រោះកម្មវិធីនេះអនុវត្តផ្ទាល់ជាមួយប្រជាជនក្រីក្រនៅក្នុងតំបន់ និងផ្តោតការយកចិត្តទុកដាក់លើបញ្ហាជាក់លាក់ដែលកំពុងកើតឡើងនៅក្នុងសហគមន៍របស់ពួកគាត់ ។
- សិក្ខាកាមភាគច្រើនចង់ធ្វើជាសមាជិកនៃក្រុមការពារកុមារដោយសារតែពេញចិត្តនឹងឋានៈ និងការទទួលខុសត្រូវ ។
- បង្កើនការរាយការណ៍ព័តិមាន និងពាក្យបណ្តឹងអំពីបញ្ហាកុមារ ករណីរំលោភសិទ្ធិ និងការកេងប្រវ័ញ្ចលើកុមារទៅដល់បុគ្គលិកបំរើការតាមមូលដ្ឋាន និងអ្នកឃ្លាំមើលនៅតាមទីតាំងគម្រោងទាំងអស់បង្ហាញពីការយល់ដឹងខ្ពស់ និងយល់ដឹងពីការទទួលខុសត្រូវរបស់សហគមន៍ក្នុងការការពារកុមារ ។

- សមាជិកខ្លះអាចឆ្លើយតប និងពិភាក្សាអំពីសេចក្តីត្រូវការ និងបញ្ហារបស់កុមារដោយខ្លួនគេផ្ទាល់នៅតាមតំបន់ដែលមានកម្មវិធីដែលឆ្ពោះទៅរកនិរន្តរ៍ភាពជាវិជ្ជមាន និងការបង្កើនចំនេះដឹងពីរបៀបឆ្លើយតបចំពោះការរំលោភសិទ្ធិកុមារ ។
- សំនួរជាច្រើនត្រូវបានលើកឡើងនៅឯសិក្ខាសាលា និងវគ្គផ្សព្វផ្សាយ ហើយត្រូវបានគេកត់សំគាល់ឃើញថាមានការកើនឡើងនូវការយល់ដឹងអំពី ថាតើរំលោភសិទ្ធិកុមារប៉ះពាល់ដល់សហគមន៍យ៉ាងដូចម្តេច ?
- បណ្តាញក្រុមការពារកុមារបានធ្វើអន្តរាគមន៍ជាច្រើនដើម្បីជួយជនរងគ្រោះពីស្ថានភាពគ្រោះថ្នាក់ដែលងាយរងគ្រោះដែលនេះជាលទ្ធផលដ៏ធំនៃការបង្កើនការផ្តល់ព័ត៌មានតាមរយៈបណ្តាញក្រុមការពារកុមារ ។
- អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងសហគមន៍មានការយល់ដឹងអំពីផលប្រយោជន៍សេវាសង្គម ។
- មានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយមណ្ឌលសុវត្ថិភាពកុមារ ដោយសារតែពួកគេបានយល់ដឹងនិងស្គាល់ពីតួនាទី និងគោលបំណងរបស់ភាគីនិមួយៗ ។
- មានអតិថិជនជាច្រើនចាប់ផ្តើមមានការយល់ដឹងសេវាសង្គមដែលផ្តល់ដោយអង្គការលីកាដូ ហើយនៅពេលជួបបញ្ហាពួកគេដឹងថាអង្គការលីកាដូជាកន្លែងដែលអាចជួយដល់ពួកគេបាន ។
- ជនបង្គោលរបស់ក្រុមអ្នកការពារកុមារមានលទ្ធភាពពាំនាំនូវបញ្ហា ដែលកើតមាននៅក្នុងសហគមន៍របស់ពួកគេនៅក្នុងព្រឹត្តិការណ៍ថ្នាក់ជាតិ ។

□□□

# ការិយាល័យប្រឆាំងអំពើទារុណកម្ម



**គោលបំណង**

- ដើម្បីផ្តល់សេវាកម្មស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាព និងការពារជនរងគ្រោះដោយអំពើទារុណកម្ម និងអំពើហិង្សាធ្ងន់ធ្ងរផ្សេងទៀតហើយនឹងដើម្បីចាត់វិធានការរារាំងការប្រើប្រាស់អំពើទារុណកម្មនៅក្នុងប្រទេសកម្ពុជា។
- ដើម្បីបណ្តុះបណ្តាលបុគ្គលិកលីកាដូ ឱ្យស្គាល់ពីសុខភាពផ្លូវចិត្ត ផ្តល់ប្រឹក្សាយោបល់ និងសេវាសង្គមកិច្ច។
- កំណត់ដៃគូសក្តានុពល ( អង្គការក្រៅរដ្ឋាភិបាល បុគ្គលសំខាន់ៗ និងបណ្តាញសហគមន៍ ។ល។) ដែលអាចសហការជាមួយគម្រោងក្នុងគោលបំណងដើម្បីបង្កើនទំហំ និងប្រសិទ្ធិភាពនៃសេវាកម្មទៅដល់ក្រុមគោលដៅនៃគម្រោង។
- ដើម្បីទប់ស្កាត់វប្បធម៌នៃអំពើទារុណកម្ម និងការប្រព្រឹត្តិដ៏សាហាវដែលកើតមានឡើងនៅក្នុងការអនុវត្តន៍ច្បាប់ និងស្ថាប័នផ្សេងៗតាមរយៈការបង្កើនការយល់ដឹង និងវិធានការទៅលើបញ្ហា និងលើកកម្ពស់ការអនុវត្តន៍ឱ្យកាន់តែល្អប្រសើរ។

**លទ្ធផលសំរេចបាន**

ការិយាល័យប្រឆាំងអំពើទារុណកម្ម ប្រតិបត្តិការការងារនៅក្នុងការិយាល័យលីកាដូប្រចាំរាជធានីភ្នំពេញ ដោយសហការជាមួយអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៅការិយាល័យតាមបណ្តាខេត្ត។ គម្រោងនេះ ផ្តល់សេវាស្តារលទ្ធភាពពលកម្មទៅដល់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរដែលត្រូវការជំនួយសង្គ្រោះផ្នែកផ្លូវកាយ និងផ្លូវចិត្ត។ ការរំលោភបំពានទាំងនោះរួមមាន ការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ អំពើទារុណកម្មដោយអាជ្ញាធរ ការវាយប្រហារដោយទឹកអាស៊ីដ និងករណីផ្សេងៗទៀត ដែលការិយាល័យប្រឆាំងអំពើទារុណកម្មបានធ្វើ ដោយមានកិច្ចសហប្រតិបត្តិការជាមួយការិយាល័យលីកាដូផ្សេងទៀត។

នៅដើមឆ្នាំ២០០៨ ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មបានធ្វើការទៅលើករណីចំនួន៤៦ ដែលក្នុងនោះមាន ៣៩ ហើយមានករណីថ្មីចំនួន៥ និង ២ ករណីទៀត កំពុងតែសហការបញ្ជូលជាមួយការិយាល័យផ្សេងទៀត។ ការិយាល័យប្រឆាំងអំពើទារុណកម្មផ្តល់សេវាស្តារលទ្ធភាពពលកម្មចំនួន៣ គឺការផ្តល់ការប្រឹក្សាយោបល់សេវា

សង្គមកិច្ច និងសេវាព្យាបាល។ តារាងខាងក្រោមបង្ហាញពីចំនួនករណីដែលទាក់ទង និងសេវាទាំងនេះក្នុងឆ្នាំ ២០០៨។

**សេវាស្តារលទ្ធភាពពលកម្មដែលផ្តល់ដោយការិយាល័យប្រឆាំងអំពើទារុណកម្មពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨**




តារាងខាងក្រោមបង្ហាញពីភាពញឹកញាប់នៃសេវាស្តារលទ្ធភាពពលកម្ម ដែលផ្តល់ដោយការិយាល័យប្រឆាំងអំពើទារុណកម្ម និងចំនួនសេវាបញ្ជូន។ នៅក្នុងករណីជាបន្ទាន់ ការិយាល័យប្រឆាំងអំពើទារុណកម្ម នឹងបញ្ជូនអតិថិជនទៅអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត ឬស្ថាប័នរាជរដ្ឋាភិបាលដែលអាចផ្តល់សេវាពេទ្យ និងការព្យាបាលដោយពេទ្យជំនាញ។

**ចំនួនសេវាស្តារលទ្ធភាពពលកម្មដែលកម្មវិធីប្រឆាំងអំពើទារុណកម្មផ្តល់ជូនអតិថិជន ពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០០៨**




បន្ថែមលើផលសំរេចបានជាក់ស្តែងដែលបានពិភាក្សាខាងលើ បុគ្គលិករបស់ការិយាល័យប្រឆាំងអំពើទារុណកម្មដែលមានបទពិសោធន៍ បង្កើនទំនាក់ទំនងដែលមានការទុកចិត្តរវាងពួកគេផ្ទាល់ និងជាមួយអតិថិជន។

***បិទការិយាល័យ***

ដោយការខ្វះខាតថវិកា ដើម្បីជួយផ្គត់ផ្គង់ដល់សកម្មភាព កម្មវិធីប្រឆាំងនឹងអំពើទារុណកម្មបានបិទការិយាល័យនៅក្នុងខែតុលា ឆ្នាំ២០០៨។ ក្នុងរយៈពេលបីខែចុងក្រោយ ករណីសំណុំរឿងមួយចំនួនដែលសេសសល់ត្រូវបានបិទ និងបញ្ជូនទៅការិយាល័យសិទ្ធិកុមារ ឬក៏បញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូរ។ បុគ្គលិកពីរនាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅការិយាល័យសិទ្ធិកុមារផ្នែកក្រុមការងារសង្គមកិច្ច ខណៈបុគ្គលិកផ្សេង ទៀតពុំទាន់មានការងារធ្វើ។

**ឥទ្ធិពល**

- អតិថិជន និងជនរងគ្រោះអាចមានលទ្ធភាពដោះស្រាយបញ្ហារបស់ពួកគេកាន់តែប្រសើរឡើង។
- ក្រុមគ្រួសាររបស់អតិថិជនមានការកើនឡើងនូវការយល់ដឹង ពីវិធីក្នុងការជួយដល់ជនរងគ្រោះនៅក្នុងក្រុមគ្រួសារគាត់។
- អតិថិជនមានសុខភាពល្អប្រសើរ បន្ទាប់ពីបានទទួលការព្យាបាលជំងឺ។

- សេចក្តីទុកចិត្ត និងទំនាក់ទំនងរវាងក្រុមគ្រួសាររបស់អតិថិជន និងបុគ្គលិកគម្រោងមានភាពល្អប្រសើរជាងមុន។
- ករណីទារុណកម្មសំខាន់ៗ គឺជាផ្នែកមួយដែលបានលើកមកពិភាក្សាតាមវិទ្យុ និងតាមការផ្សព្វផ្សាយផ្សេងៗទៀត ក្នុងគោលបំណងដើម្បីពង្រីកនូវការពិភាក្សានៅក្នុងសង្គម។

□□□

# ការិយាល័យពេទ្យ



គោលបំណង

- ដើម្បីផ្តល់ និងសម្របសម្រួលការថែទាំផ្នែកវេជ្ជសាស្ត្រសមរម្យឱ្យទណ្ឌិត និងមន្ត្រីពន្ធនាគារ ដើម្បីរកឱ្យឃើញ និងលើកឡើងនូវមូលហេតុនៃបញ្ហាសុខភាពជាចំបងនៅក្នុងពន្ធនាគារ ។
- ដើម្បីផ្តួចផ្តើមគំនិតក្នុងការអប់រំអំពីការការពារសុខភាព និងកម្មវិធីអនាម័យនៅក្នុងពន្ធនាគារ ។
- ដើម្បីរកឱ្យឃើញនូវមូលហេតុនៃការស្លាប់នៅក្នុងពន្ធនាគារ និងការធ្វើទារុណកម្ម ការព្យាបាលដោយមន្ត្រីពន្ធនាគារ បុគ្គលិកពន្ធនាគារ ។
- ដើម្បីផ្តល់នូវអាហារបន្ថែម ឱសថ និងសេវាកម្មផ្សេងៗទៀតទៅក្រុមជនងាយរងគ្រោះនៅក្នុងពន្ធនាគារ និងខាងក្រៅពន្ធនាគារ ។
- ដើម្បីឆ្លើយតបទៅនឹងករណីរំលោភសិទ្ធិសនុស្សដ៏ធ្ងន់ធ្ងរ និងពិនិត្យព្យាបាលជម្ងឺជនរងគ្រោះស្របទៅតាមប្រធានបទដើម្បីផ្តត់ផ្តង់ទៅលើបុគ្គលដែលគេបណ្តេញចេញ និងប្រឆាំងការរំលោភបំពានជាដើម ។
- ដើម្បីព្យាបាលអ្នកជម្ងឺ រៀបចំឱ្យមានការបញ្ជូនទៅមន្ទីរពេទ្យបង្អែក ផ្តល់សម្ភារៈមូលដ្ឋាន និងប្រមូលផ្តុំទិន្នន័យពីការរងរបួស និងជម្ងឺផ្សេងៗ ។
- ដើម្បីផ្តល់សេវាកម្មវេជ្ជសាស្ត្រជូនជនងាយរងគ្រោះបំផុតដែលកំពុងរស់នៅក្នុងតំបន់បណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅរាជធានីភ្នំពេញ ។

**លទ្ធផលសំរេចបាន**

ការិយាល័យពេទ្យមានសកម្មភាពសំខាន់ៗចំនួនបីគឺ:

- ការឃ្លាំមើលសុខភាពអ្នកទោស និងមន្ត្រីពន្ធនាគារនៅក្នុង ១២ ពន្ធនាគារ ។
- ការផ្តល់សេវាកម្មវេជ្ជសាស្ត្រនៅតំបន់តាំងទីលំនៅថ្មី នៅភូមិអណ្តូង និងតំបន់តាមបណ្តាខេត្តដែលត្រូវបានគេបណ្តេញចេញ ឬតំបន់តាំងទីលំនៅថ្មី ។
- ការឃ្លាំមើលព្រឹត្តិការណ៍សិទ្ធិមនុស្ស រួមមាន បាតុកម្ម កូដកម្ម ។
- ផ្តល់ព័ត៌មានស្តីពីអាហាររូបត្ថម្ភទៅដល់កុមារ និងក្រុមគ្រួសារនៅខេត្តកំពង់ស្ពឺ ។
- ផ្តល់ការព្យាបាលជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ។

## សេវាកម្មសុខភាពនៅពន្ធនាគារ

នៅក្នុងឆ្នាំ២០០៨ ការិយាល័យពេទ្យបានផ្ដល់ការព្យាបាលដល់អ្នកជំងឺនៅក្នុងពន្ធនាគារមានចំនួន ៨,៥៩២ នាក់ ក្នុងនោះមានស្ត្រី ១,០៩៧នាក់ ដែលទូរលេខមានការកើនឡើងអ្នកជម្ងឺ ១៧៤នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ។





តារាងខាងក្រោមបង្ហាញប្រាប់ពីចំនួនអ្នកជម្ងឺដែលទទួលការព្យាបាល :

**ចំនួនអ្នកដែលទទួលបានការព្យាបាលពីការិយាល័យពេទ្យសម្រាប់កម្មវិធីពន្ធនាគារក្នុងឆ្នាំ២០០៨**

| | ពន្ធនាគារ | ចំនួនពិនិត្យជម្ងឺអ្នកទោស | | ចំនួនព្យាបាលមន្ត្រីពន្ធនាគារ | | សរុបការព្យាបាលជម្ងឺ | ការចុះទៅពន្ធនាគារ |
|---|---|---|---|---|---|---|---|
| | | បុរស | ស្ត្រី | បុរស | ស្ត្រី | | |
| 1 | ទួលស្លែង | ២៣ | ០ | ៥០ | ០ | ៧៣ | ១១ |
| 2 | ប៉េហ្សិ | ៣៧២ | ៣០ | ១៩ | ០ | ៤២១ | ១១ |
| 3 | តាខ្មៅ | ៤៦៣ | ១០៣ | ២៤ | ០ | ៥៩០ | ១១ |
| 4 | ព្រៃវែង | ៥៧២ | ៤៧ | ៧៦ | ១៣ | ៧០៨ | ៩ |
| 5 | ស្វាយរៀង | ៤០៣ | ៥៩ | ៩០ | ១៨ | ៥៧០ | ៩ |
| 6 | តាកែវ | ៧៤១ | ១០៦ | ១០៥ | ១៥ | ៩៦៧ | ១១ |
| 7 | ក្រុងព្រះសីហនុ | ៦១៥ | ៧៤ | ៣៩ | ៣ | ៧៣១ | ១១ |
| 8 | កោះកុង | ៤០៣ | ៧៩ | ២៨ | ៧ | ៥១៧ | ១១ |
| 9 | ពោធិ៍សាត់ | ២៣៨ | ២៨ | ៣៧ | ៥ | ៣០៨ | ១០ |
| 10 | បាត់ដំបង | ១៣៨៥ | ២៧២ | ៣៤ | ០ | ១៦៩១ | ១០ |
| 11 | កំពង់ធំ | ៧២៨ | ៩៨ | ៤៤ | ១៣ | ៨៨៣ | ៩ |
| 12 | កំពង់ចាម | ៩៦៧ | ១២៣ | ៣៩ | ៤ | ១១៣៣ | ៩ |
| **ចំនួនសរុប** | | **៦៩១០** | **១០១៩** | **៥៨៥** | **៧៨** | **៨៥៩២** | **១២២** |

ដើម្បីពង្រឹងគុណភាព និងបរិមាណចំណីអាហារដែលបានផ្តល់ដល់អ្នកទោស ក្រុមគ្រូពេទ្យបានផ្តល់គ្រាប់ពូជបន្លែ និងសម្ភារៈសម្រាប់ដាំដុះទៅដល់ពន្ធនាគារចំនួន ១៦ នៅខែមេសា ឆ្នាំ២០០៨។ ពន្ធនាគារដែលត្រូវផ្តល់ឱ្យរួមមានៈ ខេត្តព្រះសីហនុ កោះកុង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ ត្រពាំងថ្លុង កំពត តាខ្មៅ កំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកំពង់ចាម។

**សេវាកម្មសម្រាប់ជនរងគ្រោះដោយការបណ្តេញចេញ/តំបន់ទើបតាំងទីលំនៅថ្មី និងជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស**

នៅក្នុងឆ្នាំ២០០៨ ការិយាល័យពេទ្យបានផ្តល់សេវាព្យាបាលដល់ជនរងគ្រោះដោយសាររំលោភសិទ្ធិមនុស្ស ចំនួន៣៩២នាក់ (ស្ត្រី ២៦៥នាក់) និងជនរងគ្រោះដោយសារករណីជម្លោះដីធ្លី និងការបណ្តេញចេញ រួមទាំងចុះពិនិត្យអ្នកជម្ងឺដល់កន្លែង មន្ទីរពេទ្យបង្អែក សម្ភារៈថ្នាំពេទ្យ និងអាហារបន្ថែម មានចំនួន ១១,០៣៨ នាក់ (ស្ត្រី ៧,៣៦២ នាក់)។

ក្រៅពីធ្វើការព្យាបាល ក្រុមគ្រូពេទ្យធ្វើការអនុវត្តន៍ការបង្ការ ដើម្បីពង្រឹង និងលើកកម្ពស់ផ្នែកសុខភាពមួយចំនួនដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ នៅពាក់កណ្តាល ខែមីនា រហូតដល់ចុងខែមិថុនា ឆ្នាំ២០០៨ ក្រុមគ្រូពេទ្យបានចាប់ផ្តើមសហការជាមួយក្រសួងសុខាភិបាល ដើម្បីផ្តល់ការចាក់ថ្នាំបង្ការជម្ងឺតេតាណូស របេង ខាន់ស្លាក់ គ្រុនស្វិតដៃជើង ក្អកមាន់ កញ្ជ្រិល ទៅដល់កុមារចំនួន ១,១៥៨នាក់ និង ៣៤៧នាក់ ជាក្មេងស្រីពេញវ័យ។

**ការកសាងសមត្ថភាព និងបណ្តាញ**

ដើម្បីបង្កើនសមត្ថភាព បុគ្គលិកការិយាល័យពេទ្យបានរៀបចំវគ្គបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រប្រចាំខែ ចំនួន ១០ ដង។ លើសពីនេះទៅទៀត មានបុគ្គលិកម្នាក់ត្រូវបានបញ្ជូនទៅប្រជុំជារៀងរាល់ខែដោយសមាជិកអង្គការសម្រាប់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាផ្នែកសុខភាព ហើយបុគ្គលិកម្នាក់ទៀតបានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយបណ្តាញសិទ្ធិមនុស្ស និងអ្នកផ្ទុកមេរោគអេដស៏/នៅកម្ពុជា ហៅកាត់ថា (CHRAN) ។

**ឥទ្ធិពល**

- ការិយាល័យពេទ្យបានផ្តល់ការព្យាបាលទៅដល់ប្រជាជនជាង ២០,០០០នាក់ នៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ២០០៨នេះ។ ប្រសិនបើគ្មានការិយាល័យនេះទេ ប្រជាជនទាំងនេះនឹងមានការឈឺចាប់ ទាំងផ្នែករាងកាយ ស្មារតី និងពិការភាពផ្សេងៗ។

- ការស្វែងរកអោយឃើញនូវវេជ្ជសាស្ត្រ គឺបានបំពេញការងាររបស់អ្នកឃ្លាំមើល និងអ្នកទាក់ទាញមតិគាំទ្រ និងជាភស្តុតាងនៃការព្យាបាល សំរាប់ករណីសិទ្ធិមនុស្សដ៏សំខាន់ និងការកើតឡើងផ្សេងៗ ។
- ការព្យាបាលបានផ្តល់ជូនទៅដល់ជនរងគ្រោះដែលត្រូវគេបំពារបំពានបានទាន់ពេល ដែលធ្វើអោយមានការទុកចិត្តពីសំណាក់អតិថិជន ហើយធ្វើអោយអង្គការលីកាដូ អង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូផ្សេងៗ អ្នកតំណាងច្បាប់ និងអ្នកទាក់ទាញមតិគាំទ្រអន្តរជាតិផ្តល់ជូនសេវាកម្ម មានរយៈពេលវែងក្នុងនោះមានការឃ្លាំមើលជាដើម ។
- លើសពីការព្យាបាលនេះ ការិយាល័យពេទ្យក៏បានធ្វើការជាមួយអ្នកទោស និងមន្ត្រីពន្ធនាគារ និងលើកឡើងអំពីការយល់ដឹងពីភាគីនិមួយៗ ដែលរំពឹងទទួលបាននូវការព្យាបាល និងធ្វើការតស៊ូដើម្បីទប់ស្កាត់នូវវិប្បធមិហិង្សា ដែលតែងតែកើតឡើងនៅក្នុងប្រព័ន្ធពន្ធនាគារ ។
- ការិយាល័យពេទ្យនៅតែបានបន្តផ្តល់ការព្យាបាល និងអាហារ ទៅដល់អ្នកភូមិ ភ្លុកធ្មុងនៅក្នុងខេត្តកំពង់ស្ពឺ ដែលជាផ្នែកមួយនៃកម្មវិធីអាហារូបត្ថម្ភ ដើម្បីប្រឆាំងភាពក្រីក្រ និងការពារការខ្វះខាតអាហារូបត្ថម្ភនៅក្នុងភូមិ ជាពិសេសកុមារ ។

□□□

# ការិយាល័យធនធានឯកសារ និងព័ត៌មាន

**គោលបំណង**




- ផ្តល់ឱ្យលីកាដូនូវឧបករណ៍ វិធីសាស្ត្រ នីតិវិធី ទម្រង់កម្មវិធី និងអ្នកជំនាញការដើម្បីបង្កើននូវភាពត្រឹមត្រូវ មិនលំអៀង សុក្រិតភាព និងភាពដែលអាចជឿទុកចិត្តលើរបាយការណ៍និងដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងការរក្សាទុកជាសម្ងាត់ចំពោះទិន្នន័យនៃការរំលោភសិទ្ធិមនុស្ស ។
- បង្កើនការសហប្រតិបត្តិការណ៍ និងពង្រឹងគុណភាពព័ត៌មានដែលបានចែកចាយព័ត៌មានទៅតាមបណ្តាការិយាល័យផ្សេងៗទៀតនៅក្នុងអង្គការលីកាដូ ។
- បង្កើនជំនាញបច្ចេកទេសដល់បុគ្គលិក ទាំងការប្រមូលយកព័ត៌មាន ដំណើរការព័ត៌មាន ការវិភាគព័ត៌មាន និងការយល់ដឹងទៅលើបណ្តាញប្រព័ន្ធកុំព្យូទ័រ ។
- ដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដោយប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវសិក្សាសង្គម និងស្វែងរកការគាំទ្រមតិ ។
- បង្កើតឱ្យលីកាដូនូវធនធានព័ត៌មានដែលអាចជឿជាក់បានសម្រាប់ស្ថាប័នថ្នាក់ជាតិ ថ្នាក់តំបន់ និងការស្វែងរកមតិគាំទ្រទៅថ្នាក់អន្តរជាតិ ។
- ពង្រឹងបណ្តាញព័ត៌មានជាមួយអង្គការជាតិ និងអន្តរជាតិនានា ។
- ឯកសារ និងរបាយការណ៍លើកម្មវិធី និងសកម្មភាពគម្រោងជាលទ្ធផលសម្រាប់គោលបំណងខាងក្នុងអង្គការ និងម្ចាស់ជំនួយរបស់អង្គការលីកាដូ ។
- ផ្តល់វីឌីអូ កាមេរ៉ា និងជំនាញបច្ចេកទេសទៅដល់សកម្មជននៅតាមសហគមន៍ ដើម្បីប្រមូលខ្សែរអាត់ និងជួយពួកគេដើម្បីបង្កើតឧបករណ៍សម្រាប់គម្រោងការតស៊ូមតិ ។

**លទ្ធផលសំរេចបាន**

ការងារចំបងរបស់ការិយាល័យធនធានឯកសារ និងព័ត៌មាន គឺធ្វើការចងក្រង និងបកប្រែករណីសំនុំរឿងពីការិយាល័យផ្សេងៗរបស់លីកាដូ (ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ការិយាល័យសិទ្ធិកុមារ ការិយាល័យប្រឆាំងអំពើទារុណកម្ម និងការិយាល័យសិទ្ធិស្ត្រី) ទៅក្នុងប្រព័ន្ធទិន្នន័យកណ្តាលមួយដែលមានភាពងាយស្រួល និងមានសុវត្ថិភាពខ្ពស់ក្នុងការរក្សាទុក និងការវិភាគព័ត៌មាន ។ លទ្ធផលការងាររបស់ការិយាល័យធនធានឯកសារ និងព័ត៌មានផ្សេងៗទៀតមានដូចជា: ការសម្របសម្រួលលើការចែកចាយព័ត៌មានជាមួយ

ការិយាល័យផ្សេងៗ ការរៀបចំវិភាគទិន្នន័យសម្រាប់ប្រើប្រាស់ក្នុងការតស៊ូមតិ ការថែរក្សាធនធានឯកសារ ការបង្កើតឧបករណ៍ សម្រាប់តស៊ូមតិ និងការកែប្រែគេហទំព័ររបស់អង្គការលីកាដូ។




នៅក្នុងពាក់កណ្តាលឆ្នាំ២០០៨ ការិយាល័យធនធានឯកសារ និងព័ត៌មានបានផលិត និងបោះពុម្ពព្រឹត្តិបត្រខាងក្នុងអង្គការចំនួន ៨ លេខ ខាងក្រៅអង្គការគម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ (Adopt-A-Prison Project) ចំនួន ១ អត្ថបទព័ត៌មានចំនួន ១៣ និងសេចក្តីថ្លែងការណ៍ចំនួន ១១ ហើយក៏បានផលិតព័ត៌មានសោតទស្សន៍ភាសាខ្មែរចំនួន ១២ សម្រាប់ដាក់លើគេហទំព័រអង្គការលីកាដូ។

**របាយការណ៍ (សរសេរ សោតទស្សន៍ និង វីឌីអូ)**

ការិយាល័យធនធានឯកសារ និងព័ត៌មាន ក៏បានបោះពុម្ពរបាយការណ៍ចំនួន៣ ជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយថត និងផលិតរបាយការណ៍សោតទស្សន៍ជាភាសាខ្មែរសម្រាប់អង្គការលីកាដូ ចំនួន ២ គឺ:



- ស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជាឆ្នាំ២០០៧: រឿងនិទានម្តាយ និងកូនស្រី ម្នាក់
- ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ: នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្រប់គ្រងប្រព័ន្ធព័ត៌មានកម្ពុជា ដោយរបៀបណា (ខែឧសភា ឆ្នាំ ២០០៨)
- ការវាយប្រហារ និងគម្រាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាឆ្នាំ២០០៧ (ខែសីហា ឆ្នាំ២០០៨)

របាយការណ៍សោតទស្សន៍អាចជួយក្នុងការផ្សព្វផ្សាយរបាយការណ៍ទាំងនេះឱ្យកាន់តែទូលំទូលាយទៅសហគមន៍នៅក្នុងប្រទេសកម្ពុជាដែលភាគច្រើនមិនចេះអក្សរហើយរស់នៅតាមបណ្តាខេត្តនានា ឬរស់នៅក្រៅប្រទេស ហើយពួកគេអាចដោនឡូដយករបាយការណ៍ទាំងនោះបាន។

នៅឆ្នាំ២០០៨ របាយការណ៍ចំនួន ៨,៦៦៧ ច្បាប់ត្រូវបានបោះពុម្ព ដែលមានចំនួន ៤,៥១៨ ជាភាសាខ្មែរ និង ៤,១៤៩ ជាភាសាអង់គ្លេស ហើយក៏មាន ៧,៤៥០ ស៊ីឌីរបាយការណ៍សោតទស្សន៍ជាភាសាខ្មែរត្រូវបានផលិត និងបោះពុម្ពផ្សាយផងដែរ។




ដើម្បីរំលឹកថ្ងៃទិវាបុណ្យសិទ្ធិមនុស្សអន្តរជាតិ ថ្ងៃទី១០ ខែធ្នូ និងជាខួបលើកទី ៦០នៃសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស។ ការិយាល័យធនធានឯកសារ និងព័ត៌មាន បានបោះពុម្ពផ្សាយកូនសៀវភៅស្តីពីថ្ងៃទិវាបុណ្យសិទ្ធិមនុស្សអន្តរជាតិ ដែល

សៀវភៅនេះបានពន្យល់ពីចំនុចសំខាន់បីនៃសិទ្ធិមនុស្សដែលមានចែងក្នុងសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថា: "សេរីភាពក្នុងការធ្វើដំណើរ សេរីភាព ក្នុងការនិយាយស្ដី បញ្ចេញមតិ និងសេរីភាពក្នុងការជួបប្រជុំ និងបង្កើតសមាគម"។ កូនសៀវភៅនេះ បានទាញយកករណីដែលកើតមានឡើងក្នុងឆ្នាំ២០០៨ នៅពេលដែលសិទ្ធិទាំងនោះ មិនត្រូវបានគោរពដោយរាជរដ្ឋាភិបាល ហើយវាផ្ដល់ផលប្រយោជន៍ផងដែរថា ពួកគេត្រូវធ្វើដូចម្ដេចនៅពេលដែលរាជរដ្ឋាភិបាលព្យាយាមដាក់កំហិតលើពួកគេ។ ការិយាល័យធនធានឯកសារ និងព័ត៌មាន បានបោះពុម្ពកូនសៀវភៅនេះ ចំនួន ៥,៦៥០ ក្បាល ដែលមានចំនួន ៥,០០០ក្បាល ជាភាសាខ្មែរ និងចំនួន៦៥០ក្បាល ជាភាសាអង់គ្លេស ហើយសៀវភៅច្រើនជាង ៥,០០០ក្បាល ត្រូវបានចែកចាយកំឡុងពេលទិវាបុណ្យសិទ្ធិមនុស្សអន្តរជាតិ។ ការចែកនេះត្រូវបានធ្វើឡើងនៅកន្លែងប្រារព្ធពិធីចំនួន២៦ នៅក្នុង ១៤ ខេត្ត ដែលលីកាដូបានជួយរៀបចំ។

ការិយាល័យធនធានឯកសារ និងព័ត៌មាន ក៏បានផលិតខ្សែវីឌីអូឯកសារខ្លី៧ចំនួន៣ ដែលខ្សែវីឌីអូនេះស្ដីពីការរំលោភយកដីនៅក្នុងខេត្តបាត់ដំបង ការរំលឹក១,៧០០ថ្ងៃនៃការជាប់ពន្ធនាគារដោយគ្មានទោសរបស់ ប៊ិន សំណាង និង សុខ សំអឿន និងវីឌីអូបង្ហាញពីការចេញផ្សាយរបាយការណ៍ស្ដីពីការវាយប្រហារនឹងគម្រាមកំហែងអ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ឆ្នាំ២០០៧។ វីឌីអូនេះ ត្រូវបានចេញផ្សាយនៅលើគេហទំព័រអង្គការលីកាដូ ហើយវីឌីអូក៏បានថតចំលងចំនួន ៥០ ឌីវីឌី និង ៥០ វីស៊ីឌី សំរាប់ផ្ដល់ជូនដល់ម្ចាស់ជំនួយផងដែរ។ ផលិតផលវីឌីអូ ទាំងការថត និងការកែសម្រួល គឺជាផលិតផលមិនទាន់សំរេចហើយវានឹងទទួលបានជោគជ័យក្នុងវគ្គហ្វឹកហ្វឺនជំនាញថ្មីរបស់ការិយាល័យធនធានឯកសារ និងព័ត៌មាន ហើយនឹងផ្ដល់អោយលីកាដូ នូវឧបករណ៍ទាក់ទាញមតិគាំទ្រកាន់តែមានប្រសិទ្ធិភាពខ្ពស់។

លើសពីនេះ ការិយាល័យធនធានឯកសារ និងព័ត៌មានបានផលិត ឌីវីឌី ពីរភាសាចំនួន ១,៨០៥ ដែល ៧៦០ ជាភាសាខ្មែរ និង១,០៤៥ ជាភាសាអង់គ្លេសផលិតដោយលីកាដូកាណាដា ដែលជាអង្គការក្រៅរដ្ឋាភិបាល សហការជាមួយអង្គការលីកាដូ។

ឌីវីឌី ទាំងនោះរួមមាន:

- ៣ ថ្ងៃនៅដីក្រហម
- រឿងពិតដីក្រហម
- សម្លេងកម្ពុជា
- រូបថតភូមិអណ្ដូង
- ពីរឆ្នាំយូរណាស់



( ៨០ ) របាយការណ៏សកម្មភាពប្រចាំឆ្នាំរបស់អង្គការលីកាដូ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨

- រួចផុតពីការឃ្លាំមើល
- ៧៩ លានដុល្លារសំរាប់អ្នកណា?

បញ្ជីឌីវីឌីសំខាន់ខាងលើ គឺបង្ហាញពីចំណងជើងនៃការបណ្តេញចេញពីដីនៅក្នុងទីក្រុងភ្នំពេញ ជាពិសេសចំពោះប្រជាជនរស់នៅសំបុកចាប សហគមន៏ដីក្រហម និងបឹងកក់។

**គេហទំព័ររបស់អង្គការលីកាដូ**

នៅពាក់កណ្តាលឆ្នាំ២០០៨ នេះគេហទំព័ររបស់ លីកាដូបានបង្ហាញនូវការរីកចំរើនកាន់តែច្រើន និងប្រសើរឡើងជាងមុន។ សេចក្តីថ្លែងការណ៏ជាច្រើន ត្រូវបានផ្សព្វផ្សាយព្រមជាមួយ និងរូបភាពការរំលោភសិទ្ធិមនុស្ស។

ស្ថិតិខ្លះសម្រាប់គេហទំព័រអង្គការលីកាដូមានដូចជា :

- អ្នកចូលទស្សនាគេហទំព័រជា មធ្យម ៥,០០០ នាក់ក្នុងមួយខែ។
- ប្រទេសប្រាំ ដែលនិយមចូលទស្សនាគេហទំព័រមានៈ

១. សហរដ្ឋអាមេរិច ( ១៦៩,០០០ ទំព័រ)
២. អូស្ត្រាលី ( ២៩,១០០ទំព័រ)
៣. សហគមន៏អ៊ឺរ៉ុប ( ៨,៧០០ ទំព័រ)
៤. កម្ពុជា ( ៧,៥៦៧ ទំព័រ)
៥. អង់គ្លេស ( ៥,៨០០ទំព័រ)

- ទំព័រ និងប្រធានបទសំខាន់ៗបួន ដែលបង្ហាញនៅលើគេហទំព័រៈ

១. កម្រងរូបភាព
២. របាយការណ៏
៣. សេចក្តីថ្លែងការណ៏
៤. របាយការណ៏សោតទស្សន៏

- ពាក្យស្វែងរកសំខាន់ៗ ចំនួន បី ដែលប្រើសម្រាប់ចូលក្នុងគេហទំព័រៈ

១. អង្គការលីកាដូ
២. សិទ្ធិមនុស្ស
៣. ពលកម្មកុមារនៅកម្ពុជា

**គម្រោងម៉ាស៊ីនថតរូបខ្នាតតូច (Flip Camera Project)**



នៅក្នុងឆ្នាំ២០០៨ ការិយាល័យធនធានឯកសារ និងព័ត៌មាន បានបង្កើតគម្រោងម៉ាស៊ីនថតរូបខ្នាតតូចក្រោមគម្រោងជំនួយឧបត្ថម្ភរបស់អង្គការក្រៅរដ្ឋាភិបាលជាដៃគូ WITNESS ។ WITNESS បានផ្តល់កាមេរ៉ាដៃតូចៗ ចំនួន ៥០ សម្រាប់ចែកជូនដល់សកម្មជននៅតាមសហគមន៍ ដែលមកពីបណ្តាខេត្តផ្សេងៗនៅក្នុងទូទាំងប្រទេសកម្ពុជា សម្រាប់ថតយកករណីរំលោភបំពានលើសិទ្ធិមនុស្ស ។ ម៉ាស៊ីនថតជាង៣០ ត្រូវបានចែកចាយពេញមួយឆ្នាំ ហើយខ្សែអាត់វីឌីអូ រំលោភសិទ្ធិមនុស្ស និងហេតុការណ៍ផ្សេងៗត្រូវបានថតជាពិសេសការរំលោភដីធ្លី ។ ខ្សែអាត់នេះត្រូវបានផលិតជាវិឌីអូសម្រាប់ការតស៊ូមតិផង និងប្រើសំរាប់សកម្មជនសហគមន៍ដើម្បីជាឯកសាររំលោភសិទ្ធិមនុស្សនៅក្នុងសហគមន៍ ។

**ប្រព័ន្ធទិន្នន័យ (Database)**

នៅខែមករា ឆ្នាំ២០០៨ លីកាដូ បានកែប្រែប្រព័ន្ធទិន្នន័យថ្មីដែលល្អប្រសើរពីប្រព័ន្ធទិន្នន័យចាស់ដែលបង្កើតឡើងនៅឆ្នាំ២០០៤។ ប្រព័ន្ធត្រូវផ្លាស់ប្តូរ ប្រព័ន្ធទិន្នន័យចាស់លែងប្រើដោយសារតែមិនអាចបំពេញតំរូវការគ្រប់គ្រាន់ដើម្បីទាញរកព័ត៌មាន និងបង្កើតស្ថិតិ។ ប្រព័ន្ធទិន្នន័យថ្មីបង្កើតឡើងពីភាសា MySQL ប្រើប្រាស់ជាមួយ Mozilla FireFox ដែលបានបញ្ចប់នៅក្នុងខែកុម្ភៈ និងចាប់ដំណើរការនៅខែមីនា ឆ្នាំ២០០៨។

ឥឡូវប្រព័ន្ធទិន្នន័យថ្មីនេះ ត្រូវបានប្រើប្រាស់ដោយបុគ្គលិកការិយាល័យធនធានឯកសារ និងព័ត៌មានសំរាប់បញ្ចូលទិន្នន័យនិងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សដើម្បីអង្កេតមើលស្ថានភាពសិទ្ធិមនុស្ស និងដើម្បីជាឯកសារសម្រាប់ជាព័ត៌មានបន្ថែម។ លីកាដូ អាចប្រើប្រព័ន្ធទិន្នន័យថ្មីនេះ ដើម្បីបង្កើនភាពត្រឹមត្រូវ មិនលំអៀង សុក្រិត និងភាពដែលអាចជឿទុកចិត្តទៅលើរបាយការណ៍ និងសម្ភារៈសម្រាប់ការតស៊ូមតិ។ លីកាដូ ក៏អាចធ្វើការចែកចាយព័ត៌មានលើករណីសិទ្ធិមនុស្ស និងស្ថិតិជាមួយអង្គការដ៏ទៃទៀតដែលជាដៃគូ ជាពិសេសករណីរំលោភដីធ្លី ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរ។

នៅឆ្នាំ២០០៨នេះ ការិយាល័យធនធានឯកសារ និងព័ត៌មាន បានបញ្ចូល និងពិនិត្យឡើងវិញនូវករណីរឿងចំនួន៣,៥៦៨ ករណី នៅឆ្នាំ២០០៣ ដល់ឆ្នាំ២០០៧ និង ចំនួន៨៥២ ករណី ក្នុងឆ្នាំ២០០៨ នៅក្នុងប្រព័ន្ធទិន្នន័យថ្មី។ កំឡុងឆ្នាំ២០០៩ នេះ ការិយាល័យមានគម្រោងស្រង់យកករណីសំនុំរឿងពីឆ្នាំ២០០០ ដល់ ឆ្នាំ២០០២ ដែលរក្សាទុកក្នុងប្រព័ន្ធទិន្នន័យចាស់ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យថ្មី។

(៨២) របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់អង្គការលីកាដូ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨




Statistic Form - LICADHO|DB

Monitoring Offices & Cases/Month 2008 Table

| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Battambang Office | 2 | 3 | 1 | 3 | 1 | 3 | 5 | 1 | 1 | 3 | 3 | 1 |
| B. Meanchey Office | 3 | 4 | 3 | 4 | 2 | 5 | 7 | 3 | 4 | 2 | 6 | 2 |
| K. Thom Office | 2 | 0 | 2 | 2 | 2 | 4 | 4 | 1 | 1 | 1 | 5 | 4 |
| K. Chhnang Office | 2 | 1 | 1 | 1 | 1 | 2 | 3 | 2 | 1 | 1 | 1 | 1 |
| K. Speu Office | 1 | 3 | 1 | 0 | 3 | 2 | 3 | 1 | 1 | 0 | 2 | 2 |
| Sihanoukville Office | 1 | 3 | 4 | 4 | 1 | 2 | 1 | 2 | 0 | 2 | 4 | 2 |
| Kampot Office | 2 | 2 | 0 | 2 | 2 | 2 | 1 | 2 | 2 | 2 | 1 | 3 |
| Koh Kong Office | 1 | 2 | 2 | 0 | 2 | 0 | 1 | 3 | 2 | 2 | 2 | 1 |
| K. Cham Office | 2 | 0 | 1 | 1 | 1 | 1 | 6 | 9 | 3 | 4 | 2 | 0 |
| Phnom Penh Office | 3 | 7 | 8 | 3 | 5 | 10 | 9 | 7 | 8 | 6 | 5 | 3 |
| Pursat Office | 1 | 1 | 2 | 0 | 1 | 2 | 3 | 3 | 2 | 1 | 2 | 1 |
| Siem Reap Office | 1 | 4 | 3 | 8 | 2 | 6 | 8 | 2 | 1 | 2 | 2 | 1 |
| Svay Rieng Office | 0 | 2 | 2 | 0 | 3 | 4 | 1 | 0 | 1 | 2 | 0 | 0 |

Rendered on 2009-02-18 (11:02:45)

Monitoring Offices & Cases/Month 2008 Chart




## ការកសាងសមត្ថភាព

មន្ត្រីឯកសារ-ទិន្នន័យចំនួន ៣ នាក់បានចូលសិក្សាវគ្គភាសាអង់គ្លេសនៅសាលា ACE ចំនួន ១ ឆមាស ពីខែមករា និងខែកុម្ភៈ ។

## ឥទ្ធិពល

- ស្ថិតិនៃការរំលោភបំពានសិទ្ធិមនុស្ស ត្រូវបានធ្វើឡើងឱ្យមានភាពងាយស្រួល និងកត់ត្រាទុកយ៉ាងត្រឹមត្រូវទៅក្នុងប្រព័ន្ធទិន្នន័យថ្មី ។ ដែលនេះធ្វើឱ្យមានការកើនឡើងនូវប្រសិទ្ធិភាព ក្នុងការរក្សាទុកករណីសំនុំរឿងដែលបានតាមដានដោយការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ។
- អត្ថបទព័ត៌មាន និងរឿងដែលទទួលជោគជ័យ (Success Stories) ត្រូវចេញផ្សាយនៅលើគេហទំព័រដែលបានផ្តល់សំភារៈឥតគិតថ្លៃទៅឱ្យសាធារណៈជនលើប្រធានបទបញ្ហាសិទ្ធិមនុស្ស ។

- បង្កើនសមត្ថភាពរបស់បុគ្គលិក ការិយាល័យធនធានឯកសារ និងព័ត៌មានក្នុងការថែរក្សាទុកទិន្នន័យឱ្យទាន់ពេលវេលា និងផលិតសម្ភារៈតស៊ូមតិ ។
- ព្រឹត្តិបត្រខាងក្នុងអង្គការជួយឱ្យបុគ្គលិកនៃអង្គការលីកាដូ បានចែករំលែកពីបញ្ហាសង្គម និងបញ្ហារបស់បុគ្គលិក ។
- ផលិតផលនៃវីឌីអូសម្រាប់តស៊ូមតិបានផ្តល់អោយលីកាដូ នូវគុណភាពខ្ពស់ដែលអាចងាយស្រួលដំណើរការនៅតាមសហគមន៍រហូតដល់ថ្នាក់អន្តរជាតិ ។
- លទ្ធភាពរបស់ការិយាល័យធនធានឯកសារ និងព័ត៌មាន ក្នុងការជួយដល់គ្រប់ទំរង់ទាំងអស់នៃការផលិតរបាយការណ៍ជាសាធារណៈរបស់អង្គការលីកាដូ ( ការស្រាវជ្រាវ ការចងក្រងឯកសារ ការបកប្រែ ការកែតំរូវ និងការថតជាសោតទស្សន៍) បានបង្កើនសមត្ថភាពឱ្យអង្គការលីកាដូក្នុងការផលិតរបាយការណ៍ឱ្យទាន់ពេល ។
- បង្កើនភាពត្រឹមត្រូវ និងភាពដែលអាចជឿទុកចិត្តលើសម្ភារៈនៃការតស៊ូមតិរបស់លីកាដូ ដែលរួមមានរបាយការណ៍ និងអត្ថបទសង្ខេប ។

□□□

# ការិយាល័យអប់រំសិទ្ធិមនុស្ស



- ដើម្បីផ្តល់ចំណេះដឹងប្រកបដោយប្រសិទ្ធិភាពដល់ប្រជាពលរដ្ឋកម្ពុជា គ្រប់លំដាប់ថ្នាក់ ស្ថានភាពអប់រំ និងកាលៈទេសៈស្តីពីសិទ្ធិមនុស្ស
- ជាសាកល ដែលពួកគេទទួលបានពីអ្នកដទៃ និងមានជាកម្មសិទ្ធិ ។
- ដើម្បីចែករំលែកនូវចំនេះដឹងស្តីអំពីសិទ្ធិមនុស្សទៅដល់បុគ្គលម្នាក់ៗ ក្រុមគ្រួសារនិងសហគមន៍ដូចជា ពួកគេអាចម្ចាស់ការលើសកម្មភាពផ្ទាល់ខ្លួន និងជះឥទ្ធិពលជាវិជ្ជមានទៅលើការដោះស្រាយជម្លោះ ដោយសន្តិវិធី និងការបំពាក់បំប៉នបញ្ចូលគ្នា និងការចូលរួម ។
- ដើម្បីធ្វើការចងភ្ជាប់ និងធ្វើការសាកល្បងទៅលើបណ្តុំដែលជាប់ពាក់ព័ន្ធ ការអនុវត្តន៍ និងវិធីសាស្ត្រសិក្សាដ៏មានប្រសិទ្ធិភាពដើម្បីប្រើប្រាស់យុទ្ធវិធីសម្រាប់សិក្សាដោយយល់ដឹងផ្ទាល់ពីតំរូវការច្បាស់លាស់របស់ក្រុមគោលដៅ ហើយត្រូវបានគេកំណត់ទុកដើម្បីបន្តរំលឹកឡើងវិញនូវការអនុវត្តន៍សិទ្ធិមនុស្សនៅកម្ពុជា ។
- ដើម្បីកំណត់ឱ្យឃើញពីសមាជិកនៅក្នុងសង្គម ហើយដែលក្នុងនោះវាជាតំរូវការចាំបាច់ក្នុងការយល់ដឹងពីសិទ្ធិមនុស្ស ព្រមទាំងសិទ្ធិផ្សេងៗទៀតដែលត្រូវគេរំលោភបំពាន ឬជួបឧបសគ្គ និងអ្នកដែលមានតួនាទីជួយអ្នកទាំងនោះតាមតំរូវការ ។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនិងកម្មវិធីផ្សព្វផ្សាយ ស្តីពីសិទ្ធិមនុស្សដើម្បីធ្វើការជ្រើសរើសយកក្រុមគោលដៅ ។
- ដើម្បីផ្តល់ការណែនាំជាគំនិតឱ្យដល់សហគមន៍ អំពីការឃ្លាំមើល និងសេចក្តីព្រួយបារម្ភទៅលើបញ្ហាសិទ្ធិមនុស្សសម្រាប់អង្គការលីកាដូ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដើម្បីឱ្យមានអាជ្ញាធរចូលរួមច្រើន ។

### លទ្ធផលសំរេចបាន

នៅពាក់កណ្តាលឆ្នាំ២០០៨ សកម្មភាពចំបងរបស់ការិយាល័យអប់រំសិទ្ធិមនុស្សផ្តោតសំខាន់ទៅលើការលើកកំពស់សិទ្ធិមនុស្សដោយបានរៀបចំ និងបើកវគ្គបណ្តុះបណ្តាលស្តីអំពីសិទ្ធិមនុស្សដែលរួមទាំងការធ្វើការផ្សព្វផ្សាយ និងការអភិវឌ្ឍន៍មេរៀនសម្រាប់វគ្គបណ្តុះបណ្តាលសិទ្ធិមនុស្ស ហើយបោះពុម្ពផ្សាយសៀវភៅសិទ្ធិមនុស្ស ។

## សកម្មភាពលើកកម្ពស់ការយល់ដឹងស្តីពីសិទ្ធិមនុស្ស

- វគ្គបណ្តុះបណ្តាលស្តីអំពីសិទ្ធិមនុស្សត្រូវបានផ្តល់ដោយការិយាល័យអប់រំសិទ្ធិមនុស្ស រួមមានវគ្គពិភាក្សាស្តីពីសិទ្ធិមនុស្សចំនួន ៣៤វគ្គ ក្នុងមួយវគ្គកន្លះថ្ងៃ ហើយវគ្គបណ្តុះបណ្តាល ស្តីអំពីសិទ្ធិមនុស្ស ចំនួន ១១វគ្គក្នុងមួយវគ្គមាន ៣ថ្ងៃ និងវគ្គផ្សព្វផ្សាយចំនួន ២៥៦វគ្គ ក្នុងមួយវគ្គមានកន្លះថ្ងៃ មានអ្នកចូលរួមសរុប ចំនួន ១៣,៤២៩នាក់ មាន ៧,៧៧៨នាក់ ជាស្ត្រី។
- ការប្រជុំពិភាក្សាស្តីពីសិទ្ធិមនុស្សចំនួនកន្លះថ្ងៃត្រូវបានរៀបចំ ដើម្បីបម្រើសេចក្តីត្រូវការដល់ជនរងគ្រោះដោយការរំលោភយកដីធ្លី និងបញ្ហាសិទ្ធិមនុស្សផ្សេងទៀតដូចជា អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងរំលោភបំពានការបំភិតបំភ័យខាងនយោបាយ។ អញ្ជើញអាជ្ញាធរមូលដ្ឋាន រួមមាន: មេឃុំ តំណាងក្រុមប្រឹក្សាឃុំ មេភូមិ និងមន្ត្រីនគរបាល ឱ្យចូលរួមដើម្បីមានប្រសាសន៍ឆ្លើយតបទៅនឹងសំនួររបស់សិក្ខាកាមស្តីពីបញ្ហាដែលបានលើកឡើង។
- នៅក្នុងរយៈពេលវគ្គទាំងនេះសម្ភារៈនៃការទាក់ទាញមតិគាំទ្រ គឺត្រូវបានបែងចែក។ តារាងខាងក្រោមនេះបង្ហាញពីវគ្គជាច្រើនដែលបានរៀបចំនិងបង្ហាញថាស្ត្រីបានចូលរួមច្រើនជាងពាក់កណ្តាលនៃសិក្ខាកាមសរុប។

**វគ្គបណ្តុះបណ្តាលដែលបានរៀបចំពី ខែមករា ដល់ ខែមិថុនា ឆ្នាំ២០០៨**

| ប្រភេទវគ្គបណ្តុះបណ្តាល | វគ្គដែលបានរៀបចំ | សិក្ខាកាមដែលបានបណ្តុះបណ្តាល | សិក្ខាកាមស្ត្រី |
|---|---|---|---|
| វគ្គរយៈពេល៣ ថ្ងៃ | ១១ | ៣៣៣ | ២២៨ |
| វគ្គពិភាក្សាចំនួន កន្លះថ្ងៃ | ២៥៦ | ១១,៥០៤ | ៦,៤៨៣ |
| វគ្គផ្សព្វផ្សាយ កន្លះថ្ងៃ | ៣៤ | ១,៥៩២ | ១,០៦៧ |
| **សរុប** | **៣០១** | **១៣,៤២៩** | **៧,៧៧៨** |

## ការបង្កើតកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាល

សកម្មភាពចំបងផ្សេងៗទៀតរបស់ការិយាល័យអប់រំសិទ្ធិមនុស្សដើម្បីធ្វើការអភិវឌ្ឍន៍ ការប្រមូលផ្តុំការបង្កើតការផ្លាស់ប្តូរ និងការកែប្រែសម្ភារៈសម្រាប់ការបណ្តុះបណ្តាលសិទ្ធិមនុស្ស ដើម្បីគាំទ្រក្រុមគោលដៅដែលបានចូលរួមវគ្គបណ្តុះបណ្តាល វគ្គពិភាក្សា និងវគ្គផ្សព្វផ្សាយស្តីពីសិទ្ធិមនុស្ស។ សម្ភារៈរួមមាន ឯកសារសម្រាប់ណែ

នាំ សៀវភៅណែនាំ សៀវភៅរូបភាពសម្រាប់អ្នកចេះ និងមិនចេះអក្សរ ខិត្តប័ណ្ណ កូនសៀវភៅច្បាប់ សន្លឹកប័ណ្ណផ្ទាំងរូបភាព អាវយឺត វិញ្ញាបនបត្រចូលរួមរបស់សិក្ខាកាម ប្រតិទិន និងឯកសារចែកជូនផ្សេងៗទៀត។ គ្រប់សម្ភារៈ សិក្សាទាំងអស់ត្រូវបានធ្វើឡើងជាភាសាខ្មែរ។

**ឯកសារចែកជូននៅក្នុងវគ្គបណ្តុះបណ្តាលត្រូវបានព្រាងឡើងនៅក្នុងពាក់កណ្តាលឆ្នាំ២០០៨ រួមមានៈ**

- លទ្ធិប្រជាធិបតេយ្យពិតប្រាកដ
- ការតស៊ូមតិសម្រាប់សហគមន៍
- សេចក្តីណែនាំសម្រាប់ប្រជាជនទូទៅអំពីច្បាប់នៃការអប់រំ (ដើម្បីអោយយល់ដឹងពីនីតិវិធីឃុំខ្លួនបណ្តោះអាសន្ននៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី)

បន្ថែមទៅលើនេះទៀត មានសកម្មភាពគាំទ្រ ៦ខែ ដំបូងត្រូវបានរៀបចំ និងបោះពុម្ពឡើងវិញ។

**ការបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៨**

| ប្រភេទនៃការបោះពុម្ភ | ចំនួននៃការបោះពុម្ភ |
|---|---|
| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា | ១៨,០០០ |
| ច្បាប់ភូមិបាល | ៨,០០០ |
| លទ្ធិប្រជាធិបតេយ្យពិតប្រាកដ | ៣,១៧៥ |
| ការណែនាំអំពីការតស៊ូមតិ | ៣,២០០ |
| ខិត្តប័ណ្ណ សិទ្ធិដីធ្លី | ១០,០០០ |
| ច្បាប់ការពារអំពើហិង្សាក្នុងគ្រួសារ | ៦,០០០ |
| សេចក្តីណែនាំអំពីច្បាប់នៃការអប់រំ | ៥,០០០ |
| **សរុប** | **៥៣,៣៧៥** |

**ការកសាងសមត្ថភាពរបស់បុគ្គលិក**

- បុគ្គលិកការិយាល័យអប់រំសិទ្ធិមនុស្ស បានចូលរួមក្នុងវគ្គអភិវឌ្ឍបុគ្គលិកជាច្រើនលើកដែលរៀបចំឡើងដោយអង្គការលីកាដូ រឺអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូផ្សេងទៀត។ វគ្គទាំងនោះរួមមានជំនាញទំនាក់ទំនងជំនាញ កុំព្យូទ័រវគ្គស្តីអំពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី វគ្គតស៊ូមតិសម្រាប់សហគមន៍ និងវគ្គតស៊ូមតិសម្រាប់ប្រជាជនសាមញ្ញ។

- ដោយមានការផ្លាស់ប្តូរពេលវេលា ច្បាប់ចាស់ និងច្បាប់ថ្មី មានដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ការិយាល័យអប់រំសិទ្ធិមនុស្សបានចំណាយពេលដើម្បីកែសម្រួលនូវសម្ភារៈអប់រំ និងរៀបចំវគ្គកសាងសមត្ថភាពសម្រាប់បុគ្គលិកទាក់ទាញមតិគាំទ្រទាំងអស់។ វគ្គទីមួយស្តីអំពីជំនាញនៃការទំនាក់ទំនងដែលបានធ្វើឡើងនៅថ្ងៃទី២-៣ ខែតុលា ឆ្នាំ២០០៨ ហើយវគ្គទីពីរស្តីពីក្រមរដ្ឋប្បវេណីថ្មី ដែលបានធ្វើឡើងនៅថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០០៨។

**ការបិទការិយាល័យ**

ដោយសារតែអស់ថវិកាសម្រាប់ប្រើប្រាស់ ការិយាល័យអប់រំសិទ្ធិមនុស្សបានឈប់ដំណើរការផ្នែកខ្លះតាំងពីដើមឆ្នាំ២០០៧ ហើយឈប់ដំណើរការទាំងស្រុងនៅខែធ្នូ ឆ្នាំ២០០៨។ ដោយបានធ្វើការសម្រេចចិត្តផង ដែរបន្ទាប់ពីការសង្កេតឃើញមានសហគមន៍ជាច្រើនដែលបានទទួលគុណប្រយោជន៍ពីការអប់រំ ដែលបង្កើនសមត្ថភាពដើម្បីបង្កើតវគ្គអប់រំដោយឯករាជ្យ។ បុគ្គលិកសំខាន់ៗ គឺត្រូវបានផ្ទេរទៅតាមការិយាល័យនិមួយៗនៃអង្គការលីកាដូ។ អ្នកដែលមានជំនាញផ្នែកអប់រំសិទ្ធិមនុស្ស នៅតែបន្តធ្វើការងារនៅតាមការិយាល័យនិមួយៗនៃអង្គការលីកាដូដោយផ្តោតទៅលើតែសិទ្ធិកុមារ និងសិទ្ធិស្ត្រី។

**ឥទ្ធិពល**

- សិក្ខាកាមចូលរួមកំឡុងពេលវគ្គពិភាក្សាស្តីពី សិទ្ធិមនុស្ស វគ្គបណ្តុះបណ្តាល និងវគ្គផ្សព្វផ្សាយក្នុងនោះដែរមានសិក្ខាកាមរួមមួយចំនួនបានលើកឡើងអំពីបញ្ហាផ្ទាល់ខ្លួនរបស់ពួកគាត់ ជាពិសេសបញ្ហារំលោភយកដីធ្លី ការរំលោភបំពានសិទ្ធិសេរីភាពនៃការបញ្ចេញមតិអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន និងការបំភិតបំភ័យខាងនយោបាយ។ បញ្ហាទាំងនោះ ត្រូវបានឆ្លើយតបដោយផ្ទាល់ពីអាជ្ញាធរដែលបានអញ្ជើញជាវាគ្មិន។
- ការបោះឆ្នោតជាតិជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ នៅខែកក្កដា ឆ្នាំ២០០៨ និងថ្ងៃទិវាសិទ្ធិមនុស្សអន្តរជាតិថ្ងៃទី១០ ខែធ្នូ មានសមាជិកសំខាន់ៗមកពីសហគមន៍ និងក្រុមអ្នកចូលរួមក្នុង វគ្គបណ្តុះបណ្តាលនៅការិយាល័យអប់រំសិទ្ធិមនុស្ស។ ការិយាល័យអប់រំសិទ្ធិមនុស្ស គឺជាកន្លែងចែកជូនសម្ភារៈសម្រាប់ពួកគាត់។
- ឯកសារថតចម្លងជាង ១,០០០ ច្បាប់ នៃការិយាល័យអប់រំសិទ្ធិមនុស្ស ត្រូវបានស្នើសុំដោយសមាជិកសហគមន៍ និងចែកជូនជាសាធារណៈជារៀងរាល់ខែ។
- ការិយាល័យអប់រំសិទ្ធិមនុស្សនៅមានចំនុចអន់ខ្សោយ ក្នុងការទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

□□□

# ឧបសម្ព័ន្ធទី១៖ ការចេញផ្សាយផ្សេងៗរបស់អង្គការលីកាដូ ឆ្នាំ២០០៨

## ខែមករា

Document: Dey Krahorm Land Case Explained
January 22, 2008
http://www.licadho-cambodia.org/reports.php?perm=118

Press Release: Company and Authorities Intent on Inciting Disorder in Dey Krahorm
January 08, 2008
http://www.licadho-cambodia.org/pressrelease.php?perm=171

Press Release: Dey Krhorm: Mass eviction feared
January 23, 2008
http://www.licadho-cambodia.org/pressrelease.php?perm=172

Press Release: Chea Vichea, Born Samnang & Sok Sam Oeun-Justice Denied
January 28, 2008
http://www.licadho-cambodia.org/pressrelease.php?perm=173

News: 7NG Company and Phnom Penh Authorities Intent on Inciting Disorder in Cambodia's Capital
January 09, 2008
http://www.licadho-cambodia.org/articles/20080109/69/index.html

News: After Four Years the Cambodian Judiciary Still Denies Justice to Chea Vichea, Born Samnang
January 28, 2008
http://www.licadho-cambodia.org/articles/20080128/70/index.html

Audio News: LICADHO Monthly Newsbrief (Khmer 07:39min)
January 2008
http://www.licadho-cambodia.org/media/index.php?id=69

## ខែកុម្ភៈ

Press Release: Violence against CCAWDU union members at Kingsland Garment factory condemned
Thursday, February 07, 2008
http://www.licadho-cambodia.org/pressrelease.php?perm=174

Press Release: Forced Evictions in Cambodia: Time to End Impunity
February 18, 2008

http://www.licadho-cambodia.org/pressrelease.php?perm=176

Press Release: Condemnation of More Violence in Phnom Penh Land Cases
February 22, 2008
http://www.licadho-cambodia.org/pressrelease.php?perm=175

News: Cambodian Land Eviction Crisis Draws International Attention
February 25, 2008
http://www.licadho-cambodia.org/articles/20080225/71/index.html

News: Tear Gas and Gunfire During Latest Violent Eviction In Cambodia's Capital
February 28, 2008
http://www.licadho-cambodia.org/articles/20080228/72/index.html

Audio News: LICADHO Monthly Newsbrief (Khmer 07:42min)
February 2008
http://www.licadho-cambodia.org/media/index.php?id=48

## ខែមីនា

Documents: LICADHO Annual Activity Report 2007
March 01, 2008
http://www.licadho-cambodia.org/reports.php?perm=117

Documents: Prison Conditions in Cambodia 2007: The Story of a Mother and Child
March 08, 2008
http://www.licadho-cambodia.org/reports.php?perm=116

Press release: International Women's Day 2008
Thursday, March 06, 2008
http://www.licadho-cambodia.org/pressrelease.php?perm=177
Press Release: Unlawful Detention & Alleged Torture by Ministry of Interior
March 11, 2008
http://www.licadho-cambodia.org/pressrelease.php?perm=178

Press Release: Detained Policeman Transferred to Hospital because of Poor Health
March 25, 2008
http://www.licadho-cambodia.org/pressrelease.php?perm=179

Press Release: Concerns over Recent Political Arrest in Kampong Thom Province
March 27, 2008
http://www.licadho-cambodia.org/pressrelease.php?perm=180

News: International Women's Day Highlights Reality of Life in Prison for Cambodian Women
March 17, 2008
http://www.licadho-cambodia.org/articles/20080317/73/index.html

Audio News: LICADHO Monthly Newsbrief (Khmer 07:28min)
March 2008
http://www.licadho-cambodia.org/media/index.php?id=50

## ខែឧសភា

---

Document: Reading Between the Lines: How Politics, Money & Fear Control Cambodia's Media, May 01, 2008
http://www.licadho-cambodia.org/reports.php?perm=119

Documents: Child Workers in Brick Factories: Causes and Consequences
May 08, 2008
http://www.licadho-cambodia.org/reports.php?perm=120

Press Release: 2008 LICADHO Report: Media plagued by fee And corruption
May 02, 2008
http://www.licadho-cambodia.org/pressrelease.php?perm=181

Press Release: Villagers flock to Phnom Penh as Land Crisis continues
May 29, 2008
http://www.licadho-cambodia.org/pressrelease.php?perm=182

News: Radio Free Asia Journalist Flees Cambodia After Once More Receiving Deaths Threats
May 08, 2008
http://www.licadho-cambodia.org/articles/20080508/74/index.html

News: Joint Research Report Released on Impact of Child Labor in Cambodia
May 12, 2008
http://www.licadho-cambodia.org/articles/20080512/76/index.html

Audio News: LICADHO Monthly Newsbrief (Khmer 06:41min)
May 2008
http://www.licadho-cambodia.org/media/index.php?id=70

## ខែមិថុនា

---

Press Release: Government should lift ban on Kratie local radio station
June 05, 2008
http://www.licadho-cambodia.org/pressrelease.php?perm=183

Press Release: Arrest of Moneakseka Khmer Newspaper Editor in Chief Dam Sith
June 09, 2008
http://www.licadho-cambodia.org/pressrelease.php?perm=184

Press Release: Unlawful Detention Camps Must Be Closed
June 28, 2008
http://www.licadho-cambodia.org/pressrelease.php?perm=185

News: Land Disputes Across Cambodia Lead Villagers to Phnom Penh

June 04, 2008
http://www.licadho-cambodia.org/articles/20080604/77/index.html

News: Two Years After their Eviction from the Center of Phnom Penh Villagers are Still Living in Squalor
June 06, 2008
http://www.licadho-cambodia.org/articles/20080606/78/index.html

Audio News: LICADHO Monthly Newsbrief (Khmer 08:17min)
June 2008
http://www.licadho-cambodia.org/media/index.php?id=90

## ខែកក្កដា

News: Cambodian Government Operating Unlawful Detention Camps in Phnom Penh, Locking up Homeless, Beggars and Sex Workers
July 02, 2008
http://www.licadho-cambodia.org/articles/20080702/79/index.html

Press Release: Civil Society coalition calls for an end of political violence during the electoral campaign period
July 17, 2008
http://www.licadho-cambodia.org/press/files/186JointPRPoliticalSituationPreElection08.pdf

Press Release: Crackdown on Attempted Peaceful Protest by Workers and Teachers
July 17, 2008
http://www.licadho-cambodia.org/press/files/188JointStatementCrackdownPeacefulGatheringPreahVihear2008.pdf

Press Release: Arrest of Election Monitor feared
July 31, 2008
http://www.licadho-cambodia.org/press/files/187LICADHOPrNICFECConcern08.pdf

## ខែសីហា

News: Five Cambodian Men Rescued From Trafficking Ring
August 05, 2008
http://www.licadho-cambodia.org/articles/20080805/80/index.html

Document: LICADHO Six Month Activity Report 2008
August 2008
http://www.licadho-cambodia.org/reports.php?perm=125

Audio News: LICADHO Monthly Newsbrief (Khmer 07:54 min)
August 2008
http://www.licadho-cambodia.org/media/index.php?id=142

## ខែកញ្ញា

Document: Attacks & Threats Against Human Rights Defenders in Cambodia 2007
September 2008
http://www.licadho-cambodia.org/reports.php?perm=127

Press Release: Action Needed Over Persecuted Human Rights Defenders
September 25, 2008
http://www.licadho-cambodia.org/pressrelease.php?perm=190

Press Release: Born Samnang and Sok Sam Oeun, Innocent Prisoners - 1,700 days behind Bars
September 23, 2008
http://www.licadho-cambodia.org/pressrelease.php?perm=189

News: Innocent Prisoners in Cambodia Mark 1,700 Days Behind Bars
September 23-25, 2008
http://www.licadho-cambodia.org/articles/20080925/81/index.html

Audio News: LICADHO Monthly Newsbrief (Khmer 08: 32 min)
September 2008
http://www.licadho-cambodia.org/media/index.php?id=143

## ខែតុលា

Press Release: Communities collectively lodge land complaints with authorities in Phnom Penh
October 8, 2008
http://www.licadho-cambodia.org/pressrelease.php?perm=191

Press Release: Courts used as weapon against community representatives
October 29, 2008
http://www.licadho-cambodia.org/pressrelease.php?perm=192

Audio News: LICADHO Monthly News brief (Khmer 10: 05 min)
October 2008
http://www.licadho-cambodia.org/media/index.php?id=144

## ខែវិច្ឆិកា

Press Release: Illegal arrests & Social Affairs centers: Time for Government action, not more denials
November 09, 2008
http://www.licadho-cambodia.org/pressrelease.php?perm=193

Press Release: Civil Society Appeal for Urgent Solution to the Cambodian-Thai Border Dispute
November 17, 2008
http://www.licadhocambodia.org/pressrelease.php?perm=194

Press Release: Violent eviction in Kampot should be halted
November 18, 2008
http://www.licadho-cambodia.org/pressrelease.php?perm=195

Audio News: LICADHO Monthly News brief (Khmer 12:14)
November 2008
http://www.licadho-cambodia.org/media/index.php?id=145

## ខែធ្នូ

Press Release: Open letter regarding forced eviction of Boeung Kak Lake residents
December 4, 2008
http://www.licadho-cambodia.org/pressrelease.php?perm=196

News: Borei Keila: Cambodia's Social Housing Project Five Years On
December 19, 2008
http://www.licadho-cambodia.org/articles/20081219/84/index.html

Audio News: LICADHO Monthly News brief (Khmer 12:14)
December 2008
http://www.licadho-cambodia.org/media/index.php?id=146

□□□